ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

# របាយការណ៍ស្ថានភាព

# សហគមន៍អ្នកក្រីក្រ រាជធានីភ្នំពេញ

ទិន្នន័យអង្កេតអំពីស្ថានភាព

សេដ្ឋកិច្ច សង្គមកិច្ច និងសេវាកម្ម

នៅក្នុងសហគមន៍អ្នកក្រីក្រ រាជធានីភ្នំពេញ







គាំទ្របច្ចេកទេសពី UNICEF និង IP3







រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១២

# អារម្ភកថា



របាយការណ៍បង្ហាញពីលទ្ធផលនៃ"ការវាយតំលៃអំពីស្ថានភាពសហគមន៍អ្នកក្រីក្រនៅក្នុងរាជធានីភ្នំពេញ" ដែលត្រូវបានធ្វើឡើងដើម្បីប្រមូលព័ត៌មានមូលដ្ឋានស្តីពីស្ថានភាពរបស់សហគមន៍អ្នកក្រីក្រនៅក្នុងរាជធានីភ្នំពេញ ។ ការសិក្សាអង្កេតត្រូវបានគ្រោងឡើង និងអនុវត្តដោយការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រ នៃទីចាត់ការផែនការ និងវិនិយោគ សាលារាជធានីភ្នំពេញ។ ការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្របានសហការជាមួយ មន្ទីរផែនការរាជធានីភ្នំពេញ និងបានទទួលជំនួយបច្ចេកទេសពីអង្គការមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) ។ អង្គការយូនីសេហ្វ បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) យោងតាមកិច្ចសន្យាលេខ 12/CP/1201-00 (IP3) ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១២ រវាង គ.ជ.អ.ប និងសាលារាជធានីភ្នំពេញ។

ការវាយតំលៃបានផ្តល់ពីស្ថានភាពទូទៅមួយអំពីជីវភាពរស់នៅ ស្ថានភាពសង្គម សេដ្ឋកិច្ច និងបញ្ហានានាដែលសហគមន៍អ្នកក្រីក្រ បានជួបប្រទះនៅតាមខណ្ឌទាំង ៩ ក្នុងរាជធានីភ្នំពេញ ។ លើសពីនេះទៅទៀត ការវាយតំលៃធ្វើឲ្យយើងបានពិនិត្យឡើងវិញនូវសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធដែលមាននៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ។ ការប្រមូលទិន្នន័យជាប្រព័ន្ធដំបូងមួយ សំដៅសម្រួលដល់ការកសាងផែនការអន្តរាគមន៍អភិវឌ្ឍន៍សមស្របដើម្បីដោះស្រាយរាល់តំរូវការរបស់គ្រួសារក្រីក្រនៅក្នុងរាជធានីភ្នំពេញ ។ ជាមួយគ្នានេះដែរ ឯកសារបានផ្តល់នូវអនុសាសន៍ជាក់លាក់មួយចំនួនលើសកម្មភាពដែលអាចធ្វើបានពីសំណាក់អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ ។

តាមរយៈការបោះពុម្ពផ្សព្វផ្សាយនូវរបាយការណ៍នេះ សាលារាជធានីភ្នំពេញសូមចែករំលែកលទ្ធផលនៃការវាយតំលៃជាមួយបណ្តាអ្នកពាក់ព័ន្ធ និងដៃគូទាំងឡាយ ដែលកំពុងបំពេញការងារកែលំអស្ថានភាពសហគមន៍អ្នកក្រីក្រនៅក្នុងរាជធានីភ្នំពេញ ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះដៃគូទាំងអស់ ដូចជា លេខាធិកាដ្ឋាន គ.ជ.អ.ប និងអង្គការយូនីសេហ្វ ដែលបានជួយគាំទ្រដល់ការសិក្សាអង្កេត និងការចងក្រងជាឯកសារនេះឡើង ។ ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំនៃការិយាល័យអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលបានសហការ និងរួមចំណែកដល់ការសិក្សាអង្កេតនេះ ។

យើងនាំគ្នាកសាងលើមូលដ្ឋានគ្រឹះ ដែលបានស្ថាបនាឡើងរួចមកហើយនេះ នៅតាមសហគមន៍ក្រីក្រជាច្រើនក្នុងរាជធានីភ្នំពេញ និងរួមគ្នាបន្តកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះទាំងអស់គ្នា ។

រាជធានីភ្នំពេញ, ថ្ងៃទី 10 ខែ ធ្នូ ឆ្នាំ ២០១២

**អភិបាលរាជធានីភ្នំពេញ**

**កែប ជុតិមា**

# មាតិកា

អារម្ភកថា

បញ្ជីតារាង ........ ៣

តារាងរូបភាព ........ ៣

តារាងពាក្យបំព្រួញ ........ ៤

1. សេចក្តីផ្តើម ........ ៥

2. សាវតារ ........ ៦

3. គោលបំណងនៃការវាយតម្លៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ ........ ៧

4. វិធីសាស្ត្រ ........ ៧

4.1 វិធីសាស្ត្រស្រាវជ្រាវ ........ ៧

4.2 ទំហំសំណាកគំរូ និង ទីតាំងវាយតម្លៃ ........ ៨

4.3 ដែនកំណត់ ........ ៩

5. លទ្ធផលរកឃើញ ........ ១០

5.1 ប្រជាសាស្ត្រនៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ ........ ១០

5.1.1 វិសាលភាពនៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ ........ ១០

5.1.2 តំបន់តាំងទីលំនៅបណ្តោះអាសន្ន ........ ១២

5.1.3 ប្រភេទផ្ទះ ........ ១៣

5.1.4 ទំហំគ្រួសារ ........ ១៤

5.1.5 សមាមាត្រនៃស្ថានភាពរបស់កុមារ និង យេនឌ័រ ........ ១៥

5.1.6 មេគ្រួសារ ........ ១៧

5.1.7 ប្រជាពលរដ្ឋងាយរងគ្រោះ ក្នុងចំណោមអ្នកក្រីក្រក្នុងរាជធានី ........ ១៨

5.2 ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ........ ១៩

5.2.1 មុខរបរ និង ប្រភពចំណូល ........ ១៩

5.2.2 ចំណូលគ្រួសារ ........ ២២

5.2.3 ទ្រព្យសម្បត្តិគ្រួសារ ........ ២៣

5.2.4 ស្ថានភាពបំណុល ........ ២៤

5.3 សមត្ថភាពសេវាកម្ម និង ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ........ ២៥

5.3.1 ទឹកស្អាត និង អនាម័យ ........ ២៦

5.3.2 ការថែទាំសុខភាព ........ ២៩
5.3.2.1 សេវាសុខភាពជាមូលដ្ឋាន ........ ២៩
5.3.2.2 សុខភាពមាតានិង កុមារ ........ ៣០
5.3.3 សេវាអប់រំ ........ ៣២
5.3.3.1 ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ........ ៣៣
5.3.3.2 ការទៅរៀន ........ ៣៤
5.3.4 កិច្ចការពារកុមារ ........ ៣៥
5.3.4 ការរៀបចំសហគមន៍ និង ហេដ្ឋារចនាសម្ព័ន្ធសេវាសង្គម ........ ៣៥
6 សេចក្តីសន្និដ្ឋាន ........ ៣៧
6.1 ស្ថានភាពទូទៅ - ទីតាំងនៃការតាំងទីលំនៅ និង ប្រជាសាស្ត្រ ........ ៣៧
6.2 ស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ច ........ ៣៨
6.3 ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទឹកស្អាត និងអនាម័យ ........ ៣៩
6.4 ស្ថានភាពសុខភាព ........ ៤០
6.5 ការអប់រំ ........ ៤០
6.6 កិច្ចការពារកុមារ ........ ៤១
7 អនុសាសន៍/សកម្មភាព ........ ៤២
8 ឯកសារភ្ជាប់ ........ ៤៥
ឧបសម្ព័ន្ធ ១ ៖ ផែនទីខណ្ឌ ........ ៤៥
ផែនទីខណ្ឌ តំបន់មានព័ណបង្ហាញអំពីសង្កាត់ដែលបានចងក្រងសហគមន៍អ្នកក្រីក្រក្នុងរាជធានី ........ ៤៥
ឧបសម្ព័ន្ធ ២ ៖ ចំនួនសង្កាត់ ចំនួនភូមិ ដែលមានសហគមន៍ចងក្រង និង ចំនួនសហគមន៍ចងក្រងរួច តាមទិន្នន័យបច្ចុប្បន្នភាព ........ ៥៣
ឧបសម្ព័ន្ធ ៣ ៖ បញ្ជីឈ្មោះសហគមន៍អ្នកក្រីក្រ តាមខណ្ឌ សង្កាត់ និង ភូមិ ........ ៥៤
ឧបសម្ព័ន្ធ ៤ ៖ កម្រងសំណួរសម្រាប់ធ្វើសម្ភាសន៍គ្រួសារនៅតាមសហគមន៍អ្នកក្រីក្រ ........ ៦៩
ឧបសម្ព័ន្ធ ៥ ៖ ផែនទីខណ្ឌ កម្រងសំណួរសម្រាប់សម្ភាសន៍សហគមន៍អ្នកក្រីក្រ ........ ៧៨

## បញ្ជីតារាង

**តារាងទី 1 : ទំហំគំរូក្នុង ១ ខណ្ឌ ៖ សម្ភាសន៍ជាមួយតំណាងសហគមន៍ និង គ្រួសារ** ........ ៩
តារាងទី 2 : ចំនួនប្រជាពលរដ្ឋប៉ាន់ស្មានក្នុងឃុំចំនួន ២៨១ ........ ១០
តារាងទី 3 : តំបន់សម្រាប់ដំណោះស្រាយលើគ្រួសារបានសម្ភាសន៍ ........ ១២
តារាងទី 5 : ចំនួនប្រជាពលរដ្ឋបែងចែកតាមយេនឌ័រ និង សមាមាត្រកុមារ ........ ១៦
តារាងទី 6 : មេគ្រួសារតាមខ្នងផ្ទះ ក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី ........ ១៨
**តារាងទី 7 : មុខរបរ ឬ ប្រភពសំខាន់នៃចំណូលរបស់ប្រជាពលរដ្ឋក្នុងសហគមន៍** ........ ២០
តារាងទី 8 : មធ្យោបាយធ្វើដំណើរ ........ ២៣
តារាងទី 9 : មធ្យោបាយប្រាស្រ័យទាក់ទង/ព័ត៌មាន ........ ២៤
តារាងទី 10 : មូលហេតុនាំឲ្យគ្រួសារទៅខ្ចីលុយគេ ........ ២៥
តារាងទី 11 : ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និង អនាម័យ ........ ២៧
តារាងទី 12 : ការផ្តល់សេវាសុខាភិបាល ........ ២៩
តារាងទី 13 : ការប្រើប្រាស់សេវាសុខាភិបាល ........ ៣១
តារាងទី 14 : ការអប់រំមត្តេយ្យសិក្សា និង បឋមសិក្សា ........ ៣៣
តារាងទី 15 : វត្តមានសិស្សទៅរៀននៅសាលា តាមកម្រិតផ្សេងៗ ........ ៣៤
តារាងទី 16 : ការរៀបចំសហគមន៍ និង សេវាសង្គម ........ ៣៦

## តារាងរូបភាព

រូបភាពតួលេខទី 1 : ទំហំគ្រួសារអ្នកក្រីក្រក្នុងរាជធានី ធៀបនឹងជម្រឿន និង គម្រោង CRUMP ........ ១៥

រូបភាពតួលេខទី 2 : ចំនួនកុមារធៀបនឹងជម្រឿន និង គម្រោង CRUMP ........ ១៦

រូបភាពតួលេខទី 3 : ភាគរយនៃស្ត្រី និង បុរស តួលេខទី 4 : សមាមាត្រកុមារ ........ ១៧

រូបភាពតួលេខទី 5 : សមាមាត្រគ្រួសារ ជាមួយសមាជិកក្នុងគ្រួសារ មកពីក្រុមងាយរងគ្រោះ ........ ១៩

រូបភាពតួលេខទី 6 : កម្រិតចំណូលតាមគ្រួសារ ........ ២២

រូបភាពតួលេខទី 7 : ចំនួនផ្ទះមានបង្គន់អនាម័យប្រើប្រាស់ ធៀបនឹងកម្រិតចំណូល ........ ២៨

រូបភាពតួលេខទី 8 : អ្នកខាងក្រៅផ្តល់ការគាំទ្រដល់សហគមន៍អ្នកក្រីក្រទាំង ២១២ ក្នុងរាជធានី ........ ៣៧

## តារាងពាក្យបំព្រួញ

| | |
|---|---|
| CDHS | អង្កេតប្រជាសាស្ត្រ និង សុខភាពកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CRUMP | គម្រោងអង្កេតសិក្សាស្រាវជ្រាវពីការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា ពីតំបន់ជនបទ ទៅតំបន់ទីប្រជុំជន (ឆ្នាំ ២០១១) |
| CSES | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| NCDD | គណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ |
| SSC | គណៈកម្មការទ្រទ្រង់សាលារៀន |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) |
| VHSG | ក្រុមទ្រទ្រង់សុខភាពភូមិ |

## ១. សេចក្តីផ្តើម

ចាប់ពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ២០១១ សាលារាជធានីភ្នំពេញបានកំណត់តំបន់ក្រីក្រក្នុងរាជធានីភ្នំពេញចំនួន ៥១៦ កន្លែង ក្នុងនោះមានតំបន់ចំនួន ៣៤២ កន្លែង ដែលមកទល់បច្ចុប្បន្ននេះ ត្រូវបានទទួលស្គាល់ និង រៀបចំជាសហគមន៍ និង ១៧៤ កន្លែងទៀតនៅមិនទាន់បានទទួលស្គាល់ និង រៀបចំនៅឡើយ។

កិច្ចការរៀបចំសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ គឺជាលទ្ធផលទទួលបានមកពីការប្រកាសរបស់សម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងឆ្នាំ ២០០០ ដែលតាមរយៈនេះ សហគមន៍អ្នកក្រីក្រ ក្នុងរាជធានីភ្នំពេញចំនួន ១០០ គួរត្រូវបានរៀបចំជារៀងរាល់ឆ្នាំ។ ដើម្បីជួយពង្រឹងបន្ថែមលើការអនុវត្តគោល នយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍ និង កាត់បន្ថយភាពក្រីក្រ នៅតាមសហគមន៍អ្នកក្រីក្រក្នុង រាជធានីភ្នំពេញ សាលារាជធានីភ្នំពេញបានបង្កើតការិយាល័យទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុង រាជធានីភ្នំពេញ ជាផ្នែកមួយនៃទីចាត់ការផែនការ និង វិនិយោគ រាជធានីភ្នំពេញ។

នៅពេលការិយាល័យទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រ ក្នុងរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១០ វាបានក្លាយជាភស្តុតាងមួយយ៉ាងឆាប់រហ័សថា ត្រូវការឲ្យមានការសិក្សាវាយតម្លៃបឋមជាលក្ខណៈ ប្រព័ន្ធមួយទៅលើសហគមន៍អ្នកក្រីក្រ អំពីលក្ខខណ្ឌជីវភាពរស់នៅ និងសេចក្តីត្រូវការចាំបាច់របស់ប្រជាពល រដ្ឋ។

ការសិក្សារអង្កេតមួយត្រូវបានគ្រោងធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០១១ និង បានធ្វើការប្រមូលទិន្នន័យ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដែលក្នុងនោះគេបានធ្វើសម្ភាសន៍ក្រុមគ្រួសារជាសំណាកគំរូចំនួន ២.០៣៣ គ្រួសារ និង តំណាងសហគមន៍ចំនួន ២៨១ នាក់ មួយរយៈពេលនៃការធ្វើអង្កេតនោះ។ ការវាយតម្លៃនេះ បានផ្តោតលើស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រជាពលរដ្ឋក្រីក្រក្នុងរាជធានីភ្នំពេញ និងសមត្ថភាពដែល មានស្រាប់ ក្នុងការផ្តល់សេវាសង្គមជាសំខាន់វិស័យសុខភាព អប់រំ ទឹកស្អាត និងអនាម័យ កិច្ចការពារកុមារ និងហេដ្ឋារចនា-សម្ព័ន្ធសាធារណៈ។ ក្នុងអំឡុងពេលធ្វើវិភាគ និង រាយការណ៍ ពីទិន្នន័យទទួលបានពីការវាយ តម្លៃនេះ គេតែងធ្វើការប្រៀបធៀបជាមួយទិន្នន័យផ្សេងៗទៀតដូចជា ទិន្នន័យ បានមកពីគម្រោង (CRUMP) ជម្រឿនប្រជាពលរដ្ឋឆ្នាំ ២០០៨ និង អង្កេតផ្សេងៗទៀត ដូចបានបញ្ជាក់ជូនស្រាប់។

របាយការណ៍នេះ មិនមានសេចក្តីសង្ខេបទេ ប៉ុន្តែសេចក្តីសង្ខេបរួមនៃលទ្ធផលសំខាន់ៗ ដែលបានរកឃើញ អាចរកមើលបាននៅក្នុងចំណុចទី **៦. សេចក្តីសន្និដ្ឋាន**។

## ២. សាវតារ

ក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងមកនេះ សាលារាជធានីភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័សជាមួយនឹងកំណើនពីរដងនៃចំនួនប្រជាពលរដ្ឋនៅឆ្នាំ ១៩៩៨-២០០៨[១] ដែលភាគច្រើនគឺបណ្តាលមកពីការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជាពីទីជនបទមកស្វែងរកការងារធ្វើនៅក្នុងរាជធានី។ មានការប៉ាន់ប្រមាណថានៅក្នុងឆ្នាំ ១៩៩៨ ក្នុងចំណោមប្រជាពលរដ្ឋ ២០ នាក់រស់នៅក្នុងរាជធានីភ្នំពេញ គឺមានប្រជាពលរដ្ឋម្នាក់មកពីទីជនបទ ប៉ុន្តែនៅក្នុងឆ្នាំ ២០១២ ក្នុងចំណោមប្រជាពលរដ្ឋ ១០ នាក់[២] គឺមានប្រជាពលរដ្ឋម្នាក់មកពីទីជនបទ។ ជាមួយនិងការព្យាករណ៍ថា មានប្រជាពលរដ្ឋចំនួន ១ លាន ៦ សែននាក់ នៅឆ្នាំ ២០១២ សាលារាជធានីបានប៉ាន់ស្មានថា ប្រជាពលរដ្ឋនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី នឹងមានចំនួនប្រហែលជាមួយភាគបួននៃអ្នករស់នៅក្នុងរាជធានី។

ការព្យាករណ៍ចំនួនប្រជាពលរដ្ឋផ្អែកលើមូលដ្ឋានទិន្នន័យនៃការវាយតម្លៃ យ៉ាងហោចណាស់ត្រូវប៉ាន់ស្មានចំនួនប្រជាពលរដ្ឋនៅក្នុងតំបន់អ្នកក្រីក្រក្នុងរាជធានីចំនួន ៥១៦ សហគមន៍ ថាមានមួយភាគបួនក្នុងចំណោមប្រជាពលរដ្ឋចំនួនមួយលាននាក់។

ការធ្វើនគរូបនីយកម្មគ្មានផែនការ និងកំណើនយ៉ាងឆាប់រហ័សនៃប្រជាពលរដ្ឋ បានបង្កឱ្យមានភាពក្រីក្រដែលចេះតែច្រើនឡើងៗ។ ការពង្រីករាជធានី មិនទាន់បានស្របគ្នាជាមួយនឹងការធ្វើវិនិយោគលើវិស័យសេវាសង្គមនៅឡើយ។ ជាការពិត ការធ្វើវិនិយោគជាអាទិភាពលើបញ្ហាស្ត្រី និង កុមារ នៅមានកំរិតទាបនៅឡើយ បើប្រៀបធៀបជាមួយនិងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ទិន្នន័យ ស្តីពីសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ និងស្ថានភាពលក្ខខណ្ឌរស់នៅរបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ ដោយសារតែកង្វះខាតប្រព័ន្ធប្រមូល និងវិភាគទិន្នន័យ ដែលជាកត្តារាំងស្ទះដល់ការបង្កើតជារបាយការណ៍ស្តីពីសូចនាករសង្គមសំខាន់ៗ សម្រាប់យកមកប្រើប្រាស់ធ្វើជាភស្តុតាងក្នុងការរៀបចំកសាងផែនការ កៀរគរធនធាន និងធ្វើអន្តរាគមន៍។

ជាការឆ្លើតតប រាជធានីភ្នំពេញបានរៀបចំផែនការ និងបានអនុវត្តន៍ធ្វើការវាយតម្លៃនេះឡើង ក្នុងគោលបំណងប្រមូល និងចែករំលែកព័ត៌មាន ព្រមទាំងពង្រឹងសមត្ថភាពផ្ទាល់របស់ខ្លួន ក្នុងការរៀបចំដោយឯករាជ្យនូវការធ្វើអង្កេត និងគ្រប់គ្រងទិន្នន័យ។

---

[១] របាយការណ៍គម្រោង CRUMP ទំព័រទី ១៨

[២] របាយការណ៍គម្រោង CRUMP ទំព័រទី ១

## 1. គោលបំណងនៃការវាយតម្លៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ

១. សិក្សាទៅលើស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់គ្រួសារអ្នកក្រីក្ររស់នៅក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន ជាពិសេសស្ត្រី និងកុមារ ដែលកំពុងរស់នៅតាមសហគមន៍អ្នកក្រីក្រចំនួនរាប់រយកន្លែងនៅក្នុងរាជធានីភ្នំពេញ។ ការវាយតម្លៃនេះ បានផ្តោតជាសំខាន់ទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច សុខភាព ទឹកស្អាត/អនាម័យ ការងារអប់រំ និង កិច្ចការពារកុមារ។

២. ឆ្លុះបញ្ចាំងឱ្យឃើញហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ សមត្ថភាព និងការទទួលបានសេវាសង្គម ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់គ្រួសារដែលងាយរងគ្រោះ។

៣. ពង្រឹងសមត្ថភាពការិយាល័យទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រ ក្នុងការប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធ និងវិភាគទិន្នន័យ។

៤. ចែករំលែកព័ត៌មានដែលប្រមូលបាន ជូនដៃគូរពាក់ព័ន្ធសម្រាប់ធ្វើផែនការ កៀរគរធនធាន និងជួយអន្តរាគមន៍ចំពោះការអភិវឌ្ឍតំបន់អ្នកក្រីក្រនៅក្នុងរាជធានីភ្នំពេញ ដោយផ្តោតលើសេវាសង្គម សម្រាប់កុមារ និងគ្រួសារងាយរងគ្រោះ។

## 2. វិធីសាស្ត្រ

### 4.1 វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាអង្កេតនេះត្រូវបានរៀបចំធ្វើឡើងដោយការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី និង ប្រើវិធីសាស្ត្រតាមលក្ខណៈមានការចូលរួមខ្ពស់ ដោយផ្តល់ឱកាសជូនមន្ត្រីរាជការស៊ីវិល មកពី រាជធានីភ្នំពេញបានចូលរួមពាក់ព័ន្ធ និង តំណាងសហគមន៍មកពីគ្រប់ជាន់ថ្នាក់។ ទិន្នន័យបឋមដំបូងស្តីពីសហគមន៍អ្នកក្រីក្រក្នុងរាជធានីត្រូវបានប្រមូល មន្ត្រីមកពីខណ្ឌទាំង ៩ ត្រូវបានអញ្ជើញមកធ្វើការពិគ្រោះ និងណែនាំអំពីគោលបំណងនៃការវាយតម្លៃ និងរៀបចំផែនការអនុវត្តន៍បន្តដល់ថ្នាក់សង្កាត់ និងថ្នាក់ភូមិ។ សូចនាករ និងរូបមន្តសម្រាប់កម្រងសំណួរ ត្រូវបានរៀបចំឡើងដោយផ្តោតលើសូចនាករស្តីពីសង្គមកិច្ច និង សេដ្ឋកិច្ច ឆ្លុះបញ្ចាំងស្ថានភាព និងភាពងាយរងគ្រោះរបស់ក្រុមគ្រួសារ ពីតំបន់សហគមន៍អ្នកក្រីក្រក្នុងរាជធានី។ លទ្ធផលដែលទទួលបានគឺបានរៀបចំកម្រងសំណួរចំនួន ២ កម្រង ៖



ការសម្ភាសន៍តំណាងសហគមន៍

- កម្រងសំណួរទី ១ សម្រាប់ធ្វើសម្ភាសន៍អ្នកមានភារៈកិច្ចជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានដើម្បីប៉ាន់ប្រមាណមើលសមត្ថភាព និងវត្តមានសេវាបច្ចុប្បន្នដែលមានស្រាប់នៅក្នុងសហគមន៍អ្នកក្រីក្រនិមួយៗក្នុងរាជធានី។
- កម្រងសំណួរទី ២ សម្រាប់សម្ភាសន៍ស៊ីជម្រៅជាមួយក្រុមគ្រួសារនីមួយៗដែលត្រូវបានកំណត់យក ដើម្បីប៉ាន់ប្រមាណមើលស្ថានភាពរស់នៅ និងការទទួលបានសេវាសង្គមរបស់ពួកគាត់។


សិក្ខាសាលាស្តីពីការប្រមូលទិន្នន័យសម្រាប់ជនបង្គោលមកពីសហគមន៍អ្នកក្រីក្រក្នុងរាជធានី

បន្ទាប់មក ការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យ និងវិធីសាស្ត្រសម្ភាសន៍ ជូនដល់មន្ត្រីមកពីខណ្ឌ រាប់បញ្ចូលទាំងទីប្រឹក្សា អាយ.ភី ៣ ទទួលបន្ទុកជាអភិបាលរង មន្ត្រីសេវាសង្គម និងសហព័ន្ធសាមគ្គីភាពសហគមន៍អ្នកក្រីក្រក្នុងទីក្រុង (**សាប់ហ្វ**) ផងដែរ។ មន្ត្រីទាំងនេះបានរៀបចំវគ្គបណ្តុះបណ្តាលដូចគ្នានេះដែរ សម្រាប់ចៅសង្កាត់ និង ប្រធានភូមិ ដែលបន្ទាប់មកជាអ្នករៀបចំសម្ភាសន៍ តាមគ្រួសារនិមួយៗ។ ដោយសារការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី មានធនធានមនុស្ស និងមានសមត្ថភាពកំណត់ទីប្រឹក្សា ផអ៣ និងបុគ្គលិកអង្គការយូនីសេហ្វតំបន់ភ្នំពេញ បានផ្តល់ការគាំទ្រយ៉ាងសកម្មក្នុងការរៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាល។ ទិន្នន័យត្រូវបានប្រមូលក្នុងឆ្នាំ ២០១១ និងបន្ទាប់មកការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី បានតម្លើងប្រព័ន្ធទិន្នន័យ SPSS និងចាប់ផ្តើមបញ្ចូលទិន្នន័យ និងធ្វើវិភាគ។ ដោយស្ថិតក្នុងដំណើរ ការរៀនសូត្រការរីកចម្រើនក្នុងការធ្វើវិភាគ និងការធ្វើរបាយការណ៍ទាមទារពេលវេលា និងអាចបញ្ចប់នៅក្នុងពាក់កណ្តាលឆ្នាំ ២០១២ ដោយមានជំនួយបច្ចេកទេសពីអង្គការយូនីសេហ្វ។

## 4.2 ទំហំសំណាកគំរូ និង ទីតាំងវាយតម្លៃ

សហគមន៍ដែលគេបានយកមកធ្វើជាគំរូ ត្រូវបានបែងចែកតាមសមាមាត្រនៅក្នុងខណ្ឌទាំង ៩ និងសង្កាត់ចំនួន ៥២ ដែលមានសហគមន៍អ្នកក្រីក្រក្នុងរាជធានី។ ផ្ទះដែលបានយកមកធ្វើជាគំរូ ត្រូវបានជ្រើសរើសដោយព្រាវៗ។ ជាទូទៅ ទំហំដែលត្រូវកំណត់យកមកធ្វើជាគំរូមាន ៖ ការសម្ភាសមនុស្សចំនួន ២.០៣៣ នាក់នៅក្នុងគ្រួសារអ្នកក្រីក្រក្នុងរាជធានី និង សម្ភាសន៍តំណាងសហគមន៍ចំនួន ២៨១ នាក់។

តារាងទី 1 : ទំហំសំណាកគំរូក្នុង ១ ខ័ណ្ឌ ៖ ធ្វើសម្ភាសន៍តំណាងសហគមន៍ និង គ្រួសារ

| ឈ្មោះខណ្ឌ | ធ្វើសម្ភាសន៍ តំណាងសហគមន៍ | ភាគរយក្នុង ១ ខណ្ឌ | ធ្វើសម្ភាសន៍ គ្រួសារនិមួយៗ | ភាគរយក្នុង ១ ខណ្ឌ |
|---|---|---|---|---|
| ចំការមន | 32 | 11.4% | 112 | 5.5% |
| ដូនពេញ | 24 | 8.5% | 125 | 6.1% |
| ៧មករា | 5 | 1.8% | 30 | 1.5% |
| ទួលគោក | 26 | 9. 2% | 172 | 8.5% |
| ដង្កោ | 10 | 3.6% | 138 | 6.8% |
| មានជ័យ | 65 | 23.1% | 421 | 20.7% |
| ឬស្សីកែវ | 68 | 24.2% | 398 | 19.6% |
| សែនសុខ | 19 | 6.8% | 199 | 9.8% |
| ពោធិ៍សែនជ័យ | 32 | 11.4% | 438 | 21.5% |
| **សរុប** | **281** | **100.0%** | **2033** | **100.0%** |

### 4.3 ដែនកំណត់

ដូចបានរៀបរាប់ក្នុងគោលបំណងទី ៣ រួចហើយគឺ ការវាយតម្លៃនេះត្រូវបានរៀបចំឡើងតែ១ ផ្នែកប៉ុណ្ណោះ ដើម្បីជាការកសាងសមត្ថភាព តាមរយៈការរៀនធ្វើកិច្ចការផ្ទាល់ សម្រាប់ការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី ដែលបង្ហាញថាមានប្រសិទ្ធភាពខ្ពស់ និងជាអ្នករៀនសូត្របានឆាប់រហ័ស។ ទោះជាយ៉ាងនេះក្តី ជាការពិតគឺវានៅមានកម្រិតខ្លះ ដែលគួរបញ្ជាក់ពីផលវិបាកក្នុងដំណើរការ និងការវិភាគទិន្នន័យ ហើយក៏ដូចជាការសរសេររបាយការណ៍ដែរ។

- ទោះបីជាវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យបានធ្វើរួចហើយក៏ដោយ ក៏សមត្ថភាពសមាជិកម្នាក់ៗក្នុងក្រុមមានការខុសគ្នាដែរ។ មានកម្រងសំណួរជាច្រើន ជាពិសេសសំណួរដែលបានមកពីការធ្វើសម្ភាសន៍គ្រួសារចំនួន ២.០៣៣ មិនត្រូវបានបំពេញចប់សព្វគ្រប់ទេ។ ជាលទ្ធផលគឺថា មានការបាត់បង់ទិន្នន័យជាច្រើននៅក្នុងរូបមន្ត ដែលនាំឲ្យចំនួនអ្នកឆ្លើយតបសំណួរយកជាការបានមានភាពខុសគ្នា។ នៅក្នុងរបាយការណ៍ ចំនួនសរុបនៃអ្នកឆ្លើយតបសំណួរយកជាការបានបង្ហាញដោយ "N=X"
- មូលហេតុដែលមិនបានបំពេញរូបមន្តមួយចំនួន នៅមិនទាន់មានលក្ខណៈច្បាស់លាស់ទេ។ ទោះជាយ៉ាងនេះក្តី ការពិនិត្យឡើងវិញលើទិន្នន័យ បានបញ្ជាក់យ៉ាងច្បាស់ថា ជាញឹកញាប់គឺមិនបានបំពេញទេ ជាពិសេសលើសំណួរមានលក្ខណៈរសើបដូចជា ការសួរសមាជិកក្នុងគ្រួសារពីរឿងមានជម្ងឺរ៉ាំរ៉ៃ ឬកុមារពិការជាដើម។
- ការយកអាជ្ញាធរ/តំណាងសហគមន៍នៅមូលដ្ឋានមកពាក់ព័ន្ធ និងបុគ្គលិកធ្វើអង្កេតពីខាងក្រៅមិនអព្យាក្រិតក្នុងការប្រមូលទិន្នន័យ អាចបណ្តាលឲ្យកើតជាស្ថានភាពមួយដែលអ្នកផ្តល់ចម្លើយមានអារម្មណ៍មិនស្រួល

ក្នុងការផ្តល់ចម្លើយពិត។

- បញ្ហាផ្សេងៗទៀតមានដូចជា ៖ កង្វះខាតការវាយតម្លៃទៅលើស្ថានភាពអប់រំ និងការធ្វើចំណាកស្រុករបស់ក្រុមគ្រួសារប្រជាពលរដ្ឋ។

## ៣. លទ្ធផលរកឃើញ

### 5.1 ប្រជាសាស្ត្រនៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ

#### 5.1.1 វិសាលភាពនៃសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ

តារាងទី 2 : ចំនួនប្រជាពលរដ្ឋប៉ាន់ស្មានក្នុងឃុំចំនួន ២៨១

| ឈ្មោះខណ្ឌ | ចំនួនសហគមន៍ | សរុបប្រជាពលរដ្ឋ ក្នុង ១ សហគមន៍ | ចំនួនប្រជាពលរដ្ឋ គិតជាមធ្យម ក្នុង ១ សហគមន៍ |
|---|---|---|---|
| ចំការមន | 32 | 5,391 | 168 |
| ដូនពេញ | 24 | 18,460 | 769 |
| ៧ មករា | 5 | 571 | 114 |
| ទួលគោក | 26 | 12,372 | 172 |
| ដង្កោ | 10 | 8,278 | 828 |
| មានជ័យ | 65 | 26,049 | 401 |
| ឫស្សីកែវ | 68 | 20,078 | 295 |
| សែនសុខ | 19 | 11,017 | 580 |
| ពោធិ៍សែនជ័យ | 32 | 23,904 | 747 |
| **សរុប** | **281** | **126,120** | **449** |

សហគមន៍អ្នកក្រីក្រក្នុងរាជធានី បានរីកលូតលាស់ទៅជាកន្លែងតាំងទីលំនៅបណ្តោះអាសន្នមិនផ្លូវការ ហើយ និងមានទីតាំងច្រើននៅរាយប៉ាយគ្រប់ទីកន្លែងក្នុងរាជធានីភ្នំពេញ។ ចាប់ពីឆ្នាំ ១៩៨០ មក រដ្ឋបាលរាជធានីភ្នំពេញបានកំណត់ថាមានសហគមន៍អ្នកក្រីក្រក្នុងរាជធានីចំនួន ៥១៦ កន្លែង ។ នៅក្នុងសហគមន៍ចំនួន ២៨១ ដែលជាផ្នែកមួយនៃការធ្វើអង្កេតនេះ គឺតំណាងសហគមន៍បានប៉ាន់ស្មានថា មានប្រជាពលរដ្ឋសរុបចំនួន ១២៦.១២០ នាក់។ ដូច្នេះ គិតជាមធ្យមគឺ ក្នុងមួយសហគមន៍ មានមនុស្សចំនួន ៤៤៩ នាក់រស់នៅ។ ទោះជាយ៉ាងនេះក្តី ក៏នៅតែមានសហគមន៍ចំនួនច្រើនទៀតនៅឡើយ ដែលមានទំហំតូចៗ។ ក្នុងរង្វង់ ១ ភាគ ៤ ដំបូង (គឺ ២៥% នៃសហគមន៍) នៅតាមកកន្លែងតាំងទីលំនៅបណ្តោះអាសន្ន មានអ្នករស់នៅចំនួនត្រឹមតែ ១៣០ នាក់ ប៉ុណ្ណោះ ឬ តិចជាងនេះ។



ឧទាហរណ៍នៃទីកន្លែងតាំងទីលំនៅបណ្តោះអាសន្ន តាមមាត់ទន្លេ តាមផ្លូវរថភ្លើង និងតាមប្រព័ន្ធលូទឹកស្អុយ (ប្រភព ៖ ការធ្វើសម្ភាសន៍តំណាងសហគមន៍)

តារាងទី ២: បង្ហាញថា នៅចំកណ្តាលរាជធានី គឺនៅក្នុងខណ្ឌ ៧ មករា សហគមន៍ដែលមានទំហំជាមធ្យម គឺមានប្រជាពលរដ្ឋរស់នៅតិចបំផុត គឺមានចំនួនត្រឹមតែ ១១៤ នាក់ ក្នុង ១ សហគមន៍ប៉ុណ្ណោះ ដែលបន្ទាប់មកទៀតគឺជាខណ្ឌចំការមន ដែលមានប្រជាពលរដ្ឋរស់នៅជាមធ្យមចំនួន ១៦៩ នាក់ ក្នុង ១ សហគមន៍។ គេឃើញមានការកើនឡើងខ្លាំងនូវទំហំសហគមន៍អ្នកក្រីក្រក្នុងរាជធានី ដែលមានចំនួនខុសៗគ្នា គិតជាមធ្យមគឺមានចំនួនពី ៦០០ ទៅ ៧០០ នាក់ និង មានច្រើននាក់នៅតាមខណ្ឌដូចជា ខណ្ឌដង្កោ នៅប៉ែកខាងត្បូងរាជធានីភ្នំពេញ គឺគិតជាមធ្យមមានប្រជាពលរដ្ឋចំនួន ៨២៨ នាក់ រស់នៅក្នុង ១ កន្លែងតាំងទីលំនៅបណ្តោះអាសន្ន។




| ល.រ | ឈ្មោះខណ្ឌ | ចំនួនសង្កាត់ | ចំនួនសហគមន៍ |
|---|---|---|---|
| 1 | ចំការមន | 5 | 34 |
| 2 | ដូនពេញ | 8 | 41 |
| 3 | ៧ មករា | 2 | 13 |
| 4 | ទួលគោក | 5 | 26 |
| 5 | ដង្កោ | 6 | 11 |
| 6 | មានជ័យ | 9 | 72 |
| 7 | ឫស្សីកែវ | 10 | 82 |
| 8 | សែន សុខ | 3 | 24 |
| 9 | ពោធិ៍សែនជ័យ | 4 | 32 |
| | សរុប | 52 | 335 |

### 5.1.2 តំបន់តាំងទីលំនៅបណ្តោះអាសន្ន

តំបន់តាំងទីលំនៅបណ្តោះអាសន្នជាទូទៅ គឺជាកន្លែងរស់នៅមានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ជាមួយ ស្ថិតនៅខាងក្នុង និងខាងក្រៅរាជធានី រួមមាននៅតាមផ្លូវសំខាន់ៗ តាមបណ្តោយផ្លូវរថភ្លើងតាមប្រឡាយលូទឹក ហើយក៏មាននៅតាមបឹង និងនៅលើដំបូលអគារនានាផងដែរ។ មកទល់និងឆ្នាំថ្មីៗនេះ យើងឃើញថានៅមិនទាន់មានច្បាប់ ស្តីពីការគ្រប់គ្រងលំហូរប្រជាពលរដ្ឋចូលទៅនៅលើដីសាធារណៈនៅឡើយទេ។ អាជ្ញាធរបានអនុគ្រោះ ឬ មិនបានអនុវត្តបទបញ្ញានានា និងបណ្តោយឱ្យប្រជាពលរដ្ឋមានឱកាសតាំងទីលំនៅ។

**តារាងទី 3 : តំបន់តាំងទីលំនៅបណ្តោះអាសន្ននៃក្រុមគ្រួសារដែលបានសម្ភាសន៍**

| តំបន់តាំងទីលំនៅបណ្តោះអាសន្ន | ចំនួនគ្រួសារ N=627 | ភាគរយ |
|---|---|---|
| លូបង្ហូរទឹកស្អុយ | 161 | 25.7% |
| ច្រាំងទន្លេ | 142 | 22.6% |
| ចិញ្ចើមផ្លូវ | 110 | 17.5% |
| ផ្លូវរថភ្លើង | 108 | 17.2% |
| លើដំបូលអាគារ | 30 | 4.8% |
| នៅតាមបឹង | 22 | 3.5% |
| វត្តអារាម/ចេតិយ | 12 | 1.9% |
| ផ្សេងៗ | 42 | 6.7% |
| **សរុបចម្លើយ** | 627 | |

(ប្រភព៖ ការសម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

ផែនទីបង្ហាញប្រភេទ លក្ខណៈ ភិនភាគនៃតំបន់តាំងទីលំនៅបណ្តោះអាសន្ន។ ផែនទីបង្ហាញថាប្រព័ន្ធលូបង្ហូរទឹកស្អុយនៅក្នុងខណ្ឌទាំងអស់ គឺជាតំបន់សហគមន៍អ្នកក្រីក្ររស់នៅក្នុងរាជធានី។ លើសនេះទៀត នៅក្នុងខណ្ឌប៉ែកខាងជើងតាមបណ្តោយផ្លូវរថភ្លើង ក្នុងទិសទៅខេត្តបាត់ដំបង និងខេត្តព្រះសីហនុ គឺជាកន្លែងដែលគេចូលចិត្ត ខណៈដែលគ្រប់ខណ្ឌមានព្រំប្រទល់ជាប់នឹងទន្លេ គឺមានតំបន់តាំងទីលំនៅបណ្តោះ អាសន្ន នៅជិតទឹកតែម្តង។ បញ្ហាទូទៅមួយដែលសហគមន៍អ្នកក្រីក្រក្នុងរាជធានីភាគច្រើនបំផុតមានជារួមនោះគឺថា ពួកគេបានអភិវឌ្ឍន៍នៅលើដីសាធារណៈ។

ការរីកចម្រើន និង ទំនើបនីយកម្មដ៏ឆាប់រហ័សនៃរាជធានីភ្នំពេញបច្ចុប្បន្ន មានន័យថា រាជធានីត្រូវការដី និង ត្រូវការអភិវឌ្ឍន៍បន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ។ ការកើនឡើងទ្វេដងនេះ បង្កជាការប្រឈមដ៏ធំធេងមួយដែលទាមទារឲ្យមានដំណោះស្រាយសមស្របដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ និង តម្រូវការរបស់សហគមន៍នៅតំបន់អ្នកក្រីក្រក្នុងរាជធានី។ យោងតាមការិយាល័យនៃសាលារាជធានី គឺមកទល់និងឆ្នាំ ២០០៨ មានសហគមន៍អ្នកក្រីក្រក្នុងរាជធានីចំនួន ៤២ កន្លែង បានផ្លាស់ប្តូរទីតាំងទៅរស់នៅក្នុងតំបន់តាំងទីលំនៅបណ្តោះអាសន្នដែលបានអភិវឌ្ឍន៍។



ផ្ទះឈើដំបូលស័ង្កសី និង ផ្ទះថ្ម នៅក្នុងសង្កាត់អណ្តូង ៣ កោះរកា សែនសុខ



ទោះបីការពិតគេបានប្រើប្រាស់ដីសាធារណៈសម្រាប់តាំង ទីលំនៅបណ្តោះអាសន្នក៏ដោយ ក៏មានក្រុមគ្រួសារចំនួន ៨៣% ក្នុងចំណោមអ្នកឆ្លើយតបសំណួរសម្ភាសន៍ (N-1578) បានឆ្លើយប្រាប់ដែរថា "ជាផ្ទះផ្ទាល់របស់ពួកគាត់" ដែលជាទ្រព្យសម្បត្តិរបស់ពួកគាត់។ យើងអាចសន្មត់បានថា ពួកគាត់ក៏មានគំនិតគិតដែរថា ដីដែលពួកគាត់បានសង់ផ្ទះនៅពីលើនោះ ក៏ជាទ្រព្យសម្បត្តិរបស់ពួកគាត់ដែរ។

### 5.1.3 ប្រភេទផ្ទះ

ផ្ទះឈើធម្មតាមួយមានមួយបន្ទប់ គឺជាប្រភេទទីលំនៅសំខាន់មួយ នៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី។ នៅតំបន់ដែលងាយប្រឈមនឹងទឹកជំនន់ ពួកគាត់សង់ផ្ទះនៅលើធុងបណ្តែត (ជាក្បូន) តាមលក្ខណៈប្រពៃណីនៅជនបទ។ ពាក្យថា "ផ្ទះថ្ម" គឺមានន័យថា ជាអគារផ្ទះតូចធ្វើពីឥដ្ឋ ឬ អគារផ្ទះល្វែង។ ជាពិសេស នៅកន្លែងតំបន់តាំងទីលំនៅបណ្តោះអាសន្ន វាជាផ្ទះថ្មតូចដែលភាគច្រើនសាងសង់ដោយមានការគាំទ្រពីជំនួយខាងក្រៅ ឬ ការគាំទ្ររបស់រាជរដ្ឋាភិបាល។ ទីលំនៅភាគច្រើនគឺជាលំនៅស្ថានអចិន្ត្រៃយ៍ ដែលប្រជាពលរដ្ឋគិតថា វាជាទ្រព្យសម្បត្តិរបស់ពួកគាត់។ ក្នុងចំណោមអ្នកឆ្លើយតបសំណួរសម្ភាសន៍ គឺមានតែ ១៧% ប៉ុណ្ណោះ ដែលបាននិយាយប្រាប់ថា ពួកគាត់ "ជួល" កន្លែងពីគេសម្រាប់ស្នាក់នៅ និង រស់នៅ។ មានប្រជាពលរដ្ឋមួយចំនួនតូច គឺត្រឹមតែ ២% ប៉ុណ្ណោះ ដែលកំពុងរស់នៅតាមជម្រកមានលក្ខណៈបណ្តោះអាសន្ន។

**តារាងទី ៤ ៖ ការសាងសង់ផ្ទះ**

| ប្រភេទផ្ទះ | ចំនួនផ្ទះ (N=1325) | ភាគរយ |
|---|---|---|
| ផ្ទះឈើដំបូលស័ង្កសី ឬ ហ្វីប្រូស៊ីម៉ង់ត៍ ផ្ទះថ្ម | 848 | 64.9% |
| ផ្ទះថ្ម | 206 | 15.% |
| ផ្ទះឈើដំបូលក្បឿង | 74 | 5.6% |
| ជម្រកសង់ពីកូនឈើ ប្រក់ដំបូលស្បូវ ឬ ក្រណាត់សំពត់តង់ | 107 | 8.1% |
| ជម្រកបណ្ដោះអាសន្នប្រក់តង់កៅស៊ូ | 25 | 1.9% |
| ផ្សេងៗ | 65 | 4.9% |
| **សរុបចម្លើយ** | 1,325 | 100% |

(ប្រភព៖ ការសម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

### 5.1.4 ទំហំគ្រួសារ

គ្រួសារអ្នកក្រីក្រនៅរាជធានី តែងតែមានសមាជិកក្នុងគ្រួសារច្រើនជាងគ្រួសារដទៃរស់នៅក្នុងរាជធានីភ្នំពេញ។ រូបទី ១ ប្រៀបធៀបទំហំគ្រួសារនៃសហគមន៍អ្នកក្រីក្រនៅរាជធានី ជាមួយនិងលទ្ធផលជម្រឿន (ពណ៌ក្រហម) ឆ្នាំ ២០០៨ (ពណ៌បៃតង) និង CRUMP[3]។ មធ្យមភាគទូទៅនៃប្រជាពលរដ្ឋតាមគ្រួសារដូចបានបង្ហាញក្នុងរូបភាពតួលេខទី១ នៅក្នុងគ្រួសារមួយដែលមានសមាជិកចំនួន ៥,៦៨ នាក់ គឺមានន័យថា គ្រួសារក្រីក្រក្នុងរាជធានី ត្រូវចិញ្ចឹមមនុស្សម្នាក់បន្ថែមទៀត ដែលលើសពីស្តង់ដារ "ជម្រឿនគ្រួសារក្នុងរាជធានីភ្នំពេញ" និងគ្រួសារមួយត្រូវចិញ្ចឹមមនុស្ស ២ នាក់បន្ថែមទៀត បើប្រៀបធៀបទៅនិងកអង្កេតគម្រោង CRUMP។

នៅក្នុងគ្រួសារតូចមួយដែលមានសមាជិកពីម្នាក់ទៅបួននាក់ គឺសមាមាត្រនៃអ្នកក្រីក្រក្នុងរាជានី មានចំនួនតិចជាង បើប្រៀបធៀបជាមួយនិងទិន្នន័យជម្រឿន និង ក្រុមសំណាកគំរូរបស់ CRUMP។ គ្រួសារដែលមានសមាជិកពីម្នាក់រហូតដល់ ៣ នាក់ ដែលអង្កេត CRUMP



គ្រួសារកំពុងបរិភោគអាហារថ្ងៃត្រង់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ

[3] របាយការណ៍គម្រោង CRUMP ទំព័រលេខ ២៦

តែងតែយកធ្វើជាសំណាកគំរូ និងមធ្យមភាគរបស់រាជធានីភ្នំពេញនោះ គឺមានចំនួនតិចជាង ២០% ក្នុងចំណោមអ្នកក្រីក្រនៅរាជធានី។ បើចាប់រាប់ពីគ្រួសារដែលមានសមាជិក ៥ នាក់ គឺយើងឃើញថា មានចំណុចជារបត់ ហើយសមាមាត្រនៃគ្រួសារអ្នកក្រីក្ររស់នៅរាជធានីដែលមានសមាជិកច្រើន គឺអាចមានចំនួនលើសពីគ្រួសារដទៃ។ មានគ្រួសារអ្នកក្រីក្រនៅរាជធានីចំនួនជាង ៤៥% មានសមាជិកចាប់ពី ៦ នាក់ឡើងក្នុងមួយគ្រួសារ។

រូបភាពតួលេខទី 1 : ទំហំគ្រួសារអ្នកក្រីក្រក្នុងរាជធានី ធៀបជាមួយជម្រឿន និង គម្រោង CRUMP




(ប្រភព : ភាគរយនៃការធ្វើសម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ ពាក់ព័ន្ធ ជាមួយនិងការវាយតម្លៃអ្នកក្រីក្រក្នុងរាជធានី)

### 5.1.5 សមាមាត្រនៃស្ថានភាពរបស់កុមារ និង យេនឌ័រ

កុមារមានចំនួនដល់ទៅ ៣៥% ក្នុងចំណោមប្រជាពលរដ្ឋសរុប (រូបភាពទី ៤)។ លទ្ធផលនេះគឺវាដូចគ្នានឹងជម្រឿនឆ្នាំ ២០០៨ ដែលមានសមាមាត្រកុមារ ៣៣,៧% មានអាយុក្រោម ១៤ ឆ្នាំ និង មាន ៦២% ជាអ្នកមានអាយុ ១៥-៦៤ ឆ្នាំ និងមាន ៤,៣% ជាជនចាស់ជរា[៤]។ ដូចគ្នានឹងការរកឃើញនូវទំហំគ្រួសារដែលបានរៀបរាប់ខាងលើដែរ គឺចំនួនកុមារជាមធ្យមនៅតាមគ្រួសារអ្នកក្រីក្រក្នុងរាជធានី មានកម្រិតខ្ពស់ជាងមធ្យមភាគរបស់រាជធានីភ្នំពេញ។ ខណៈដែលចំនួនកុមារជាមធ្យមមាន ១,៩៦ នាក់ នៅតាមគ្រួសារក្នុងសហគមន៍អ្នកក្រីក្រ

[៤] ជម្រឿនប្រជាពលរដ្ឋទូទៅឆ្នាំ ២០០៨

ក្នុងរាជធានី គឺមានត្រឹមតែ ១,៥ នាក់ប៉ុណ្ណោះ ក្នុងចំណោមប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ[៥] និងមានកុមារចំនួនប្រហែល ម្នាក់ប៉ុណ្ណោះ ក្នុងចំណោមអ្នកធ្វើចំណាកស្រុក ដែលយកមកធ្វើជាសំណាកគំរូ សម្រាប់អង្កេតគម្រោង CRUMP[៦]។ រូបទី ២ បង្ហាញថា ចំនួនពាក់កណ្តាលនៃក្រុមអ្នកដែលត្រូវបានយកមកធ្វើជាចំណាកគំរូសម្រាប់អង្កេតចន្លោះជម្រឿន (CIS) និងគម្រោង CRUMP គឺមិនមានកុមារទេ ខណៈដែលគ្រួសារអ្នកក្រីក្រក្នុងរាជធានីចំនួន ៥៧% មានកុមារ ឬ កូនចំនួន ២ នាក់ ឬច្រើនជាងនេះ។

**រូបភាពតួលេខទី 2 : ចំនួនកុមារធៀបជាមួយជម្រឿន និងគម្រោង CRUMP**




(ប្រភព : សម្ភាសន៍ផ្ទាល់ជាមួយក្រុមគ្រួសាររបាយការណ៍ CRUMP ជម្រឿនឆ្នាំ ២០០៨) ក្នុងចំណោមគ្រួសារចំនួន ២.០៣៣ គ្រួសារ ដែលបានសម្ភាសន៍ ឃើញថា ក្នុងអត្រាផលធៀបចំពោះភេទ គឺមាន ៥២% ជាស្ត្រី និង ៤៨% ជាបុរស ដែលឆ្លុះបញ្ចាំងលទ្ធផលជម្រឿនឆ្នាំ ២០០៨ ដូចគ្នាពិតសម្រាប់តំបន់អ្នកក្រីក្រក្នុងរាជធានី ដែលបង្ហាញថា ការធ្វើអង្កេតនេះវាបានគ្របដណ្តប់ក្រុមគំរូ ដែលអាចយកជាការបាន។

**តារាងទី 5 : ចំនួនប្រជាពលរដ្ឋបែងចែកតាមយេនឌ័រ និង សមាមាត្រកុមារ**

| ឈ្មោះខណ្ឌ | ចំនួនគ្រួសារ | សមាជិកក្នុងគ្រួសារ | | | ចំនួនកុមារអាយុក្រោម ១៨ ឆ្នាំ |
|---|---|---|---|---|---|
| | | សមាជិកសរុបក្នុងគ្រួសារ | ស្ត្រី | បុរស | |
| ចំការមន | 112 | 705 | 358 | 347 | 188 |
| ដូនពេញ | 125 | 656 | 341 | 315 | 182 |

[៥] អង្កេតចន្លោះជម្រឿន

[៦] របាយការណ៍គម្រោង CRUMP ទំព័រលេខ ២១

| | | | | | |
|---|---|---|---|---|---|
| ប្រាំពីរមករា | 30 | 172 | 92 | 80 | 38 |
| ទួលគោក | 172 | 991 | 518 | 473 | 337 |
| ដង្កោ | 138 | 782 | 405 | 377 | 254 |
| មានជ័យ | 421 | 2,495 | 1,293 | 1,202 | 924 |
| ឫស្សីកែវ | 398 | 2,194 | 1,181 | 1,013 | 760 |
| សែនសុខ | 199 | 1,074 | 560 | 514 | 390 |
| ពោធិ៍សែនជ័យ | 438 | 2,486 | 1,311 | 1,175 | 921 |
| **សរុប** | **2,033** | **11,555** | **6,059** | **5,496** | **3,994** |

(ប្រភព៖ ការសម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

**រូបភាពតួលេខទី 3 : ភាគរយស្ត្រី និង បុរស**




**រូបភាពតួលេខទី 4 : សមាមាត្រកុមារ**




(ប្រភព: **ទិន្នន័យពីការសម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ សរុប** N=11,555)

### 5.1.6 មេគ្រួសារ

ជិត ៦០% នៃមេគ្រួសារនៅសហគមន៍អ្នកក្រីក្រក្នុងរាជធានីគឺជាបុរស។ ទោះជាយ៉ាងនេះក្តី នៅសហគមន៍អ្នកក្រីក្រក្នុងរាជធានី បើគិតជាមធ្យមភាគ គឺមានមេគ្រួសារជាស្ត្រីច្រើនជាងគ្រួសារ នៅទូទាំងប្រទេស។ ទិន្នន័យជម្រឿនឆ្នាំ ២០០៨ បានបង្ហាញថា ក្នុងចំណោមគ្រួសារប្រជាពលរដ្ឋកម្ពុជា គឺមាន ២៥,៦% ដែលមានស្ត្រីជាមេគ្រួសារ រីឯសមាមាត្រស្ត្រីជាមេគ្រួសារនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានីវិញគឺមានចំនួន ៣៨,៣% ដែលក្នុងចំណោមនេះគឺមាន ២៧,០% ជាស្ត្រីមានកូនគ្មានស្វាមី ឬស្ត្រីមេម៉ាយ។ មានគ្រួសារចំនួនតិចតួចប៉ុណ្ណោះដែលមានមនុស្សចាស់ជរា ឬ កុមារជាមេគ្រួសារ។

តារាងទី 6 : មេគ្រួសារតាមផ្ទះ នៅសហគមន៍អ្នកក្រីក្រក្នុងរាជធានី

| មេគ្រួសារ | ចំនួនគ្រួសារ | ភាគរយនៃគ្រួសារ |
|---|---|---|
| បុរស/ប្តី | 1,206 | 59.3% |
| ស្ត្រីមានកូនគ្មានស្វាមី | 548 | 27.0% |
| ស្ត្រី/ពន្ទប្រ | 228 | 11.2% |
| កុមារ | 3 | 0.1% |
| ជីដូនជីតា | 28 | 1.4% |
| ផ្សេងៗ | 20 | 1.0% |
| សរុប | 2,033 | 100% |

(ប្រភព៖ ការសម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

### 5.1.7 ប្រជាពលរដ្ឋងាយរងគ្រោះ ក្នុងចំណោមអ្នកក្រីក្រក្នុងរាជធានី

អង្កេតបានធ្វើការប៉ាន់ប្រមាណទៅលើប្រភេទទាំង ៣ នៃក្រុមងាយរងគ្រោះ ក្នុង ១ គ្រួសារ ៖ កុមារកំព្រា ឬ កុមារត្រូវគេបោះបង់ចោល ក្នុងគ្រួសារ កុមារពិការ និង សមាជិកគ្រួសារ ដែលមានជម្ងឺឈឺរ៉ាំរ៉ៃ។ រូបទី ៥ បង្ហាញថា មាន ១ គ្រួសារ ក្នុងចំណោម ៦ គ្រួសារ យ៉ាងហោចណាស់ក៏មានសមាជិកម្នាក់ដែរ ជាអ្នកងាយរងគ្រោះ និង ១ ភាគ ៤ នៃគ្រួសារទាំងនោះ បាននិយាយថា មានសមាជិកម្នាក់ជាអ្នកឈឺរ៉ាំរ៉ៃ។ នេះគឺជាចំនួនមួយខ្ពស់ និង បង្កជាបន្ទុកបន្ថែមដល់គ្រួសារដែលត្រូវថៃទាំ។ ការព្យាបាលអ្នកមានជម្ងឺរ៉ាំរ៉ៃ និង ថៃទាំអ្នកពិការ គឺត្រូវពាក់ព័ន្ធនឹងការចំណាយដូចជា ៖ ទៅលើថ្នាំ និង ការជួយស្តារសម្បទាឡើងវិញ។ ជំពូក ៥.២ បង្ហាញថា ល័ក្ខខ័ណ្ឌសេដ្ឋកិច្ច ឬ ជីវភាពរស់នៅរបស់គ្រួសារអ្នកក្រីក្រជាច្រើននៅក្នុងរាជធានី មានលក្ខណៈទន់ខ្សោយខ្លាំង ដូច្នេះ មនុស្សច្រើននាក់ដែលត្រូវការការថៃទាំបន្ថែម និង ដែលអាចជួយដល់ការរកចំណូលក្នុងកម្រិតមួយណានោះ ត្រូវគេមើលឃើញថា ជាបញ្ហាប្រឈមដ៏ធំសម្រាប់ក្រុមគ្រួសារដែលមានផលប៉ះពាល់។

**រូបភាពតួលេខទី 5 : សមាមាត្រគ្រួសារដែលមានសមាជិកក្នុងគ្រួសារមកពីក្រុមងាយរងគ្រោះ**




(ប្រភព : សម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ)

## 5.2 ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច

ល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច គឺជាសូចនាករសំខាន់សម្រាប់វាយតម្លៃស្ថានភាពអភិវឌ្ឍន៍សង្គម។ លទ្ធផលការវាយតម្លៃបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច នៅមានកម្រិតទាបតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី ដែលបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសគឺក្រុមអ្នកដែលងាយរងគ្រោះ។ គ្រួសារភាគច្រើនមានការខ្វះខាតធនធាន សម្រាប់ឆ្លើយតបនឹងតម្រូវការសង្គម ដូចជាការថែទាំសុខភាព ឬ ការផ្តល់ការអប់រំដល់កូនៗ។

### 5.2.1 មុខរបរ និង ប្រភពចំណូល

គ្រួសារអ្នកក្រីក្រភាគច្រើនរស់នៅក្នុងរាជធានី មានប្រភពចំណូលចម្រុះ ដែលទទួលបានមកពីសមាជិកចំនួន ២ នាក់ក្នុងគ្រួសារ ជាអ្នកធ្វើការជួយដល់គ្រួសារ។ ក្នុង ១ គ្រួសារ ចំនួនស្ត្រីជាមធ្យម ដែលធ្វើការ គឺមានច្រើនជាងចំនួនបុរស ដែលប្រហែលជាបណ្តាលមកពីមានសមាមាត្រស្ត្រីខ្ពស់ជាងបុរស នៅក្នុងចំណោមប្រជាពលរដ្ឋសរុបទូទៅ។

យោងតាមអង្កេតគម្រោង CRUMP គឺគេបានសំដៅលើមុខរបរជាក់លាក់តាមយេនឌ័រ[7]។ ឧទាហរណ៍ដូចជាបុរសធ្វើការច្រើនផ្នែកសំណង់ ខណៈដែលស្ត្រីធ្វើការច្រើនផ្នែកឧស្សាហកម្មផលិតកម្ម ឬស្ត្រីភាគច្រើនជាអ្នកលក់ដូរនៅតាមសហគមន៍ ខណៈដែលបុរសធ្វើជាអ្នករត់រ៉ឺម៉ក ម៉ូតូឌុប ឬរត់ស៊ីក្លូ។ ការសិក្សាអង្កេតនៅសហ-

[7] របាយការណ៍គម្រោង CRUMP ទំព័រលេខ ៣០

គមន៍ក្រីក្រក្នុងរាជធានី បានរកឃើញប្រភពចំណូលសំខាន់ៗចំនួន ៣ មាន៖ ជាកម្មករ/កម្មការិនីរោងចក្រ សំណង់ លក់ដូរបន្តិចបន្តួចនៅក្នុងសហគមន៍ និង ជាអ្នករត់រ៉ឺម៉ក ម៉ូតូឌុប ឬ រត់ស៊ីក្លូ។ ប្រភពចំណូលទាំង ៣ នេះ សុទ្ធតែជាប្រភពដែលរកចំណូលបានតិច ប្រើពលកម្មគ្មានជំនាញ ឬ ជាការងារបម្រើសេវាដែលអ្នកមានកម្រិតអប់រំកម្រិតណាក៏អាចធ្វើបាន។ ការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី បានសង្កេតឃើញថា ប្រជាពលរដ្ឋភាគច្រើននៅតាមសហគមន៍ក្រីក្រក្នុងរាជធានី សុទ្ធសឹងតែជាអ្នកមានកម្រិតអប់រំទាប។ (ប៉ុន្តែការសិក្សាអង្កេតនេះ ពុំបានវាយតម្លៃទៅលើកម្រិតអប់រំឡើយ)។


បុរសៗកំពុងធ្វើការងារផ្នែកសិប្បកម្ម



ជាអ្នកលក់ដូរនៅក្នុងសហគមន៍



និង នៅខាងស្តាំដៃគឺជាអ្នករត់រ៉ឺម៉ក ម៉ូតូឌុប និង អ្នកប្រមូលសម្រាម

**តារាងទី 7 : មុខរបរ ឬ ប្រភពសំខាន់ៗនៃចំណូលរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍**

| ប្រភេទការងារ | ចម្លើយ<br>N | <br>ភាគរយនៃអ្នកឆ្លើយ (N=2744) | ភាគរយនៃករណី/គ្រួសារ (N=1971) |
|---|---|---|---|
| រោងចក្រ/កម្មករសំណង់ | 860 | 31.3% | 43.6% |
| អ្នកលក់ដូរក្នុងសហគមន៍ | 547 | 19.9% | 27.8% |
| អ្នករត់ម៉ូតូឌុប | 445 | 16.2% | 22.6% |
| និយោជិកក្នុងវិស័យឯកជន/សាធារណៈ | 285 | 10.4% | 14.5% |
| អ្នកប្រមូលសម្រាម | 143 | 5.2% | 7.3% |
| អ្នកផ្តល់សេវា និង ពលកម្ម | 119 | 4.3% | 6.0% |
| សិប្បកម្មជាលក្ខណៈគ្រួសារ | 61 | 2.2% | 3.1% |

| | | | |
|---|---|---|---|
| អ្នកផ្តល់សេវាកំសាន្តសប្បាយ | 52 | 1.9% | 2.6% |
| អ្នកធ្វើកសិកម្ម | 38 | 1.4% | 1.9% |
| ផ្សេងៗ | 194 | 7.1% | 9.8% |

(ប្រភព : សម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ N =1971)

ក្នុងចំណោមក្រុមគ្រួសារទាំងអស់ គឺមានត្រឹមតែ ១៤,៥% ប៉ុណ្ណោះ ដែលបានប្រាប់ថា មានសមាជិកក្នុងគ្រួសារចេញទៅធ្វើការនៅតាមវិស័យឯកជន/សាធារណៈ ក្នុងនាមជាមន្ត្រីរាជការ ឬ ធ្វើការងារនៅតាមក្រុមហ៊ុននានា។ ការងារទាំងនេះភាគច្រើន តម្រូវឲ្យអ្នកដាក់ពាក្យសុំធ្វើការ បានរៀនចប់កម្រិតមធ្យមសិក្សាបឋមភូមិ យ៉ាងតិច។

កម្មកររោងចក្រ/សំណង់ និង និយោជិកតាមវិស័យសាធារណៈ/ឯកជន អាចធានាបានប្រាក់បៀវត្សរ៍ទៀងទាត់ប្រចាំខែ ខណៈដែលអ្នកផ្សេងទៀតត្រូវពឹងផ្អែកលើមុខរបរប្រចាំថ្ងៃដែលគេអាចរកបានមិនទៀងទាត់។ ឧទាហរណ៍ដូចជា នៅថ្ងៃមានភ្លៀង ហើយមិនសូវមានអ្នកធ្វើដំណើរច្រើន គឺអ្នកមានមុខរបរបើកបរអាចរកចំណូលបានតិចជាងថ្ងៃធម្មតា។

ឱកាសរកចំណូលបានគួរឲ្យចាប់អារម្មណ៍មួយទៀត សម្រាប់សហគមន៍អ្នកក្រីក្រនៅរាជធានីគឺផលិតកម្មសិប្បកម្ម ដែលជាការផលិតសម្ភារៈផ្សេងៗនៅតាមផ្ទះ ប៉ុន្តែការវាយតម្លៃនេះបង្ហាញថា ក្នុងចំណោមក្រុមគ្រួសារទាំងអស់ដែលបានធ្វើសម្ភាសន៍ គឺមានត្រឹមតែ ៣% ប៉ុណ្ណោះ ដែលបានចូលប្រឡូកក្នុងការងារប្រភេទនេះ។ ដូច្នេះឃើញថា មានគំរូល្អៗខ្លះដែរនៅក្នុងសហគមន៍។ ស្ត្រីម្នាក់បានចាប់ផ្តើមដេរខ្នើយ និង ភួយមានលក្ខណៈជាមុខរបរខ្នាតតូច ប៉ុន្តែមានអតិថិជនកើនឡើង ដែលធ្វើឱ្យស្ត្រីរូបនេះអាចផ្តល់ការងារដល់អ្នកដទៃនៅជិតខាងបានធ្វើ ជួយការងារផលិតរបស់គាត់។



មុខរបរផលិតកម្មរបស់គាត់មានទំហំធំល្មម និង អាចផ្តល់ការងារឱ្យអ្នកជិតខាងជួយធ្វើបាន

យោងតាមការិយាល័យអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានី បានឱ្យដឹងថា មានការលំបាករកទីផ្សារសមស្របជូនសហគ្រិនតាមក្រុមគ្រួសារ សម្រាប់លក់ទំនិញ និងបណ្តុះបណ្តាលពួកគាត់ឱ្យផលិត ទំនិញ មានគុណភាពដើម្បីអាចប្រកួតប្រជែងបាននៅតាមទីផ្សារ។ ខណៈដែលទស្សនៈវិស័យរយៈពេលមធ្យម កំពុងមានច្រើនឡើងដូចនេះផលិតកម្មតាមផ្ទះ ក៏មានសក្តានុពលច្រើនដែរសម្រាប់រកចំណូល។

### 5.2.2 ចំណូលគ្រួសារ

គ្រួសារក្រីក្រនៅរាជធានី មានចំណូលទាបណាស់ ក្នុងនោះគឺមានគ្រួសារចំនួន ៦០% រកចំណូលបានតិចជាង ៧៥ ដុល្លារអាមេរិក ក្នុង ១ ខែ។ គ្រួសារដែលជាមធ្យមមានសមាជិកលើសពី ៥ នាក់ គឺធនធានដែលត្រូវការសម្រាប់មនុស្សម្នាក់ក្នុងគ្រួសារនោះ ត្រឹមតែ ១៥ ដុល្លារប៉ុណ្ណោះ ក្នុង ១ ខែ ឬ ០,៥០ ដុល្លារ ក្នុងមួយថ្ងៃ។ របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១០ បានកំណត់បន្ទាត់ភាពក្រីក្រជាចំណូលសម្រាប់មនុស្សម្នាក់ដែលអាចហូបអាហារមាន ២.១០០ កាល់ឡូរីយ៉ាងតិច ក្នុង ១ ថ្ងៃ រួមផ្សំនិងការចំណាយបន្តិចបន្តួចថែមទៀត សម្រាប់ទិញ/ជួលរបស់របរដែលមិនមែនជាអាហារដូចជា ជម្រក និងសម្លៀកបំពាក់ជាដើម។ បន្ទាត់ភាពក្រីក្រថ្នាក់ជាតិឆ្នាំ ២០០៧ បានកំណត់ត្រឹម ២,៤៧០ រៀល ក្នុងម្នាក់ក្នុង ១ ថ្ងៃ ឬ ប្រហែលជាស្មើនឹង ០,៦ ដុល្លារអាមេរិក[៨]។

ដោយពិចារណាលើតម្លៃបច្ចុប្បន្នសម្រាប់បំពេញតម្រូវការចាំបាច់ៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងអាចសន្និដ្ឋានបានថា គ្រួសារភាគច្រើនកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ និង មិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់សម្រាប់ចំណាយប្រចាំថ្ងៃ ដែលហួសពីលទ្ធភាព។ ប្រជាពលរដ្ឋភាគច្រើន ពិតជាមានការលំបាកនឹងទទួលបានសេវាសាធារណៈ ឬ សេវាវិនិយោគ សម្រាប់កែលម្អលក្ខខណ្ឌជីវភាពរស់នៅរបស់ខ្លួន។

**រូបភាពតួលេខទី 6 : កម្រិតចំណូលរបស់គ្រួសារ**




(ប្រភព: សម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ)

[៨] CSES (អង្កេតសង្គមកិច្ច សេដ្ឋកិច្ចកម្ពុជា) ការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋឆ្នាំ ២០០៧

### 5.2.3 ទ្រព្យសម្បត្តិគ្រួសារ

ក្នុងចំណោមក្រុមគ្រួសារទាំងអស់ ដែលបានធ្វើសម្ភាសន៍ គឺមានគ្រួសារចំនួនជាង ៦០% ដែលមានម៉ូតូមួយគ្រឿងក្នុងមួយគ្រួសារ ដែលគេអាចប្រើប្រាស់វាបានជាមធ្យោបាយដឹកជញ្ជូនផង និង ជាទ្រព្យសម្បត្តិផងដែរ។ យានជំនិះទីពីរដែលសំខាន់ដែរនោះគឺ "កង់" ឬ ទោចក្រយាន។ ចំណែកឯរ៉ឺម៉កវិញគឺមាន ៤,៤% និង មានរថយន្តតែមួយគ្រឿងគត់ (០,៤%) ក្នុងចំណោមក្រុមគ្រួសារដែលបានធ្វើសម្ភាសន៍។ បែបនេះគឺវាមានភាពខុសគ្នាខ្លាំងណាស់ បើប្រៀបធៀបជាមួយចំនួនមធ្យមភាគនៃប្រជាពលរដ្ឋរាជធានីភ្នំពេញ ដែលក្នុងនោះគឺ ២០,៧% មានរថយន្ត[9]។ ក្នុងចំណោមអ្នកក្រីក្រនៅរាជធានី គឺមានក្រុមគ្រួសារជិតដល់ ១ ភាគ ៥ ដែលមិនមានមធ្យោបាយធ្វើដំណើរ។

**តារាងទី 8 : មធ្យោបាយធ្វើដំណើរ**

| ប្រភេទយានយន្ត | ចម្លើយ N | ចម្លើយ ភាគរយនៃអ្នកឆ្លើយ (N=2203) | ភាគរយនៃករណី/គ្រួសារ (N=1836) |
|---|---|---|---|
| ម៉ូតូ | 1140 | 51.7% | 62.1% |
| កង់ | 610 | 27.7% | 33.2% |
| រ៉ឺម៉ក ម៉ូតូកង់បី | 80 | 3.6% | 4.4% |
| រថយន្ត | 19 | 0.9% | 1.0% |
| ស៊ីក្លូ | 347 | 15.8% | 18.9% |
| មិនមានយានយន្ត | 347 | 15.8% | 18.9% |

(ប្រភព៖ សម្ភាសន៍តាមគ្រួសារដោយមានចម្លើយចម្រុះ)

ទោះជាមានការលំបាកផ្នែកសេដ្ឋកិច្ចក៏ដោយ ក៏មានមនុស្សភាគច្រើនមានធនធានជាឧបករណ៍សម្រាប់ធ្វើការប្រាស្រ័យទំនាក់នងគ្នាដែរ នៅក្នុងចំណោមសហគមន៍អ្នកក្រីក្រនៅរាជធានី ដែលក្នុងនោះគឺក្នុងចំណោមគ្រួសារ

[9] អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០០៩ របាយការណ៍គម្រោង CRUMP ទំព័រលេខ ៣៤

ទាំងអស់មានលើសពី ៨០% ដែលមានទូរស័ព្ទចល័តប្រើប្រាស់។ ដូចនៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដូច្នោះដែរគឺ ទូរស័ព្ទចល័តបានក្លាយជាទ្រព្យដ៏មានសារៈសំខាន់មួយសម្រាប់ធ្វើការប្រាស្រ័យទាក់ទងគ្នា ផ្ទៃកមុខជំនួញ និង រក្សាទំនាក់ទំនងដឹងឮពីគ្នាទៅវិញទៅមកជាមួយ និងក្នុងចំណោមសមាជិកគ្រួសារ។ ទូរទស្សន៍មានចំនួនច្រើនជាងវិទ្យុ ដែលក្នុងចំណោមក្រុមគ្រួសារទាំងអស់នោះគឺមាន ៣ ភាគ ៤ ដែលមានទូរទស្សន៍ និង ក្នុងចំណោម ៥ គ្រួសារ គឺមានតិចជាងមួយគ្រួសារដែលមានវិទ្យុ។

**តារាងទី ១ : មធ្យោបាយជាឧបករណ៍សម្រាប់ធ្វើការប្រាស្រ័យទំនាក់ទំនង/ផ្តល់ព័ត៌មាន**

| មធ្យោបាយសម្រាប់ធ្វើការប្រាស្រ័យ ទំនាក់ទំនង/ផ្តល់ព័ត៌មាន | ចម្លើយ | | ភាគរយនៃករណី/គ្រួសារ (N=1798) |
|---|---|---|---|
| | N | ភាគរយនៃអ្នកឆ្លើយ (N=3217) | |
| ទូរស័ព្ទចល័ត | 1,467 | 45.6% | 81.6% |
| ទូរទស្សន៍ | 1,369 | 42.6% | 76.1% |
| វិទ្យុ | 320 | 9.9% | 17.8% |
| ផ្សេងៗ | 61 | 1.9% | 3.4% |

(យគ្រួសារផ្ទាល់ប្រភព៖ សម្ភាសន៍ជាមួ)

### 5.2.4 ស្ថានភាពបំណុល

ក្នុងចំណោមក្រុមគ្រួសារដែលបានធ្វើសម្ភាសន៍ គឺមាន ៨៣% កំពុងជំពាក់បំណុលគេ។ មូលហេតុដែលនាំឱ្យជំពាក់បំណុលគេគឺ មានអ្នកឆ្លើយសំណួរចំនួនជាងពាក់កណ្តាលនាក់ប្រាប់ថា គាត់បានខ្ចីបំណុលគេជាប្រភេទ "ឥណទាន" សម្រាប់យកមកប្រកបមុខរបរបង្កើនចំណូល។ ទោះជាយ៉ាងនេះក្តី ក៏មានគ្រួសារចំនួនយ៉ាងច្រើនដែរ ដែលបានឲ្យគេខ្ចីប្រាក់ យកទៅបង់ថ្លៃសេវាព្យាបាលជម្ងឺ និង សេវាសម្រាលកូនផងដែរ។ មានមនុស្សជិត ១ ភាគ ៣ គ្រួសារ បានខ្ចីប្រាក់ពីគេយកមកទិញស្បៀងអាហារ ដែលគាត់ត្រូវការជាចាំបាច់។ ក្នុងចំណោម ១០ គ្រួសារ គឺមាន ១ គ្រួសារ ជំពាក់បំណុលគេ ដោយសារត្រូវយកទៅចាយវាយសម្រាប់ការអប់រំរៀនសូត្ររបស់កូនគាត់។

ឬសគល់នៃបញ្ហាជាប់ជំពាក់បំណុលគេ គឺបណ្តាលមកពីមានចំណូលតិច ក្នុងគ្រួសារអ្នកក្រីក្រនៅរាជធានី។ ដូចបានរៀបរាប់ខាងលើរួចមកហើយគឺ មុខរបរមានជំនាញតិច និង ទទួលបានប្រាក់កម្រៃទាប វាពុំអាចរកចំណូលបានគ្រប់គ្រាន់ សម្រាប់សន្សំយកទៅធ្វើវិនិយោគ ឬ ចំណាយលើការចិញ្ចឹមជីវភាពបាននោះឡើយ។

**តារាងទី 10 : មូលហេតុដែលនាំឲ្យគ្រួសារខ្ចីប្រាក់ពីគេ**

| | N | ចម្លើយ ភាគរយនៃអ្នកឆ្លើយ (N=2571) | ភាគរយនៃករណី/គ្រួសារ (N=1593) |
|---|---|---|---|
| ចាប់ផ្តើមប្រកបមុខជំនួញ | 863 | 33.6% | 54.2% |
| សេវាព្យាបាលពីពេទ្យ | 724 | 28.2% | 45.4% |
| ទិញស្បៀងអាហារបន្ទាន់ | 464 | 18.0% | 29.1% |
| ការអប់រំរៀនសូត្ររបស់កូន | 215 | 8.4% | 13.5% |
| សង់ផ្ទះដែលខូចខាតដោយគ្រោះមហន្តរាយ | 164 | 6.4% | 10.3% |
| សេវាសម្រាលកូន | 86 | 3.3% | 5.4% |
| ផ្សេងៗ | 55 | 2.1% | 3.5% |

(ប្រភព៖ សម្ភាសន៍គ្រួសារផ្ទាល់)

## 5.3 សមត្ថភាពសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់

ជំពូកនេះផ្តល់ទស្សនៈទូទៅអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូរផ្សេងទៀត ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី ដោយផ្តោតលើផ្លូវ ថាមពលអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ក៏ដូចជាការទុកដាក់ចោលសម្រាមផងដែរ។ សហគមន៍អ្នកក្រីក្រក្នុងរាជធានី និង កន្លែងតាំងទីលំនៅបណ្តោះអាសន្នជាច្រើន បានទទួលការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធដូចជា អនាម័យ រស់នៅស្អាត និង បរិស្ថានមានសុវត្ថិភាព ជាលក្ខណៈកុមារមេត្រី។ ផ្លូវនៅក្នុងរូបភាពនេះ គឺជាផ្លូវដូចគ្នានិងផ្លូវនៅក្នុងឃុំគោកឃ្លាំង ២ នៅមុនពេល និងក្រោយពេលមានការអភិវឌ្ឍ។

សូមកត់សម្គាល់ថា ព័ត៌មានដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ គឺត្រូវបានប្រមូលក្នុងពេលចុះជួបសម្ភាសន៍តំណាងសហគមន៍។



ការកែលម្អដែលមើលឃើញ : ផ្លូវមួយខ្សែនៅសហគមន៍គោកឃ្លាំងទី ២/ខណ្ឌសែនសុខ មុន និង ក្រោយការអភិវឌ្ឍ។

### 5.3.1 ទឹកស្អាត និងអនាម័យ

ក្នុងចំណោមសហគមន៍ចំនួន ៦ គឺមានសហគមន៍ចំនួន ៥ បានទទួលការផ្គត់ផ្គង់ទឹកស្អាត ដែលក្នុងនោះគឺមាន ៩៦% ត្រូវបានផ្គត់ផ្គង់ដោយរាជរដ្ឋាភិបាល តាមរយៈអាជ្ញាធរ (រដ្ឋាករ) ទឹករាជធានីភ្នំពេញ។ មានសហគមន៍ចំនួន ៤១ ទៀត ដែលមិនទាន់មានទឹកស្អាតប្រើប្រាស់នៅឡើយ ហើយទឹកដែលពួកគេមានសម្រាប់ប្រើប្រាស់នោះគឺបានមកពីព្រែកព ៖ ទឹកទន្លេ បឹង ទឹកភ្លៀង/អណ្តូង និង មានតែ ២ ករណីប៉ុណ្ណោះដែលប្រើទឹកស្រះ។ ខណ្ឌឫស្សីកែវមានសហគមន៍ច្រើនបំផុត (មាន ២៤ សហគមន៍) ដែលមិនមានទឹកស្អាតប្រើប្រាស់ និង បន្ទាប់មកទៀតគឺខណ្ឌមានជ័យ (មាន ៦ សហគមន៍) និង ខណ្ឌពោធិ៍សែនជ័យ (៥ សហគមន៍)។ ទោះជាការផ្គត់ផ្គង់ទឹកស្អាត មានអត្រាគ្របដណ្តប់ខ្ពស់រួចហើយក៏ដោយ ក៏នៅមានបញ្ហាបន្ទាន់មួយទៀតនៅឡើយដែរ ដែលបញ្ហានោះគឺជាបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី ដែលត្រូវការពង្រីកការផ្គត់ផ្គង់ទឹកស្អាតឱ្យបានច្រើនបន្ថែមទៀត ដោយសារថា នៅមានសហគមន៍ចំនួន ១៥% ទៀតនៅឡើយ ក្នុងចំណោមសហគមន៍គោលដៅ ដែលនៅមិនទាន់បានតភ្ជាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតចូលទៅដល់។

តារាងទី 11 : ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ

| | N ចម្លើយតំណាងសហគមន៍ | ភាគរយសហគមន៍ |
|---|---|---|
| មានទឹកស្អាតប្រើប្រាស់ (N=280) | 239 | 85.4% |
| មានប្រព័ន្ធលូក្នុងសហគមន៍ (N=273) | 196 | 71.6% |
| មានប្រព័ន្ធប្រមូលសម្រាមក្នុងសហគមន៍ (N=274) | 165 | 60.2% |
| មានបង្គន់អនាម័យសាធារណៈក្នុងសហគមន៍ (N=268) | 30 | 11.2% |
| យុទ្ធនាការផ្សព្វផ្សាយលើកកម្ពស់ទឹកស្អាត និង អនាម័យ (N=266) | 174 | 65.4% |

(ប្រភព ៖ សម្ភាសន៍ជាមួយតំណាងសហគមន៍)

ក្នុងចំណោមតំណាងសហគមន៍ គឺមាន ៤៨% បានលើកឡើងថាស្ថានភាពអនាម័យ និងបរិស្ថាន ជាបញ្ហាចម្បងនៅក្នុងសហគមន៍របស់ពួកគាត់។ ចម្លើយនេះ គឺវាស៊ីគ្នានិងទិន្នន័យនៅក្នុងតារាងទី ១១ ដែលបង្ហាញថា នៅមានសហគមន៍មួយចំនួនទៀតនៅឡើយ ដែលត្រូវការឱ្យមានការតភ្ជាប់ប្រព័ន្ធលូទឹកសម្អុយ និងមានការប្រមូលយកកាកសំណល់សម្រាមចេញពីសហគមន៍។



ទីជំរកដែលអាចចម្លងជម្ងឺច្រើនមុខបាន។ ខ្វះការយល់ដឹងនៅឡើយ អំពីការរស់នៅស្អាតបរិស្ថានល្អ និងអនាម័យ។

មានសហគមន៍ខ្លះមិនអាចឱ្យរថយន្តដឹកសម្រាមចូលទៅដល់បាន ដូច្នេះត្រូវរកវិធីផ្សេងទៀតដើម្បីគ្រប់គ្រងកាកសំណល់សម្រាម។

ក្រៅពីការពង្រីកហេដ្ឋារចនាសម្ព័ន្ធអនាម័យ គឺនៅមានបញ្ហាប្រឈមធំមួយទៀតនៅក្នុងសហគមន៍ គឺកង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីហានិភ័យដែលអាចកើតមានចំពោះបំពុលបរិស្ថាន។ ស្ថានភាពដូចនៅក្នុងរូបភាពនេះ គឺមាននៅគ្រប់ទីកន្លែង។ សំបកកង់រថយន្តចាស់ៗគឺជាប្រភព ការកកើតសត្វមូសដែលជាភ្នាក់ងារចម្លងជម្ងឺគ្រុនឈាម ទឹកមិនស្អាតគឺជាព្រភពសម្រាប់បាក់តេរីបង្កជាជម្ងឺរាក និងការពុកផុយរលួយនៃកាកសំណល់សម្រាម អាចបញ្ចេញសារធាតុមានគ្រោះថ្នាក់ចូលទៅក្នុងទឹក និងចំណីអាហារ។

ឧទាហរណ៍ជាក់ស្តែងដែលជារឿងពិតមួយពីសហគមន៍

*ស្ត្រីម្នាក់បានបោះសម្រាមចោលតាមប្រហោងរនាបឫស្សីទៅក្នុងទឹកក្រោមផ្ទះរបស់គាត់។ នៅពេលគេសួរថា ហេតុអ្វីបានជាគាត់បោះសម្រាមចោលដូច្នេះ គាត់ឆ្លើយថា ៖ ពេលដែលខ្ញុំបោះសម្រាមចោលក្រោមផ្ទះរបស់ខ្ញុំ កាកសំណល់នឹងគរឡើង ហើយយូរៗទៅវានឹងគោកលែងមានទឹកតទៅទៀត។ បន្ទាប់មកខ្ញុំត្រូវការដាក់ដីបន្តិចបន្តួចពីលើសម្រាមនោះដើម្បីឱ្យខ្ញុំបានរស់នៅលើដីគោក។*

តារាងទី ១១ ក៏បានបង្ហាញផងដែរថា ក្នុងចំណោមសហគមន៍ទាំងអស់ គឺមានសហគមន៍ចំនួនត្រឹមតែ ១១% ប៉ុណ្ណោះ ដែលមានបង្គន់អនាម័យសាធារណៈ។ ទោះជាយ៉ាងនេះក្តី ក្នុងចំណោមក្រុមគ្រួសារដែលបានធ្វើសម្ភាសន៍ គឺគេបានរកឃើញថា ក្នុងចំណោមក្រុមគ្រួសារទាំងអស់ មានគ្រួសារចំនួនប្រហែលជា ៨០% ប៉ុណ្ណោះ ដែលមានបង្គន់អនាម័យប្រើប្រាស់ គឺនៅសល់តែប្រហែលជា ២០% ទៀតប៉ុណ្ណោះ ជាមធ្យម ដែលត្រូវការបង្គន់សាធារណៈ។ គ្រួសារដែលមិនមានបង្គន់អនាម័យប្រើប្រាស់ទាំងនេះ ទំនងជាមនុស្សដែលមានជីវ-ភាពខ្សត់ខ្សោយក្នុងគ្រួសារ។ រូបភាពលេខ ៧ បង្ហាញថា ក្នុងចំណោមក្រុមគ្រួសារដែលមានចំណូលខ្ពស់បំផុត គឺមានលើសពី ៩០% ជាគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ក្នុងគ្រួសារ ខណៈដែលគ្រួសារក្រីក្រខ្លាំងមិនមានចំណូលសោះ មានចំនួនមួយភាគបី ពុំមានបង្គន់អនាម័យប្រើប្រាស់។ ដូច្នេះ ក្រុមមនុស្សទាំងនេះ ជាចាំបាច់គឺត្រូវតែធ្វើការកំណត់បន្ថែមទៀត ដើម្បីធ្វើផែនការមួយឱ្យអាចមានអន្តរាគមន៍ និងជំនួយ។

**រូបភាពតួលេខទី 7 : ចំនួនផ្ទះមានបង្គន់អនាម័យ ធៀបជាមួយនឹងកម្រិតចំណូល**




(ប្រភព: សម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ)

### 5.3.2 ការថែទាំសុខភាព

បញ្ហាសុខភាពគឺជាកង្វល់យ៉ាងសំខាន់របស់តំណាងសហគមន៍អ្នកក្រីក្រនៅក្នុងរាជធានី ដែលក្នុងនោះគឺមានពួកគាត់ចំនួនពាក់កណ្តាលនាក់ បាននិយាយថា មេរោគអេដស៍/ជម្ងឺអេដស៍ និង បញ្ហាកង្វះអាហាររូបត្ថម្ភ គឺជាបញ្ហាមួយរបស់សហគមន៍ពួកគាត់ និង មាន ៣២% ក៏បានលើកឡើងផងដែរថា មានកុមារកើតជម្ងឺរាក។ ដូចបានបង្ហាញនៅខាងលើស្រាប់ គឺមានគ្រួសារជាច្រើន ដែលត្រូវការខ្ចីប្រាក់ពីគេ យកទៅបង់ថ្លៃសេវាសុខភាព។ ចំណុចនេះ គឺមានន័យថា ក្រុមគ្រួសារប្រជាពលរដ្ឋទាំងនេះ ត្រូវការឱ្យមានសេវាសុខភាពជាចាំបាច់។

ការវាយតម្លៃសហគមន៍អ្នកក្រីក្រក្នុងរាជធានី បានផ្តោតលើសូចនាករសុខភាពមួយចំនួន ដែលទាក់ទងនឹង ៖ ការទទួលបានសេវាជាមូលដ្ឋាន និង សេវាថែទាំសុខភាពផ្ទៃពោះ មុនពេលសម្រាលកូន រួមមានទាំងការទទួលបានថ្នាំបង្ការ និង អាហាររូបត្ថម្ភ ផងដែរ។

#### 5.3.2.1 សេវាសុខភាពជាមូលដ្ឋាន

ក្នុងចំណោមសហគមន៍ទាំងអស់ គឺមានសហគមន៍ចំនួនប្រហែលជាពាក់កណ្តាល អាចទទួលបានសេវាពីមណ្ឌលសុខភាពនៅជិតៗសហគមន៍ ឬ មានភ្នាក់ងារផ្តល់សេវាសុខភាព អាចចុះទៅដល់ពួកគាត់បាន។ អ្វីដែលជាវិជ្ជមាននោះគឺថា សេវាវិស័យមេរោគអេដស៍ និង ជម្ងឺអេដស៍ដ៏ពិសេស បានពង្រីកខ្លួនដែលមានល្បឿនដូចគ្នានោះដែរ និងមានបម្រើសេវានៅក្នុងសហគមន៍ចំនួនជិតពាក់កណ្តាលនៃសហគមន៍ទាំងអស់នោះ។

**តារាងទី 12 : ការផ្តល់សេវាសុខាភិបាល**

| សេវាសុខភាពកំពុងមានស្រាប់ | N ចម្លើយតំណាងសហគមន៍ | ភាគរយសហគមន៍ |
|---|---|---|
| មណ្ឌលសុខភាពនៅក្បែរ (N=២៧៣) | 143 | 52.4% |
| បានបង្កើតភ្នាក់ងារគាំទ្រសុខភាពភូមិ (N=២៦៩) | 143 | 53.2% |
| សកម្មភាពពិនិត្យដល់កន្លែង ក្នុងរយៈពេល ៣ ខែមុន (N=២៦៩[10]) | 122 | 45.4% |
| សេវាសម្រាប់ប្រជាពលរដ្ឋរស់នៅជាមួយជម្ងឺអេដស៍ (N=២៦៥) | 143 | 54.0% |

(ប្រភព ៖ សម្ភាសន៍តំណាងសហគមន៍)

[10] សូមកត់សម្គាល់ថា ក្នុងរាជធានីភ្នំពេញ គឺមណ្ឌលសុខភាពមិនត្រូវមានសកម្មភាពចុះពិនិត្យជាទៀងទាត់ដល់ទីកន្លែងក្នុងសហគមន៍ទេ។ រីឯនៅជនបទវិញ គឺមន្ត្រីថែទាំសុខភាពសាធារណៈ ត្រូវចុះទៅពិនិត្យតាមភូមិក្នុង ១ ខែ ម្តង។ ពាក្យថា ការចុះពិនិត្យដល់ទីកន្លែង នៅក្នុងតារាងនេះ គឺចង់និយាយអំពីសកម្មភាពនានាដែលអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តន៍ ដោយសហការជាមួយសេវាសុខភាពសាធារណៈ។

វាមានសារៈសំខាន់ណាស់ ក្នុងការពង្រីកសេវាគ្របដណ្តប់របស់ក្រុមភ្នាក់ងារគាំទ្រសុខភាពភូមិ ដែលមានត្រឹមតែ ៥៣% ប៉ុណ្ណោះ នៅក្នុងចំណោមសហគមន៍ទាំងអស់នេះ។ ក្រុមភ្នាក់ងារគាំទ្រសុខភាពភូមិ គឺជារចនាសម្ព័ន្ធសុខភាពផ្លូវការមានលក្ខណៈវិមជ្ឈការបំផុតរបស់ក្រសួងសុខាភិបាល។ ក្រុមភ្នាក់ងារគាំទ្រសុខភាពភូមិ (មានស្ត្រីម្នាក់/បុរសម្នាក់) គឺជាមនុស្សដែលសហគមន៍បោះឆ្នោតតែងតាំង ឬ ជ្រើសតាំង ដូច្នេះ គេទុកចិត្តលើពួកគាត់ និង អាណត្តិរបស់ពួកគាត់។ ពួកគាត់មានភារកិច្ចទទួលខុសត្រូវសំខាន់ៗដូចជា ៖ អប់រំសុខភាព បញ្ជូនអ្នកជម្ងឺទៅកាន់គ្រឹស្ថានសុខភាពសាធារណៈ និងសហការជាមួយដៃគូរមកពីខាងក្រៅ។ ភ្នាក់ងារគាំទ្រសុខភាពភូមិភាគច្រើន ក៏ជាសមាជិកគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែរ ដែលកំណត់រកតម្រូវការរបស់សហគមន៍ សំណូមពរ និង បញ្ហាបន្ទាន់នានាពាក់ព័ន្ធនឹងសេវាសុខភាពសាធារណៈ។



ការផ្តល់សេវាថែទាំសុខភាពបឋម នៅមណ្ឌលសុខភាពគីឡូម៉ែត្រលេខ ៩

### 5.3.2.2 សុខភាពមាតា និងកុមារ

តារាងទី ១៣ បង្ហាញទិន្នន័យស្តីពីការទទួលបានការថែទាំសុខភាពផ្ទៃពោះមុនពេលសម្រាលកូន និងថ្នាំបង្ការ។ ១៩២ គ្រួសារដែលបានធ្វើសម្ភាសន៍ សុទ្ធតែមានសមាជិកក្នុងគ្រួសារដែលមានផ្ទៃពោះ។ ក្នុងចំណោម ១០ គ្រួសារ គឺមាន ៨ គ្រួសារ ដែលស្ត្រីមានផ្ទៃពោះទទួលសេវាថែទាំសុខភាពផ្ទៃពោះបានពេញលេញដែលមានន័យថា យ៉ាងហោចណាស់ស្ត្រីមានផ្ទៃពោះបានទៅទទួលការប្រឹក្សាចំនួន ៤ ដង ក្នុងរយៈពេលមានផ្ទៃពោះនោះ។ មានតែ ៩ គ្រួសារប៉ុណ្ណោះដែលស្ត្រីមានផ្ទៃពោះមិនបានទទួលការពិនិត្យផ្ទៃពោះមុនពេលសម្រាលកូន។

មណ្ឌលសុខភាពរដ្ឋគឺជាមណ្ឌលដែលស្ត្រីមានផ្ទៃពោះប្រើប្រាស់ ដើម្បីទទួលបានការថែទាំសុខភាពផ្ទៃពោះមុនពេលសម្រាលកូន។ ក្នុងចំណោម ១៧៥ គ្រួសារ គឺមានតែ ៥ គ្រួសារប៉ុណ្ណោះ ដែលឆ្លើយថា បានប្រើប្រាស់គ្លីនិកឯកជន និងមានពីរករណីដែលនិយាយថា បានប្រើប្រាស់សេវាឆ្មបបុរាណ។

**តារាងទី 13 : ការប្រើប្រាស់សេវាសុខាភិបាល**

| | N ចម្លើយតាមគ្រួសារ | ភាគរយគ្រួសារ |
|---|---|---|
| គ្រួសារដែលមានស្ត្រីបានទទួលការថែទាំសុខភាពផ្ទៃពោះពេញលេញមុនពេលសម្រាលកូន (N=១៩២) | 152 | 79.2% |
| គ្រួសារដែលប្រើប្រាស់សេវាមណ្ឌលសុខភាពសម្រាប់ថែទាំសុខភាពផ្ទៃពោះ មុនពេលសម្រាលកូន (N=១៧៤) | 146 | 83.9% |
| គ្រួសារដែលមានកុមារអាយុតិចជាង ១២ ខែ ទទួលបានថ្នាំបង្ការគ្រប់ចំនួន (N=៥៧៩) | 482 | 83.2% |

(ប្រភព៖ សម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

ក្នុងចំណោមគ្រួសារទាំងអស់គឺមាន ៨៣% ដែលមានកុមារអាយុក្រោម ១២ ខែ ទទួលបានថ្នាំបង្ការពេញលេញ និង មានតែ ៤% ប៉ុណ្ណោះដែលមិនបានទទួល។ លទ្ធផលនេះអាចប្រៀបធៀបគ្នាបានជាមួយនិងលទ្ធផលនៅក្នុងអង្កេតប្រជាសាស្ត្រ និង សុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១០។ យោងតាម CDHS គឺក្នុងចំណោមកុមារកម្ពុជា ដែលមានអាយុចន្លោះពី ១២ ទៅ ២៣ ខែ មានកុមារចំនួន ៧៩% បានទទួលថ្នាំបង្ការពេញលេញ និង មានតែ ៤% ប៉ុណ្ណោះ ដែលមិនបានទទួល[១១] និង ក្នុងចំណោមស្ត្រីកម្ពុជាចំនួន ១០ នាក់ គឺមានស្ត្រីចំនួន ៩ នាក់ ដែលបានទទួលសេវាពិនិត្យសុខភាពផ្ទៃពោះមុនពេលសម្រាលកូនពីអ្នកជំនាញ[១២]។

សញ្ញាអាសន្នអំពីស្ថានភាពសុខភាពកុមារគឺថា ក្នុងចំណោមគ្រួសារទាំងអស់ គឺមាន ៤៣% (N=១២១៦) គ្រួសារ បានប្រាប់ថា មានកុមារខ្វះអាហារូបត្ថម្ភនៅក្នុងគ្រួសារ។ បញ្ហាកង្វះអាហារូបត្ថម្ភចំពោះកុមារ គឺស្ថិតនៅលំដាប់ទី ៣ ក្នុងចំណោមបញ្ហាសំខាន់ៗ ដែលតំណាងសហគមន៍បានកំណត់ ដែលនៅក្នុងនោះ គឺមាន ៥០% បាននិយាយថា បញ្ហាកង្វះអាហារូបត្ថម្ភគឺជាបញ្ហារបស់ពួកខ្លួន និងមាន ៣២% ទៀត និយាយបន្ថែមថា បញ្ហាដែលកុមារមានកើតជម្ងឺរាក ក៏ជាបញ្ហាមួយដែរ។ នៅក្នុងបរិបទនេះ ប្រការសំខាន់គឺត្រូវកត់សម្គាល់ថា ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ មិនត្រូវបានសិក្សាវាយតម្លៃដោយមានការវាស់វែងបានត្រឹមត្រូវឡើយ ក្នុងពេលចុះអង្កេត។ ពាក្យថា "កុមារខ្វះអាហារូបត្ថម្ភ" គឺបានផ្អែកលើការយល់ឃើញពីអ្នកឆ្លើយតបសំណួរសម្ភាសន៍។

[១១] អង្កេតប្រជាសាស្ត្រ និង សុខភាពកម្ពុជា (CDHS) លទ្ធផលរកឃើញសំខាន់ៗ ទំព័រលេខ ១១
[១២] CDHS ឆ្នាំ ២០១០ លទ្ធផលរកឃើញសំខាន់ៗ ទំព័រលេខ ៩

ទោះជាយ៉ាងនេះក្តី ការបង្ហាញប្រាប់នេះគឺវាមានថា មាតាបិតាបានមើលឃើញភាពខុសគ្នាក្នុងការអភិវឌ្ឍចំពោះកូនរបស់ខ្លួន បើប្រៀបធៀបជាមួយនិងអ្នកដទៃ។

CDHS ឆ្នាំ ២០១០ បានរកឃើញថា មានកុមារកម្ពុជាចំនួន ៤០% ក្រិន ដែលមានន័យថា កុមារទាបធៀបនឹងអាយុ និង ដែលបង្ហាញថា កុមារមាន ជម្ងឺខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ។ បញ្ហានេះមិនសូវជាមានច្រើនទេនៅតាមទីក្រុង ដូចជានៅក្នុងរាជធានីភ្នំពេញ មាន ២៥% និង មិនមានសោះ សម្រាប់ ស្ត្រីជាម្តាយដែលមានការ អប់រំល្អ និង ជាមនុស្សក្នុង គ្រួសារ អ្នកមានទ្រព្យសម្បត្តិធូរធា។



*ម្តាយ និង កូននៅតែត្រូវការកិច្ចការពារពិសេស*

បើធ្វើការពិចារណាឲ្យបានជិតដល់លើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងស្ថានភាពអប់រំនៃគ្រួសារអ្នកក្រីក្រនៅរាជធានី ឃើញថា កូនរបស់ពួកគាត់កំពុងប្រឈមនឹងភាពងាយរងគ្រោះនៃបញ្ហាកង្វះអាហារូបត្ថម្ភ។ ត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀត ដើម្បីសិក្សាវាយតម្លៃស្ថានភាពអាហារូបត្ថម្ភរបស់កុមារនៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី។ ការផ្តល់អាហារូបត្ថម្ភបានគ្រប់គ្រាន់ តាំងពីកុមារនៅតូច គឺជាពេលសំខាន់បំផុតសម្រាប់ការលូតលាស់ និងការអភិវឌ្ឍសមស្របនៃមុខងារនានាក្នុងខ្លួនប្រាណកុមារ និងត្រូវតែចាត់ទុកថា វាជាមូលដ្ឋានគ្រឹះមួយ ដ៏សំខាន់សម្រាប់សុខភាពបុគ្គលម្នាក់ៗ ដោយឡែក និងសុខភាពសហគមន៍ជាទូទៅ។

### 5.3.3 សេវាអប់រំ

នៅក្នុងគោលដៅទី ២ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាចិត្តសម្រេចឲ្យបាននូវសកលកម្មការអប់រំបឋមសិក្សា និង បន្តដល់ការអប់រំជាមូលដ្ឋានឱ្យបាន ៩ ឆ្នាំ។ នៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី គេបានកសាងគ្រឹះរចនាសម្ព័ន្ធយ៉ាងសំខាន់ សម្រាប់រួមចំណែកវិភាគទានដល់ការសម្រេចបាន CMDG។ ប៉ុន្តែភាពក្រីក្រ នៅតែជាបញ្ហាប្រឈមដ៏សំខាន់នៅឡើយ នៅលើផ្លូវឆ្ពោះទៅសម្រេចឱ្យបានការអប់រំស្មើគ្នា។

### 5.3.3.1 ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន

សហគមន៍អ្នកក្រីក្រក្នុងរាជធានី មានចំនួនច្រើនមែនទែន (៨៨%) ដែលមានកុមារទៅរៀននៅសាលាបឋមសិក្សា មានចម្ងាយផ្លូវជិតជាង ១ គីឡូម៉ែត្រពីផ្ទះ។ នេះគឺជាសមិទ្ធផលមួយដ៏ធំធេង ដែលសម្រេចបានលើលទ្ធភាពអាចទទួលបានការអប់រំកម្រិតបឋមសិក្សា។

ក្នុងចំណោមសហគមន៍អ្នកក្រីក្រក្នុងរាជធានី គឺមានសហគមន៍ចំនួនពាក់កណ្ដាលបានបង្កើត គណៈកម្មការទ្រទ្រង់សាលារៀន (SSC)។ គណៈកម្មការទ្រទ្រង់សាលារៀន មានសមាសភាពនាយកសាលា និង សមាជិកសហគមន៍ និង មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសាលារៀន។



*ថ្នាក់បឋមសិក្សា គាំទ្រដោយសង្កាត់ស្ទឹងមានជ័យ*

តាមរយៈការប្រឹក្សាដ៏ទូលំទូលាយមួយមួយជាមួយ សហគមន៍ SSC បានធានាឲ្យមានការចូលរួម ពីសហគមន៍ក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍សាលារៀន។ គ្រប់សាលាបឋមសិក្សាទាំងអស់ត្រូវមាន SSC និងត្រូវពង្រីកថែមទៀតជាការចាំបាច់។

ក្នុងចំណោមតំណាងសហគមន៍ គឺមានតំណាងចំនួនត្រឹមតែ ៣០% ប៉ុណ្ណោះដែលបាននិយាយប្រាប់អំពីមត្តេយ្យសិក្សា ដូច្នេះត្រូវតែពង្រីកការអប់រំកុមារតូចបន្ថែមទៀត ជាការចាំបាច់សម្រាប់សហគមន៍អ្នកក្រីក្រក្នុងរាជធានី។

**តារាងទី 14 : ហេដ្ឋារចនាសម្ព័ន្ធការអប់រំមត្តេយ្យសិក្សា និងបឋមសិក្សា**

| | N ចម្លើយតំណាងសហគមន៍ | ភាគរយសហគមន៍ |
|---|---|---|
| សាលាបឋមសិក្សាដែលនៅជិត (១ គ.ម) (N=២៧៣) | 239 | 87.5% |
| បានបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន ដែលមានដំណើរការ (N=២៥៤) | 140 | 55.1% |
| បានបង្កើតមត្តេយ្យសិក្សា នៅក្នុងសហគមន៍ (N=២៦៩) | 81 | 30.1% |

(ប្រភព៖ សម្ភាសន៍ជាមួយតំណាងសហគមន៍)

### 5.3.3.2 ការទៅរៀន

ការចុះឈ្មោះចូលរៀនសាលាបឋមសិក្សារបស់គ្រួសារ ឬ សហគមន៍អ្នកក្រីក្រក្នុងរាជធានី មានលក្ខណៈល្អប្រសើរណាស់ គឺមានគ្រួសារចំនួន ៩១% ដែលមានកុមារគ្រប់អាយុចូលរៀនកម្រិតបឋមសិក្សា បានបញ្ជូនកុមារឱ្យទៅរៀន។ ប៉ុន្តែ គួរឱ្យសោកស្តាយ គឺមានអត្រាធ្លាក់ចុះវិញ ពេលដែលសិស្សឡើងថ្នាក់ទៅរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ។ មានគ្រួសារចំនួន ២៤% ដែលមានកុមារអាយុ ១២-១៤ ឆ្នាំ គឺមិនមានកុមារចូលរៀនកម្រិតមធ្យមសិក្សាទេ។ យុវវ័យដែលបានរៀនសូត្រត្រឹមកម្រិតបឋមសិក្សា មានឱកាសតិចតួចណាស់ក្នុងការរកការងារបានធ្វើ។ ការអប់រំកម្រិតមត្តេយ្យសិក្សាកំពុងមានការអភិវឌ្ឍទៅមុខ ដែលមានគ្រួសារចំនួន ៤៣% ដែលមានកុមារអាយុ ៣-៥ ឆ្នាំ បានចូលរៀនកម្រិតអប់រំសម្រាប់កុមារតូច ប៉ុន្តែនៅមានឱកាសច្រើនទៀតនៅឡើយសម្រាប់ពង្រីកបន្ថែមទៀត។

**តារាងទី15: ការទៅរៀននៅសាលា តាមកម្រិតផ្សេងៗ**

| | N ចម្លើយតាមគ្រួសារ | ភាគរយគ្រួសារ |
|---|---|---|
| គ្រួសារមានកូនអាយុ ៦-១១ ឆ្នាំ រៀននៅសាលាបឋមសិក្សា (N=៨៦៤) | 785 | 90.9% |
| គ្រួសារមានកូនអាយុ ១២-១៤ ឆ្នាំ រៀននៅមធ្យមសិក្សា (N=៨៧៥) | 627 | 71.7% |
| គ្រួសារមានកូនអាយុ ៣-៥ ឆ្នាំ រៀននៅមត្តេយ្យសិក្សា (N=៦៦៦) | 285 | 42.8% |

(ប្រភព៖ សម្ភាសន៍ជាមួយគ្រួសារផ្ទាល់)

(សូមចំណាំថា ចំនួនភាគរយនៅក្នុងនេះ គឺមិនតំណាងឱ្យចំនួនកុមារទេ ប៉ុន្តែវាតំណាងឱ្យសមាមាត្រគ្រួសារ/ខ្នងផ្ទះ។ ដូច្នេះ យើងមិនអាចផ្ទៀងផ្ទាត់ចំនួនកុមារចូលរៀនសាលា ឬ ផ្ទៀងផ្ទាត់ភេទកុមារបានឡើយ)។

### 5.3.4 កិច្ចការពារកុមារ

កុមារគឺជាអ្នកងាយរងគ្រោះបំផុតនៅក្នុងសង្គម ប៉ុន្តែ កុមារគឺជាគ្រឹះនៃការអភិវឌ្ឍនាពេលអនាគតដែលត្រូវការកិច្ចការពារ។ ការកើតមានបរិយាកាសសម្រាប់សហគមន៍អ្នកក្រីក្រក្នុងរាជធានី គឺជាបរិយាកាសដែលអាចមានគ្រោះថ្នាក់ដល់កុមារ។ យើងបានពណ៌នានៅខាងលើ រួចហើយ អំពី កត្តាហានិភ័យជាច្រើនដូចជា ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ដែលកុមារមិនទទួលបានការថែទាំ ឬ ការគាំទ្រគ្រប់គ្រាន់ មានការបំពុលបរិយាកាស ខ្វះការយល់ដឹងអំពីសុខភាព បញ្ហាសំណល់ និងហេដ្ឋារចនាសម្ព័ន្ធ។



*ការដើរលេងជាធម្មតា ក៏អាចជាការគំរាមកំហែងដល់អាយុជីវិតបានដែរ*

ជំហានវិជ្ជមានមួយឆ្ពោះទៅរកកិច្ចការពារកុមារគឺថា កុមារចំនួន ៧៨% (N=៣៩៩៤) មកពីគ្រួសារដែលបានធ្វើសម្ភាសន៍ក្នុងពេលចុះវាយតម្លៃ មានសំបុត្របញ្ជាក់កំណើត ដែលជាការផ្តល់ឲ្យកុមារមានសិទ្ធិក្នុងនាមជាពលរដ្ឋស្របច្បាប់ម្នាក់។

ទោះជាយ៉ាងនេះក្តី មានសូចនាករជាច្រើនថែមទៀតដែលជាកង្វល់ ៖ ក្នុងចំណោមគ្រួសារចំនួន ១៤%(N=១០៨២) គឺមានកុមារកំពុងធ្វើការក្នុង "ស្ថានភាពប្រកបដោយគ្រោះថ្នាក់"។ (ការវាយតម្លៃនេះពិតជាបានបញ្ជាក់អំពីចរិកការងារដែលកុមារទាំងនេះកំពុងធ្វើ)។

មានសហគមន៍ចំនួន ៤៣% (N=២៥១) បានប្រាប់ថា មានអំពើហិង្សាក្នុងគ្រួសារ ១៤% ជាការបំពានពីគ្រឿងញៀន ៤% ប្រាប់ថា មានការរំលោភបំពានលើផ្លូវភេទ។

### 5.3.4 ការរៀបចំសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធសេវាសង្គម

ចំណុចខ្លាំងរបស់សហគមន៍អ្នកក្រីក្រក្នុងរាជធានីគឺ សហគមន៍ភាគច្រើនបំផុត (៨៦%) បានតែងតាំងតំណាងមួយរូបរបស់ខ្លួន។ អ្នកតំណាងទាំងនោះគឺជាធនធានមនុស្សដ៏សំខាន់នៅថ្នាក់សហគមន៍ ដែលពួកគាត់អាចអនុវត្តន៍មុខងារជាជនបង្គោលសម្រាប់អន្តរាគមន៍ និង ពិគ្រោះប្រឹក្សាយោបល់ជួសមុខសហគមន៍។

គេបានបង្កើតមណ្ឌលផ្តល់សេវាសង្គមកិច្ច នៅក្នុងសហគមន៍មួយ ក្នុងចំណោមប្រាំសហគមន៍អ្នកក្រីក្រនៅរាជធានី ហើយប្រហែលជាមកពីសហគមន៍ជាច្រើនមានទំហំតូចៗ ដូច្នោះចំនួនមណ្ឌលនេះ ក៏តិចតាមនោះដែរ។ មានសហគមន៍ចំនួនត្រឹមតែ ១៦ ប៉ុណ្ណោះដែលមានធនធានសម្រាប់ដោះស្រាយឆ្លើយតបសេចក្តីត្រូវការរបស់កុមារ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា សហគមន៍ចំនួន ២០ បានបង្កើតឱ្យមានមូលនិធិសង្គម ចាត់ចែង

ដោយសហគមន៍ផ្ទាល់ សម្រាប់ឆ្លើយតបបញ្ហានានាដែលកើតមាននៅក្នុងសហគមន៍ដូចជា ពេលមានអាសន្ន ត្រូវការសេវាពេទ្យ ជាដើម។ មូលនិធិដែលសហគមន៍បង្កើត និង ចាត់ចែងដោយផ្ទាល់ខ្លួនឯងនេះ ក៏ជាធនធានដ៏មានសារៈសំខាន់ផងដែរ សម្រាប់អន្តរាគមន៍នៅថ្ងៃអនាគត។

អ្វីដែលជាការលើកទឹកចិត្តខ្លាំងនោះគឺ សហគមន៍ភាគច្រើនបំផុត កំពុងទទួលបានជំនួយពីស្ថាប័ន ឬ ទីភ្នាក់ងារនានាពីខាងក្រៅសហគមន៍ ដោយមានតំណាងសហគមន៍ចំនួន ៧៧% បានប្រាប់ថា គាត់បានទទួលការគាំទ្រពីបណ្តាទីភ្នាក់ងារនានា ពីខាងក្រៅសហគមន៍។

**តារាងទី 16 : ការរៀបចំសហគមន៍ និងសេវាសង្គម**

| | N ចម្លើយតំណាងសហគមន៍ | ភាគរយសហគមន៍ |
|---|---|---|
| តំណាងឲ្យអ្នកក្រីក្រ (N=២៧៤) | 235 | 85.8% |
| មណ្ឌលសេវាសង្គមកិច្ច នៅក្នុងសហគមន៍ (N=២៦៦) | 52 | 19.5% |
| ធនធានសម្រាប់ឆ្លើយតបសេចក្តីត្រូវការរបស់កុមារ (N=២៧០) | 16 | 5.9% |
| មណ្ឌលកុមារកំព្រានៅក្នុងសហគមន៍ (N=២៦៦) | 29 | 10.9% |
| សេវា/មូលនិធិសង្គម នៅក្នុងសហគមន៍ (N=២៦៣) | 54 | 20.5% |
| សេវាគាំទ្រពីទីភ្នាក់ងារផ្សេងៗទៀត (N=២៧៧) | 212 | 76.6% |

(ប្រភព៖ សម្ភាសន៍ជាមួយតំណាងសហគមន៍)

រូបភាពទី ៨ បង្ហាញចម្លើយចម្រុះ ដែលអ្នកផ្តល់ចម្លើយបានឆ្លើយ ទាក់ទងនឹងប្រភពនៃការគាំទ្រពីអ្នកខាងក្រៅ។ អាជ្ញាធរមូលដ្ឋានថ្នាក់សង្កាត់ និង ខណ្ឌ បានផ្តល់ការគាំទ្រជូនសហគមន៍ចំនួនជាង ៩០%។ លើសពីនេះ គឺមានដៃគូរអភិវឌ្ឍន៍ជាតិ និង អន្តរជាតិនានា បានផ្តល់ការគាំទ្រជូនសហគមន៍ចំនួន ៦០% ក្នុងចំណោមសហគមន៍ដែលបានចុះអង្កេត និង ក្នុងចំណោមសហគមន៍ចំនួនប្រាំ គឺមានសហគមន៍ចំនួនមួយ ដែលបានទទួលជំនួយពីមន្ទីរបច្ចេកទេសរដ្ឋ ឬ ពីសប្បុរសជន។

អ្វីដែលត្រូវកត់សម្គាល់នោះគឺថា ទោះបីជាមានការគាំទ្រពីរចនាសម្ព័ន្ធសង្គមខាងក្រៅក៏ដោយ ក៏សេវានៅតែមិនទាន់បានអភិវឌ្ឍន៍ខ្លាំងខ្លានៅឡើយដែរ បើធៀបទៅនឹងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវថ្នល់ ឬ ការផ្គត់

ផ្គង់ថាមពលអគ្គីសនី ជាដើម។ ច្បាស់ជាងនេះទៅទៀតនោះគឺថា អភិបាលកិច្ចមូលដ្ឋាន កំពុងនាំមុខក្នុងការគាំទ្រដល់សហគមន៍អ្នកក្រីក្រនៅក្នុងរាជធានី។

**រូបភាពតួលេខទី ៨ : អ្នកពីខាងក្រៅផ្ដល់ការគាំទ្រដល់សហគមន៍អ្នកក្រីក្រក្នុងរាជធានីចំនួន ២១២ សហគមន៍**




(ប្រភព៖ សម្ភាសន៍ជាមួយតំណាងសហគមន៍ អាចជាចម្លើយចម្រុះ)

## 6 សេចក្ដីសន្និដ្ឋាន

### 6.1 ស្ថានភាពទូទៅ - ទីតាំងនៃការតាំងទីលំនៅ និង ប្រជាសាស្ត្រ

សហគមន៍អ្នកក្រីក្រក្នុងរាជធានី មានចំនួនរាប់រយសហគមន៍ កំពុងរស់នៅរាយប៉ាយក្នុងខណ្ឌទាំង ៩ នៅរាជធានីភ្នំពេញ ដែលមានទ្រង់ទ្រាយជាសហគមន៍ខុសៗគ្នា ដោយមានស្ថានភាព បញ្ហា និងសេចក្ដីត្រូវការផ្សេងៗគ្នារៀងៗខ្លួន។ វិធីសាស្ត្រ "ធ្វើផែនការ ឬ ប្លូព្រីន" ដើម្បីឆ្លើយតបចំពោះសេចក្ដីត្រូវការ សម្រាប់អភិវឌ្ឍន៍របស់អ្នកក្រីក្រក្នុងរាជធានី គឺមិនអាចអនុវត្តន៍ទៅបានទេ ដូច្នេះតម្រូវឱ្យមានការខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយផ្សេងៗគ្នា សម្រាប់ដោះស្រាយសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋម្នាក់ៗដោយឡែកៗពីគ្នាតាមការជាក់ស្ដែង។

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ដែលប្រជាពលរដ្ឋបានតាំងទីលំនៅតាមទីប្រជុំជននៅក្នុង និងក្រៅរាជធានីដោយពុំមានច្បាប់ទំលាប់ច្រើនឡើយ។ ការតាំងទីលំនៅ បានកើនឡើងនៅតាមប្រព័ន្ធលូទឹក ផ្លូវរថភ្លើង ទន្លេ និងផ្លូវទឹក ឬប្រឡាយទឹកតូចៗ និងតាមផ្លូវជាតិមួយចំនួន ដែលទាំងអស់នោះសុទ្ធតែជាដីសាធារណៈ។

សហគមន៍ខ្លះ ស្ថិតនៅចំកណ្តាលរាជធានី ដែលមិនសូវជាមានដីច្រើនសម្រាប់សាងសង់ជម្រក ដូច្នោះពួកគាត់ក៏សាងសង់លំនៅដ្ឋាននៅលើដំបូលអគារ។ ដោយសាររាជធានីភ្នំពេញមានកំណើនសេដ្ឋកិច្ចខ្លាំង និងមានកំណើនប្រជាពលរដ្ឋច្រើន ដូច្នោះវាតម្រូវឱ្យមានការធ្វើទំនើបនីយកម្មហេដ្ឋារចនាសម្ព័ន្ធ ហើយក៏បានធ្វើឱ្យមានសម្ពាធទៅលើដីធ្លីកើនឡើងផងដែរ។ មកទល់ពេលនេះ មានសហគមន៍អ្នកក្រីក្រក្នុងរាជធានីជាច្រើនសហគមន៍ ត្រូវបានរៀបចំ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល។ ក៏ប៉ុន្តែ ត្រូវធ្វើការសិក្សា និងបញ្ជាក់បន្ថែមទៀតអំពីស្ថានភាពដីធ្លីរបស់សហគមន៍អ្នកក្រីក្រក្នុងរាជធានី។ ទស្សនៈទូទៅជាប្រព័ន្ធ និងទូលំទូលាយ មួយអាចជួយធ្វើឱ្យប្រជាពលរដ្ឋមានភាពច្បាស់លាស់សម្រាប់ពួកគាត់រៀបចំកសាងផែនការអភិវឌ្ឍន៍សហគមន៍របស់ខ្លួននាពេលអនាគត។

លំនៅដ្ឋានដែលប្រជាពលរដ្ឋបានសាងសង់នៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី ភាគច្រើនគឺជាប្រភេទផ្ទះតូចៗធ្វើពីឈើ ឬ ថ្ម ដោយសារតែទីកន្លែងវាតូចចង្អៀត។ ទោះជាយ៉ាងនេះក៏ដោយ ក៏គ្រួសារភាគច្រើន (៨៣%) និយាយថា ផ្ទះទាំងនោះជាអចលនទ្រព្យរបស់ពួកគាត់ ហើយផ្ទះទាំងនោះសាងសង់ឡើងជាសំណង់អចិន្ត្រៃយ៍ មិនមែនជាលក្ខណៈបណ្តោះអាសន្ននោះដែរ។

គ្រួសារនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ គាត់រស់នៅកកកុញ ច្រើនជាងការដែលរាជធានីភ្នំពេញបានគិតជាមធ្យមភាគ និងមានគ្រួសារធំៗជាច្រើន ហើយមានកូនច្រើន ប៉ុន្តែរស់នៅក្នុងទីកន្លែងតូចចង្អៀត។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ១០% ដែលចំនួននេះវាខ្ពស់ជាងចំនួនគ្រួសារគិតជាមធ្យមសម្រាប់កម្ពុជា និងស្ត្រីមានកូនគ្មានស្វាមី (គ្មានប្តី) មានចំនួនជាច្រើនគ្រួសារ។ ក្នុងចំណោមបួនគ្រួសារគឺមានជិតមួយគ្រួសារ ដែលត្រូវមើលថែទាំកុមារងាយរងគ្រោះ និងក្នុងចំណោមប្រាំគ្រួសារ គឺមានមួយគ្រួសារដែលមានអ្នកឈឺជម្ងឺរ៉ាំរ៉ៃ។ សមាសភាពប្រជាសាស្ត្រនេះ បានដាក់សម្ពាធសង្គមយ៉ាងច្រើនទៅលើគ្រួសារ និងសមាជិកក្នុងគ្រួសាររបស់ពួកគាត់។

## 6.2 ស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ច

ប្រជាពលរដ្ឋភាគច្រើននៅក្នុងសហគមន៍អ្នកក្រីក្រក្នុងរាជធានី មានមុខរបរដែលមានជំនាញទាប ដែលក្នុងនោះគឺមានគ្រួសារចំនួន ៦០% អាចរកប្រាក់ចំណូលបានតិចជាង ៧៥ ដុល្លារអាមេរិក ក្នុងមួយខែ។ មុខរបរចម្បងរបស់ពួកគាត់គឺប្រើពលកម្មធ្វើការងារផលិតកម្មឧស្សាហកម្ម ធ្វើការងារនៅតាមការដ្ឋានសំណង់ ឬប្រកបអាជីវ

កម្មខ្នាតតូចតាមគ្រួសារ។ "អ្នកធ្វើការក្នុងការិយាល័យ" មានចំនួនតិចតួចបំផុត ដោយសារថា ជាទូទៅអ្នករស់នៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី គឺជាមនុស្សមានកម្រិតអប់រំទាប។

ដោយសារមានប្រាក់ចំណូលទាប ដូច្នេះគ្រួសារមិនមានលទ្ធភាពសន្សំប្រាក់ទេ ពីព្រោះប្រាក់ដែលរកបានមកត្រូវយកទៅចំណាយភ្លាមៗលើជីវភាពរស់នៅដូចជា លើស្បៀងអាហារជាដើម។ ដូច្នេះពួកគាត់មានធនធានតិចតួច ឬ ក៏គ្មានសោះ សម្រាប់ដោះស្រាយបញ្ហាដែលមិនអាចដឹងមុនដូចជា ជម្ងឺកើតមានលើសមាជិក គ្រួសារណាម្នាក់។ ជាលទ្ធផល គឺភាគរយមួយដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា គ្រួសារចំនួន ៨៣% បានជាប់ជំពាក់បំណុលគេ ដែលធ្វើឲ្យពួកគាត់កាន់តែងាយរងគ្រោះ ធ្លាក់ចូលក្នុងភាពក្រីក្រកាន់តែជ្រៅ។

ការបង្កើនសមត្ថភាពសេដ្ឋកិច្ចរបស់គ្រួសារ តាមរយៈការមានការងារល្អៗធ្វើ ដែលមានប្រាក់ចំណូលខ្ពស់ អាចជួយដោះស្រាយបានបញ្ហាស្នូលរបស់សហគមន៍អ្នកក្រីក្រក្នុងរាជធានី។ ការអប់រំ មានតួនាទីយ៉ាងសំខាន់មួយនៅក្នុងអន្តរាគមន៍រយៈពេលខ្លី និង រយៈពេលយូរអង្វែង។

## 6.3 ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទឹកស្អាត និងអនាម័យ

ផ្លូវថ្នល់ (៩៦%) ថាមពលអគ្គិសនី (៩២%) និងការផ្គត់ផ្គង់ទឹកស្អាត (៨៥%) ត្រូវបានអភិវឌ្ឍន៍យ៉ាងទូលំទូលាយនៅក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។ ទឹកកខ្វក់គឺជាប្រភពជម្ងឺក្រពះពោះវៀន ដូច្នេះការកែលម្អ បន្ថែមទៀតលើការផ្គត់ផ្គង់ទឹកស្អាត ត្រូវបានមើលឃើញថា ជាបញ្ហាប្រឈមយ៉ាងចម្បងមួយក្នុងចំណោមបញ្ហាប្រឈមជាច្រើនទៀត នៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

បញ្ហាដទៃទៀតដូចជា ប្រព័ន្ធលូទឹក (៧២%) និងសេវាប្រមូលសម្រាម (៦០%) ដែលកែលម្អបរិស្ថាន អនាម័យនៅតែជាកត្តាគ្រោះថ្នាក់ធំមួយនៅឡើយ សម្រាប់សុខភាពរបស់ប្រជាពលរដ្ឋ និងជាកង្វល់របស់តំណាងសហគមន៍ជាច្រើន។

ការយល់ដឹងអំពីអនាម័យខ្លួនប្រាណ និងការបំពុលបរិស្ថាននៅមានកម្រិតទាបនៅឡើយ ក្នុងចំណោមសហគមន៍អ្នកក្រីក្រក្នុងរាជធានី ដូច្នេះត្រូវប្រើវិធីសាស្ត្រផ្តល់ព័ត៌មាន អប់រំ និងប្រាស្រ័យទាក់ទង ដើម្បីសម្រេចឱ្យបានការងារកែលម្អក្នុងរយៈពេលមួយដ៏ខ្លី។ ការិយាល័យទទួលបន្ទុកអភិឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានី បានស្នើឱ្យមានកម្មវិធីសាកល្បង និងយកសហគមន៍ដែលបានរៀបចំល្អរួចហើយ ធ្វើជាគំរូសម្រាប់ទាក់ទាញសហគមន៍ដទៃឱ្យអនុវត្តន៍តាម។

ក្នុងចំណោមគ្រួសារជាសំណាកគំរូ ធ្វើសម្ភាសន៍ក្នុងអង្កេតនេះ គឺមានចំនួន ៨០% បានប្រើប្រាស់បង្គន់អនាម័យ ហើយអត្រានៃគ្រួសារប្រើប្រាស់បង្គន់អនាម័យ អាចកើនឡើងទៅតាមកម្រិតនៃប្រាក់ចំណូលតាមគ្រួសារ។ ក្នុងចំណោមគ្រួសារអ្នកក្រីក្រខ្លាំង គឺចំនួនអ្នកដែលមិនប្រើប្រាស់បង្គន់អនាម័យមានលើសពី ៣០%។

## 6.4 ស្ថានភាពសុខភាព

បង្កើតរចនាសម្ព័ន្ធថែទាំសុខភាពបឋមដូចជា មណ្ឌលសុខភាព (៥២%) ក្រុមគាំទ្រសុខភាពភូមិ (VHSG) (៥៣%) ក្រុមចុះដល់មូលដ្ឋាន (៤៥%) និងសេវាផ្នែកមេរោគអេដស៍/ជម្ងឺអេដស៍ (៥៤%) នៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី បានចំនួនពាក់កណ្តាលនៃសហគមន៍ទាំងអស់។ សេវាថែទាំសុខភាពផ្ទៃពោះមុនពេលសម្រាលកូន (៧៩%) និងកម្មវិធីផ្តល់ថ្នាំបង្ការ (៨៣%) ត្រូវបានប្រើប្រាស់ច្រើន ដោយគ្រួសារដែលបានឆ្លើយតបសំណួរអង្កេតនេះ។ ស្ថាប័នផ្តល់សេវា ដែលស្ត្រីចូលចិត្តជាងគេសម្រាប់មើលថែទាំសុខភាពផ្ទៃពោះមុនពេលសម្រាលកូននោះគឺស្ថានប័នរដ្ឋ។

ទោះបីជាមានសេវាទាំងនេះហើយក៏ដោយ ក៏លទ្ធផលខ្លះ ទទួលបានពីការធ្វើអង្កេតទាក់ទងនឹងសុខភាព និងការទទួលបានសេវានេះ នៅមានកន្លែងខ្លះដែលត្រូវបារម្ភដែរ។

យោងតាមការវិនិច្ឆ័យយល់ឃើញផ្ទាល់របស់ពួកគាត់ គឺមានគ្រួសារ (៤៣%) និងតំណាងសហគមន៍ជាច្រើន (៥០%) នាក់ បានប្រាប់ថា មានកុមារ "ខ្វះអាហារូបត្ថម្ភ" និងមាន ៣២% ប្រាប់ថា មានកុមារកើតជម្ងឺរាគ។

ទាក់ទងនឹងការទទួលបានសេវាសុខភាពនេះដែរ គឺមានប្រជាពលរដ្ឋជាច្រើន ត្រូវជំពាក់បំណុលគេ ក្នុងនោះគឺមាន ៤៥% បានខ្ចីប្រាក់ពីគេយកមកព្យាបាលជម្ងឺ និង ៥% យកមកប្រើប្រាស់ពេលសម្រាលកូន។

## 6.5 ការអប់រំ

ការទៅរៀនសាលានៅក្បែរផ្ទះ (៨៨%) គឺមានភាពល្អប្រសើរសម្រាប់កុមារមកពីសហគមន៍អ្នកក្រីក្រក្នុងរាជធានីក៏ដូចជាការចុះឈ្មោះចូលរៀនថ្នាក់ទី ១ ដែរ។ មានគ្រួសារចំនួន ៩១% ដែលមានកូនអាយុ ៦-១១ ឆ្នាំ បានបញ្ជូនកូនទៅរៀន។

បញ្ហាដែលប្រឈមគឺការឆ្លងភូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិ ដែលមានគ្រួសារចំនួនត្រឹមតែ ៧២%ប៉ុណ្ណោះ មានកូនទៅរៀនកម្រិតមធ្យមសិក្សា។ មានគ្រួសារចំនួនតិចជាងពាក់កណ្តាល (៤៣%) ដែលបាននិយាយប្រាប់អំពីការអប់រំកុមារតូច។

ដូចបានលើកឡើងពីខាងលើរួចមកហើយ គឺការកែលម្អកម្រិតអប់រំ វាមានសារៈសំខាន់ខ្លាំងណាស់ ហើយក៏មានសារៈប្រយោជន៍ដែរក្នុងការចម្រេចបានដំណោះស្រាយរយៈពេលយូរអង្វែង និងប្រកបដោយចីរភាពក្នុងការបង្កើនសមត្ថភាពសង្គមកិច្ច-សេដ្ឋកិច្ច។ ដូច្នេះ ការធានាឲ្យមានការអប់រំមានសមភាព និងឈានដល់កម្រិតខ្ពស់សម្រាប់កុមារមកពីសហគមន៍អ្នកក្រីក្រក្នុងរាជធានីនោះ គឺជាទិសដៅរួមមួយរបស់បណ្តាអ្នកពាក់ពន្ធ័ទាំងឡាយនៅក្នុងការងារអភិវឌ្ឍន៍។

## 6.6 កិច្ចការពារកុមារ

កិច្ចការពារសិទ្ធិកុមារ ឱ្យកុមារមានជីវិត មានសិទ្ធិរស់រាន និងសិទ្ធិអភិវឌ្ឍន៍ ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាកាតព្វកិច្ចយ៉ាងសំខាន់មួយរបស់រដ្ឋ និងអ្នកបំពេញតួនាទីភារកិច្ច នៅគ្រប់លំដាប់ថ្នាក់។

អភិបាលកិច្ចមូលដ្ឋាន ដែលទាក់ទាញការគាំទ្រសិទ្ធិកុមារ មានសារៈសំខាន់ក្នុងការធានាថា រាល់ការសម្រេចចិត្តលើការធ្វើផែនការអភិវឌ្ឍន៍ គឺត្រូវតែពិចារណាអំពីសាសេចក្តីការ និងសិទ្ធិរបស់កុមារ។

ជាការលើកទឹកចិត្តមួយដែរ ដែលសហគមន៍ជាច្រើន (៧៧%) ទទួលបានការគាំទ្រពីស្ថាប័ន ឬ ទីភ្នាក់ងារនានាមកពីខាងក្រៅសហគមន៍ ក៏ប៉ុន្តែ មានសហគមន៍មួយចំនួនតូច គឺតែ ៦% ប៉ុណ្ណោះ ដែលមានធនធានសម្រាប់ដោះស្រាយសេចក្តីការរបស់កុមារ។ មានសហគមន៍ចំនួនត្រឹមតែ ១១% ប៉ុណ្ណោះ ដែលមានមណ្ឌលសម្រាប់ឆ្លើយតបសេចក្តីត្រូវការរបស់កុមារកំព្រា ឬកុមារដែលត្រូវបានគេបោះបង់ចោល ប៉ុន្តែមិនមានមណ្ឌលសេវាសង្គមកិច្ចច្រើនទេ (២០%)។

ដោយសារមានសហគមន៍ភាគច្រើន (៩១%) បានទទួលការគាំទ្រពីរាជរដ្ឋាភិបាល - ខណ្ឌ និងសង្កាត់ - ដូច្នេះគេឃើញមានឱកាសមួយសម្រាប់រួមចំណែកដល់ការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍។ ការពង្រីកការពិគ្រោះយោបល់ជាមួយសហគមន៍តាមរយៈគណៈកម្មការនានា និងក្រុមការងារផ្សេងៗ គឺវាមានសារៈសំខាន់ខ្លាំងណាស់។ គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មការសង្កាត់ទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មការវិនិយោគឃុំ/សង្កាត់ មានតួនាទីសំខាន់ ក្នុងការទាក់ទាញការ

គាំទ្រចំពោះវិធានការចាំបាច់នានាដើម្បីឈានទៅសម្រេចបានការអនុវត្តសិទ្ធិកុមារនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី។

## 7 អនុសាសន៍/សកម្មភាព

វិសាសភាពអនុសាសន៍ មានភាពទូលំទូលាយ និងចាំបាច់ត្រូវមានវិធីសាស្រ្តចម្រុះមួយសម្រាប់ដោះស្រាយរាល់សេចក្តីត្រូវការរបស់សហគមន៍អ្នកក្រីក្រក្នុងរាជធានី។

អនុសាសន៍ភាគច្រើន ត្រូវបានធ្វើឡើងតាមសកម្មភាពជាក់លាក់របស់ការិយាល័យទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានី ដើម្បីពិនិត្យតាមដានលទ្ធផលដែលបានរកឃើញ និងសេចក្តីសន្និដ្ឋានរបស់អង្កេតនេះ និងដើម្បីបន្តការចូលរួមរបស់អ្នកពាក់ពន្ធ័ទាំងឡាយ និងក្រុមគោលដៅទៅក្នុងសកម្មភាពបន្ថែមទៀត។

**អ្វីដែលសាលារាជធានីភ្នំពេញអាចធ្វើបាន ៖**

- រៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលពីការវាយតម្លៃរបស់ការិយាល័យទទួលបន្ទុកអភិវឌ្ឍន៍សហ-គមន៍អ្នកក្រីក្រ នៅគ្រប់កម្រិតថ្នាក់ដូចជា ថ្នាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងបណ្តាដៃគូអភិវឌ្ឍន៍នានា។ គោលបំណងនៃវគ្គសិក្ខាសាលានេះ គឺបង្កើតការយល់ដឹង និង វិធីសាស្រ្ត រួមគ្នាមួយ នៅក្នុងចំណោមអ្នកអនុវត្តន៍ទាំងអស់ ទាក់ទងនឹងការចូលរួមអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រ ក្នុងរាជធានី ស្របទៅតាមយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។
- សហការជាមួយស្ថាប័នថ្នាក់ជាតិ ព្រមទាំងអង្គការជាតិ អន្តរជាតិ ក្នុងការអនុវត្តសកម្មភាព ទាក់ទងនឹងការអភិវឌ្ឍសហគមន៍អ្នកក្រីក្រក្នុងរាជធានី។
- បន្តចងក្រង និង រៀបចំសហគមន៍ចំនួន ១៧៥ កន្លែង ដែលមិនទាន់មានរចនាសម្ព័ន្ធជាផ្លូវការ។
- បន្តបង្កើត និង រក្សាការប្រមូលទិន្នន័យជាប្រព័ន្ធ ស្តីពីសហគមន៍អ្នកក្រីក្រក្នុងរាជធានី។
- សហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីសិក្សា និង កំណត់សេចក្តីត្រូវការបន្ថែមទៀត សម្រាប់ការអភិវឌ្ឍ នៅតាមសហគមន៍។
- លើកទឹកចិត្តមន្ទីរពាក់ព័ន្ធដូចជា មន្ទីរសុខាភិបាល មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរអប់រំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា និងមន្ទីរពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបង្កើនការផ្តល់សេវាសង្គមដល់សហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញបន្ថែមទៀត។

- បែកចែក/វិភាជ និងគៀរគរធនធានហិរញ្ញវត្ថុឱ្យមានគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍ធនធានសង្គមស្របទៅតាមផែនការអភិវឌ្ឍន៍/វិនិយោគរបស់សាលារាជធានី។

**អ្វីដែលអាជ្ញាធរមូលដ្ឋានអាចធ្វើបាន ៖**

- សហការជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ គណៈកម្មការសង្កាត់ទទួលបន្ទុកកិច្ចការនារី និងកុមារ គណៈ-កម្មការទ្រទ្រង់សាលារៀន និងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ដើម្បីកំណត់សេចក្តីត្រូវការសម្រាប់កិច្ចអភិវឌ្ឍន៍ និងបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សង្កាត់។
- ផ្តល់ការណែនាំដល់សហគមន៍ ឲ្យបង្កើតផែនការអភិវឌ្ឍន៍សហគមន៍ និងធ្វើការសម្រេចលើគម្រោងអភិវឌ្ឍន៍។
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យមើលឱ្យបានលម្អិតលើជំនួយដែលអាចមានសម្រាប់ធ្វើសំណើសុំអភិវឌ្ឍន៍សហគមន៍។ អញ្ជើញអង្គការមិនមែនរដ្ឋាភិបាល ដែលបំពេញការងារនៅក្នុងសង្កាត់ ឱ្យចូល រួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់/គណៈកម្មការសង្កាត់ ទទួលបន្ទុកកិច្ចការនារី និង កុមារ ដើម្បីកសាងទំនាក់ទំនង និង សហការគ្នា។
- ពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋាន (សំបុត្រកំណើត ក្នុងរយៈពេល ៣០ ថ្ងៃ ចុះសំបុត្រអាពាហ៍ពិពាហ៍ មិនអនុញ្ញាតឲ្យរៀបការមុនមានអាយុ ១៨ ឆ្នាំ និង ចុះសំបុត្រមរណភាព ព្រមទាំងមូលហេតុនៃមរណភាព)។
- គណៈកម្មការទ្រទ្រង់សាលារៀន ៖ កាត់បន្ថយការបង់ប្រាក់ក្រៅផ្លូវការ លើកកម្ពស់គុណភាពអនាម័យ បង្កើនតំបន់គ្របដណ្តប់លើសេវាមត្តេយ្យសិក្សាសហគមន៍ ពិនិត្យការងារគ្រប់គ្រងសាលារៀន (ដូចជា ការបែកចែកគ្រូបង្រៀន) ពិនិត្យតាមដានវត្តមានរបស់គ្រូ/សិស្ស នៅតាមសាលារៀន និងអត្រាសិស្សបោះបង់ការសិក្សា និងពលកម្មកុមារជាដើម។
- គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ៖ បង្កើនការចុះដល់មូលដ្ឋាន ដល់គ្រួសារក្រីក្របំផុត និងទាក់ទាញការគាំទ្រ លើការមិនយកថ្លៃសេវាសម្រាប់ប្រជាពលរដ្ឋក្រីក្រ។
- កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងចែកបណ្ណ័ក្រីក្រ (អាយ.ឌី.ភួរ) ដែលជួយអ្នកក្រីក្រឲ្យរួចផុតពីការបង់ថ្លៃសេវាសាធារណៈ ជាពិសេសគឺថ្លៃថែទាំសុខភាព។
- វាយតម្លៃការប្រើប្រាស់ដីធ្លីរបស់សហគមន៍អ្នកក្រីក្រក្នុងរាជធានី ស្របទៅតាមសារាចរណែនាំលេខ ០៣ និងជូនដំណឹងដល់ប្រជាពលរដ្ឋតាំងទីលំនៅឱ្យបានដឹងអំពីការតាំងទីលំនៅរបស់ពួកគាត់នៅថ្ងៃអនាគត។

**អ្វីដែលកម្មវិធីអភិវឌ្ឍន៍ និង ដៃគូអភិវឌ្ឍន៍ អាចធ្វើបាន ៖**

- បន្តពង្រីកអត្រាគ្របដណ្តប់នៃសេវាសាធារណៈ ដែលផ្តួចផ្តើមដោយរាជរដ្ឋាភិបាល។ ដៃគូអភិវឌ្ឍន៍ គួរក្តាប់យកឱកាសនេះ ដើម្បីជួយដល់ស្ថាប័នពាក់ព័ន្ធ នៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ។
- ទំនាក់ទំនងជាមួយទីភ្នាក់ងារឥណទានខ្នាតតូច ដើម្បីផ្តល់ការគាំទ្រដល់ការបង្កើតប្រាក់ចំណូល ផ្តល់ចំណេះដឹងអំពីហិរញ្ញវត្ថុ (ជាពិសេសសម្រាប់យុវជន) និងស្វែងរកលទ្ធភាព សម្រាប់ទទួលបានឥណទាន ជួសជុល/កែលម្អលំនៅដ្ឋាន។
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដែលអាចផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់គ្រួសារអ្នកក្រីក្រក្នុងរាជធានី ដូចជាសិប្បកម្មជាលក្ខណៈគ្រួសារ និងជំនាញផ្សេងៗទៀត ទាក់ទងនឹងការបង្កើតប្រាក់ចំណូល ជំនាញទីផ្សារ ការងារគ្រប់គ្រង ការបើកអាជីវកម្មផ្ទាល់ខ្លួន ភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ និងជួយស្វែងរកទីផ្សារសម្រាប់លក់ផលិតផលដែលបានផលិត។
- ទំនាក់ទំនងជាមួយអ្នកផ្តល់សេវា/ដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំការផ្គត់ផ្គង់ទឹកស្អាត ថាមពលអគ្គីសនី និង បង្គន់អនាម័យ ដល់គ្រួសារដែលមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ យកចិត្តទុកដាក់ជា ពិសេសលើការគ្រប់គ្រងកាកសំណល់សម្រាម នៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី (ស្ថាប័នឯកជន) ដើម្បីទប់ស្កាត់ការផ្ទុះរាលដាលនៃជម្ងឺឆ្លងផ្សេងៗ។
- ផ្តល់ការអប់រំក្រៅប្រព័ន្ធ ដល់កុមារនៅតាមសហគមន៍អ្នកក្រីក្រក្នុងរាជធានី និងខិតខំព្យាយាមធានាថាសិស្សអាចចូលរៀនកម្រិតវិទ្យាល័យ ក្រោយពីបញ្ចប់ថ្នាក់បឋមសិក្សា។
- ផ្តល់អាហារបន្ថែមដល់ស្ត្រីមានផ្ទៃពោះ និងកុមារខ្វះអាហារូបត្ថម្ភនៅតាមតាមសហគមន៍។
- ផ្តល់សេវាថែទាំសុខភាពដល់ស្ត្រី កុមារ និងជនចាស់ជរា
- ផ្សព្វផ្សាយបន្តបន្ថែមទៀតអំពីការប្រាស្រ័យទាក់ទង ស្តីពីការផ្លាស់ប្តូរឥរិយាបថ/អាកប្បកិរិយាប្រព្រឹត្តលើបញ្ហាសុខភាព ទឹកស្អាត និងអនាម័យ និងបរិស្ថាន។

## ៨ ឯកសារភ្ជាប់

### ឧបសម្ព័ន្ធ ១ ៖ ផែនទីខណ្ឌ

ផែនទីខណ្ឌ តំបន់មានព័ណបង្ហាញអំពីសង្កាត់ដែលបានចងក្រងសហគមន៍អ្នកក្រីក្រក្នុងរាជធានី

ផែនទី ១ ៖ ខណ្ឌចំការមន



## ផែនទី ២ ៖ ខណ្ឌដូនពេញ



## ផែនទី ៣ ៖ ខណ្ឌ ៧ មករា



## ផែនទី ៤ ៖ ខណ្ឌទួលគោក



## ផែនទី ៥ ៖ ខណ្ឌដង្កោ




## ផែនទី ៦ ៖ ខណ្ឌមានជ័យ



## ផែនទី ៧ ៖ ខណ្ឌឫស្សីកែវ



## ផែនទី ៨ ៖ ខណ្ឌសែនសុខ



## ផែនទី៩ ៖ ពោធិ៍សែនជ័យ


ផែនទីបង្ហាញទីតាំងសហគមន៍បានចងក្រងតាមសង្កាត់
ខណ្ឌពោធិ៍សែនជ័យ
ពន្លាំង
គោករកា
(៧សហគមន៍)
ក្រាំងធ្នង់
(២សហគមន៍)
សំរោងក្រោម
ស្នោរ
ឳឡោក
កាកាប
ត្រពាំងក្រសាំង
(១២សហគមន៍)
កំបូល
ចោមចៅ
(១១សហគមន៍)
កន្ទោក
ភ្លើងឆេះរទេះ
បឹងធំ
កំណត់សំគាល់
សង្កាត់មិនបានចងក្រង
២៦- ចោមចៅ
២៧- គោករកា
២៨- ត្រពាំងក្រសាំង
២៩- ក្រាំងធ្នង់
N
1:100,000
0 1,250 2,500 5,000m
ផលិតនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១២
470000
477000
484000
1290000
1285000
1280000
1275000
1270000
1265000

## ឧបសម្ព័ន្ធ ២ ៖ ចំនួនសហគមន៍បានចងក្រងតាមទិន្នន័យបច្ចុប្បន្នភាព

| ល.រ | ឈ្មោះខណ្ឌ | ចំនួនសង្កាត់ | ចំនួនភូមិ | ចំនួនសហគមន៍ | កំណត់សំគាល់ |
|---|---|---|---|---|---|
| ១ | ចំការមន | 5 | 17 | 34 | មិនបានសម្ភាសន៍ ២ សហគមន៍ |
| ២ | ដូនពេញ | 8 | 29 | 41 | មិនបានសម្ភាសន៍ ១៦ សហគមន៍ បន្ថែមថ្មី ៦ |
| ៣ | ៧ មករា | 2 | 7 | 13 | មិនបានសម្ភាសន៍ ២ សហគមន៍ |
| ៤ | ទួលគោក | 5 | 24 | 26 | បានសម្ភាសន៍ទាំងអស់ |
| ៥ | ដង្កោ | 6 | 9 | 11 | បន្ថែមថ្មី ២ សហគមន៍ |
| ៦ | មានជ័យ | 9 | 42 | 72 | មិនបានសម្ភាសន៍ 7 សហគមន៍ |
| ៧ | ឫស្សីកែវ | 10 | 29 | 82 | មិនបានសម្ភាសន៍ ១២ សហគមន៍ |
| ៨ | សែន សុខ | 3 | 12 | 24 | បានសម្ភាសន៍ទាំងអស់ |
| ៩ | ពោធិ៍សែនជ័យ | 4 | 22 | 32 | បានសម្ភាសន៍ទាំងអស់ |
| | **សរុប** | **52** | **191** | **335** | |

## ឧបសម្ព័ន្ធ ៣ ៖ បញ្ជីឈ្មោះសហគមន៍អ្នកក្រីក្រ តាមខណ្ឌ សង្កាត់ និង ភូមិ

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| I. ខណ្ឌ ចំការមន | | | |
| ១. សង្កាត់ បឹងកេងកង ៣ | | | |
| ១ | សហគមន៍ពន្លឺថ្មី | ភូមិ ១ | |
| ២ | សាមគ្គីមានជ័យ | ភូមិ ២ | |
| ៣ | សន្តិភាព | | |
| ៤ | ទួលស្លែង A | ភូមិ ៣ | |
| ៥ | ទួលស្លែង B | | |
| ៦ | ត្បៀងធ្លាក់ | | |
| ៧ | ចម្រើនផល | ភូមិ ៤ | |
| ៨ | រស្មីសាមគ្គី | | |
| ៩ | ទឹកកក | ភូមិ ៥ | |
| ១០ | សាមគ្គីរីករាយ | | |
| ១១ | សែនសុខ | ភូមិ ៦ | |
| ១២ | សុខសាន្ត " ក " | ភូមិ ៨ | |
| ១៣ | សុខសាន្ត " ខ " | | |
| ១៤ | សុខសាន្ត " គ " | | |
| ១៥ | សុខសាន្ត " ឃ " | | |
| ១៦ | ចន្ទ្រា | ភូមិ ៩ | |
| ១៧ | សាមគ្គីថ្មី | | |
| ២. សង្កាត់ អូរឡាំពិក | | | |
| ១៨ | សហគមន៍មហាមន្ត្រី | ភូមិមហាមន្ត្រី | |
| ៣ សង្កាត់ ទួលស្វាយព្រៃ ១ | | | |
| ១៩ | ឃ្លាំងក្រដាស | ភូមិ ៦ | |
| ២០ | ជ័យជំនះ | ភូមិ ៧ | មិនបានសម្ភាសន៍ |
| ២១ | ពន្លឺសាមគ្គី | | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៤. សង្កាត់ ទំនប់ទឹក | | | |
| ២២ | សហគមន៍ទំនប់ទឹក សុខសាន | ភូមិ ៤ | |
| ២៣ | សហគមន៍ទំនប់ទឹក បន្ទាយស្លឹក | | |
| ២៤ | សហគមន៍ទំនប់ទឹក I | ភូមិ ៥ | |
| ២៥ | សហគមន៍ទំនប់ទឹក II | | |
| ២៦ | សហគមន៍ទំនប់ទឹក III | | |
| ២៧ | សហគមន៍ទំនប់ទឹក IV | | |
| ៥. សង្កាត់ ផ្សារដើមថ្កូវ | | | |
| ២៨ | សហគមន៍បាដិក ១, ភូមិ ១ | ភូមិ ១ | |
| ២៩ | សហគមន៍បាដិក 2, ភូមិ ១ | | មិនបានសម្ភាសន៍ |
| ៣០ | សហគមន៍បាដិក , ភូមិ 2 | ភូមិ ២ | |
| ៣១ | សហគមន៍បាដិក , ភូមិ 3 | ភូមិ ៣ | |
| ៣២ | សហគមន៍ សាមគ្គីរុងរឿង | ភូមិ ៥ | |
| ៣៣ | សហគមន៍ពន្លក ១, ភូមិ ៥ | | |
| ៣៤ | សហគមន៍ពន្លក ២, ភូមិ ៥ | | |
| **សរុប** | **៣៤ សហគមន៍** | **១៧ ភូមិ** | **មិនបានសម្ភាសន៍ចំនួន ២ សហគមន៍** |
| | **II. ខណ្ឌ ដូន ពេញ** | | |
| ១. សង្កាត់ ផ្សារថ្មីទី១ | | | |
| ៣៥ | មន្រ្តីសង្កាត់ | ភូមិ ៥ | គឺជាសហគមន៍មន្រ្តី សង្កាត់ |
| ២. សង្កាត់ ផ្សារថ្មីទី៣ | | | |
| ៣៦ | សុខសាន្ត | ភូមិ ១២ | |
| ៣៧ | ប្លងតាន់ប៉ាថ្មី | ភូមិ ៧ | |
| ៣៨ | សហគមន៍ភូមិ ៥៣ | ភូមិ ៤ | |
| ៣៩ | សហគមន៍ទី១៤ | ភូមិ ១៤ | |
| ៤០ | សហគមន៍ ដូនពេញ | ភូមិ ១៣ | |
| ៤១ | ផ្សារថ្មីភូមិ ១០ AB | ភូមិ ១០ | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៣. សង្កាត់ ផ្សារកណ្តាល ១ | | | |
| ៤២ | ផ្សារកណ្តាលទី ១ | ភូមិ ១១ | |
| ៤៣ | ផ្សារកណ្តាល ១A | | មិនបានសម្ភាសន៍ |
| ៤៤ | បាញ់ហយ | ភូមិ ១៦ | មិនបានសម្ភាសន៍ |
| ៤៥ | ទ្រុងកុក | ភូមិ ១៥ | មិនបានសម្ភាសន៍ |
| ៤. សង្កាត់ ចតុមុខ | | | |
| ៤៦ | សហគមន៍ ៤/៥ | ភូមិ ៤.៥ | |
| ៥. សង្កាត់ ជ័យជំនះ | | | |
| ៤៧ | ជ័យជំនះ | ភូមិ ៤ | |
| ៤៨ | ព្រហ្មបាយ័ន | ភូមិ ៧ | |
| ៦. សង្កាត់ ផ្សារចាស់ | | | |
| ៤៩ | ហេមជាតិ | ភូមិ ២ | |
| ៥០ | សហគមន៍ ភូមិ ៣ | ភូមិ ៣ | |
| ៥១ | សហគមន៍ វាំក្នាន់ | | |
| ៧. សង្កាត់ ស្រះចក | | | |
| ៥២ | កំពង់ផែ ១ | ភូមិ ១៣ | ថ្មី |
| ៥៣ | កំពង់ផែ ២ | | ថ្មី |
| ៥៤ | កំពង់ផែ ៣ | ភូមិ ១៤ | ថ្មី |
| ៥៥ | មករា ១ | ភូមិ ១៥ | ថ្មី |
| ៥៦ | មករា ២ | | ថ្មី |
| ៥៧ | មករា ៣ | | ថ្មី |
| ៥៨ | សាមគ្គីភូមិ ៣/១ | ភូមិ ៣ | |
| ៥៩ | សាមគ្គីភូមិ ៣/២ | | មិនបានសម្ភាសន៍ |
| ៦០ | សាមគ្គីភូមិ ៣/៣ | | មិនបានសម្ភាសន៍ |
| ៦១ | រំចេក | ភូមិ ៩ | |
| ៦២ | ព្រះកេតុមាលា | ភូមិ ១២ | |
| ៦៣ | សួស្តី | ភូមិ ១១ | |
| ៦៤ | សាមគ្គីភូមិ ៦/៣ | ភូមិ ៦ | មិនបានសម្ភាសន៍ |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៦៥ | សហគមន៍ ២២ | ភូមិ ២ | មិនបានសម្ភាសន៍ |
| ៦៦ | អភិវឌ្ឍន៍ភូមិ ២ | | មិនបានសម្ភាសន៍ |
| ៦៧ | ភូមិ ២០ (ក) | ភូមិ ២០ | មិនបានសម្ភាសន៍ |
| ៦៨ | រំដួល | ភូមិ ២១ | មិនបានសម្ភាសន៍ |
| ៦៩ | សុភមង្គល | | មិនបានសម្ភាសន៍ |
| ៧០ | រួសរាយ | ភូមិ ២៤ | មិនបានសម្ភាសន៍ |
| ៧១ | រស្មី ២៤ (ក) | | មិនបានសម្ភាសន៍ |
| ៧២ | រស្មី ២៤ (ខ) | | មិនបានសម្ភាសន៍ |
| ៧៣ | តាប្រាក់ ៥ | ភូមិ ២២ | មិនបានសម្ភាសន៍ |
| ៧៤ | តាប្រាក់ ៤ | | មិនបានសម្ភាសន៍ |
| ៨. សង្កាត់ វត្តភ្នំ | | | |
| ៧៥ | វត្តភ្នំ | ភូមិ១០ | |
| **សរុប** | **៤១ សហគមន៍** | **២៩ ភូមិ** | **មិនបានសម្ភាសន៍ ១៦ សហគមន៍ ឈ្មោះសហគមន៍បន្ថែមថ្មី ចំនួន ៦** |
| | | **III. ខណ្ឌ ៧ មករា** | |
| ១. សង្កាត់ វាលវង់ | | | |
| ៧៦ | សហគមន៍អគារ ក | ភូមិ ១២ | |
| ៧៧ | សហគមន៍អគារ ខ | | |
| ៧៨ | សហគមន៍អគារ គ | | |
| ៧៩ | សហគមន៍អគារ ឃ | | |
| ៨០ | សហគមន៍អគារ ង | | |
| ៨១ | សហគមន៍អគារ ច | | |
| ៨២ | សហគមន៍ពេទ្យក្រុង | ភូមិ ៤ | |
| ៨៣ | សហគមន៍ ជូលីណា | ភូមិ ៣ | |
| ២. សង្កាត់ មនោរម្យ | | | |
| ៨៤ | អង្គរមានជ័យ | | |
| ៨៥ | រស្មីមនោរម្យ | ភូមិ ១ | មិនបានសម្ភាសន៍ |
| ៨៦ | ថ្នាយបង្គំ | ភូមិ ២ | មិនបានសម្ភាសន៍ |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៨៧ | ថ្មដា | ភូមិ ៣ | |
| ៨៨ | សុខមានជ័យ | ភូមិ ៥ | |
| **សរុប** | **១៣ សហគមន៍** | **៧ ភូមិ** | **មិនបានសម្ភាសន៍ចំនួន ២ សហគមន៍** |
| **IV. ខណ្ឌ ទួលគោក** | | | |
| **១. សង្កាត់ ទឹកល្អក់ ១** | | | |
| ៨៩ | សហគមន៍ភូមិ ៧ | ភូមិ ៧ | |
| ៩០ | សហគមន៍ភូមិ ១៥ | ភូមិ ១៥ | |
| ៩១ | សហគមន៍ភូមិ ១៦ | ភូមិ ១៦ | |
| **២. សង្កាត់ បឹងកក់ ១** | | | |
| ៩២ | សហគមន៍ភូមិ ៣ (347-345) | ភូមិ ៣ | |
| ៩៣ | សហគមន៍ភូមិ ៨ | ភូមិ ៨ | |
| ៩៤ | សហគមន៍ភូមិ ១៤ (ក្រុម 54) | ភូមិ ១៤ | |
| **៣. សង្កាត់ បឹងកក់ ២** | | | |
| ៩៥ | សហគមន៍ភូមិ ២៣ | ភូមិ ២៣ | |
| ៩៦ | សហគមន៍ភូមិ ២១ | ភូមិ ២១ | |
| ៩៧ | សហគមន៍ភូមិ ២២ ( ក ) | ភូមិ ២២ | |
| ៩៨ | សហគមន៍ភូមិ ២២ (ខ) | | |
| ៩៩ | សហគមន៍ភូមិ ២២ (គ) | | |
| ១០០ | សហគមន៍ភូមិ ១២ | ភូមិ ១២ | |
| ១០១ | សហគមន៍ភូមិ ១៧ | ភូមិ ១៧ | |
| ១០២ | សហគមន៍ភូមិ ៨ | ភូមិ ៨ | |
| **៤. សង្កាត់ ផ្សារដើមគរ** | | | |
| ១០៣ | សហគមន៍ មិត្តភាព | មិត្តភាព | |
| **៥. សង្កាត់ បឹងសាឡាង** | | | |
| ១០៤ | សហគមន៍សាមគ្គីភូមិ ១ | ភូមិ ១ | |
| ១០៥ | សហគមន៍សាមគ្គីភូមិ ២ | ភូមិ ២ | |
| ១០៦ | សហគមន៍ក្រីក្រ ភូមិ ៣ | ភូមិ ៣ | |
| ១០៧ | សហគមន៍សាមគ្គីភូមិ ៤ | ភូមិ ៤ | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ១០៨ | សហគមន៍អ្នកក្រីក្រ ភូមិ ៦ | ភូមិ ៦ | |
| ១០៩ | សហគមន៍សាមគ្គីភូមិ ៩ | ភូមិ ៩ | |
| ១១០ | សហគមន៍សាមគ្គីភូមិ ១០ | ភូមិ ១០ | |
| ១១១ | សហគមន៍សាមគ្គីភូមិ ១១ | ភូមិ ១១ | |
| ១១២ | សហគមន៍សាមគ្គីភូមិ ១៤ | ភូមិ ១៤ | |
| ១១៣ | សហគមន៍ក្រីក្រ ភូមិ ១៦ | ភូមិ ១៦ | |
| ១១៤ | សហគមន៍សាមគ្គីភូមិ ១៧ | ភូមិ ១៧ | |
| **សរុប** | **២៦ សហគមន៍** | **២៤ ភូមិ** | |
| | | **V. ខ័ណ្ឌ ដង្កោ** | |
| **១. សង្កាត់ ដង្កោ** | | | |
| ១១៥ | សហគមន៍សាមគ្គីភូមិម៉ែល១ | ម៉ែល | |
| ១១៦ | អភិវឌ្ឍន៍ភូមិម៉ែល ២ | | |
| ១១៧ | សហគមន៍ ភូមិថ្មី | ថ្មី | |
| ១១៨ | សហគមន៍បឹងតាម៉ាត | ខ្វា | |
| **២. សង្កាត់ ព្រៃវែង** | | | |
| ១១៩ | សហគមន៍ទួលសំបូរ | ទួលសំបូរ | |
| ១២០ | សហគមន៍អភិវឌ្ឍន៍ទួលសំបូរ | | ថ្មី |
| ១២១ | សហគមន៍សេរីជីជុះ | សេរីជីជុះ | |
| **៣. សង្កាត់ ជើងឯក** | | | |
| ១២២ | សហគមន៍ជើងឯក | ជើងឯក | |
| **៤. សង្កាត់ ប្រទះឡាង** | | | |
| ១២៣ | សហគមន៍ ជ័យជំនះ | គោកខ្សាច់ | |
| **៥. សង្កាត់ ព្រៃស** | | | |
| ១២៤ | សហគមន៍អន្លង់គងថ្មី | អន្លង់គង | ថ្មី |
| **៦. សង្កាត់ ព្រែកកំពឹស** | | | |
| ១២៥ | សហគមន៍ដំណាក់សង្កែ | ដំណាក់សង្កែ | |
| **សរុប** | **១១ សហគមន៍** | **៩ ភូមិ** | **បន្ថែមថ្មី ២ សហគមន៍** |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| | VI. ខណ្ឌ មានជ័យ | | |
| ១. សង្កាត់ និរោធ | | | |
| ១២៦ | សហគមន៍បឹងឈូកនិរោធ | បឹងឈូក | |
| ១២៧ | សហគមន៍បឹងឈូកមានជ័យ | | |
| ១២៨ | សហគមន៍បឹងឈូកប្រជុំវង្ស | តាងៅ | |
| ១២៩ | សហគមន៍តាងៅលើ | | មិនបានសម្ភាសន៍ |
| ១៣០ | សហគមន៍ដើមព្រីន ១ | | មិនបានសម្ភាសន៍ |
| ១៣១ | សហគមន៍មិត្តភាព | | មិនបានសម្ភាសន៍ |
| ១៣២ | សហគមន៍ព្រៃកបារាំង | | មិនបានសម្ភាសន៍ |
| ១៣៣ | សហគមន៍តាងៅកណ្តាល | | |
| ១៣៤ | សហគមន៍កោះនរា ១ | កោះនរា | មិនបានសម្ភាសន៍ |
| ១៣៥ | សហគមន៍កោះនរា ២ | | មិនបានសម្ភាសន៍ |
| ២. សង្កាត់ ច្បារអំពៅ១ | | | |
| ១៣៦ | សហគមន៍ដើមម៉ាក់ក្លឿ | ភូមិដើមម៉ាក់ក្លឿ | |
| ១៣៧ | សហគមន៍ភូមិព្រែក | ភូមិព្រែក | |
| ១៣៨ | សហគមន៍ដើមអំពិល ១ | ភូមិដើមអំពិល | |
| ១៣៩ | សហគមន៍ដើមអំពិល ២ | | |
| ៣. សង្កាត់ ច្បារអំពៅ២ | | | |
| ១៤០ | សហគមន៍ភូមិដើមចាន់ ១ | ភូមិដើមចាន់ | |
| ១៤១ | សហគមន៍អភិវឌ្ឍន៍ដើមចាន់ | ភូមិដើមចាន់ ១ | |
| ១៤២ | សហគមន៍កណ្តាល(ពេជ្រចាន់គីរី) | ភូមិកណ្តាល | |
| ១៤៣ | សហគមន៍សំណាងមានជ័យ | ភូមិកណ្តាល ១ | |
| ១៤៤ | សហគមន៍ដើមស្លែង ១ | ភូមិដើមស្លែង | |
| ៤. សង្កាត់ ព្រែកប្រា | | | |
| ១៤៥ | រីកចម្រើន | អូរអណ្តូង ១ | |
| ១៤៦ | ចម្រើនអភិវឌ្ឍន៍ (ក) | | |
| ១៤៧ | ព្រែកតាពៅ ១ | ព្រែកតាពៅ | |
| ១៤៨ | ព្រែកតាពៅ ២ | | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ១៤៩ | ចម្រើនអភិវឌ្ឍន៍ | អូរអណ្ដូង | |
| ១៥០ | ព្រះពន្លា | ភូមិព្រះពន្លា | |
| ១៥១ | ជ័យជំនះ | | |
| ៥. សង្កាត់ ចាក់អង្រែលើ | | | |
| ១៥២ | សហគមន៍ព្រែកតាគង់ (រុងរឿង) | ភូមិព្រែកតាគង់ | |
| ១៥៣ | ព្រែកតាគង់ ១ | ព្រែកតាគង់ ១ | |
| ១៥៤ | ព្រែកតាគង់ ២ | ព្រែកតាគង់ ២ | |
| ១៥៥ | ព្រែកតាគង់ ៣ | ព្រែកតាគង់ ៣ | |
| ១៥៦ | ព្រែកតានូ ១ | ព្រែកតានូ ១ | |
| ១៥៧ | ព្រែកតានូ ២ | ព្រែកតានូ ២ | |
| ១៥៨ | ព្រែកតានូ ៣ | ព្រែកតានូ | មិនបានសម្ភាសន៍ |
| ១៥៩ | ព្រែកតានូ | | |
| ៦. សង្កាត់ ចាក់អង្រែក្រោម | | | |
| ១៦០ | សហគមន៍ទួលរកា ១ | ភូមិទួលរកា ១ | |
| ១៦១ | ទួលរកា ៣ | | |
| ១៦២ | ទួលរកា ២ | ទួលរកា | |
| ១៦៣ | ទួលរកា ៤ | | |
| ១៦៤ | ព្រែកតាឡុង ៣ | ព្រែកតាឡុង ១ | |
| ១៦៥ | ព្រែកតាឡុង ១ | ព្រែកតាឡុង ៣ | |
| ១៦៦ | ព្រះនារាយណ៍ | | |
| ១៦៧ | ព្រែកតាឡុង ២ | ភូមិព្រែកតាឡុង | |
| ១៦៨ | ព្រែកតាឡុង ៤ | | |
| ៧. សង្កាត់ បឹងទំពុន | | | |
| ១៦៩ | ចម្រើនផល | ត្នោតជ្រុំ ៣ | |
| ១៧០ | ត្នោតជ្រុំ ៣ | | |
| ១៧១ | ត្នោតជ្រុំ ៨ | ត្នោតជ្រុំ ១ | |
| ១៧២ | នារីឈានមុខ | ត្នោតជ្រុំ | |
| ១៧៣ | ត្នោតជ្រុំ ១ | ត្នោតជ្រុំ ៤ | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ១៧៤ | ត្នោតជ្រុំ ៤ | | |
| ១៧៥ | ត្នោតជ្រុំ ៥ | | |
| ១៧៦ | សហគមន៍ត្នោតជ្រុំ ៦ | ត្នោតជ្រុំ ២ | |
| ១៧៧ | សហគមន៍ត្នោតជ្រុំ ៩ | | |
| ១៧៨ | សហគមន៍ ១ | ក្បាលទំនប់ ២ | |
| ៨. សង្កាត់ ស្ទឹងមានជ័យ | | | |
| ១៧៩ | ជា ផេង | ភូមិឫស្សី | |
| ១៨០ | ភូមិឫស្សីអភិវឌ្ឍន៍ | ភូមិឫស្សី ១ | |
| ១៨១ | ចម្រើនមានជ័យ | ភូមិទ្រា ២ | |
| ១៨២ | ព្រះច័ន្ទក្រហម | ភូមិមានជ័យ | |
| ១៨៣ | សុវណ្ណភូមិមានជ័យ | | |
| ១៨៤ | ស្ទឹងមាសមានជ័យ | | |
| ១៨៥ | អរុណសួស្តី មានជ័យ | | |
| ១៨៦ | ស្រ្តីសាមគ្គីមានជ័យ | | |
| ១៨៧ | មានជ័យស្រ្តីអភិវឌ្ឍន៍ | ភូមិមានជ័យ ១ | |
| ១៨៨ | សន្សំប្រាក់ដើម្បីអភិវឌ្ឍន៍ | | |
| ១៨៩ | សាមគ្គីមានជ័យថ្មី | | |
| ១៩០ | ភ្នាតអភិវឌ្ឍន៍ | ភូមិ ភ្នាត | |
| ១៩១ | ទួលសែនជ័យ ១ | | |
| ១៩២ | ទួលសែនជ័យ ២ | ភូមិព្រែកទាល់ | |
| ១៩៣ | ទួលសែនជ័យ អភិវឌ្ឍន៍ | | |
| ១៩៤ | ចម្រើនមានជ័យ (ក) | | |
| ១៩៥ | អភិវឌ្ឍន៍មានជ័យ | ភូមិដំណាក់ធំ ២ | |
| ១៩៦ | មាតាបិតា សិស្សដើម្បីកុមារ | | |
| ៩. សង្កាត់ វាលស្បូវ | | | |
| ១៩៧ | សហគមន៍គ្រួសារព្រះគ្រីស្ត | ស្វាយតាអុក | |
| **សរុប** | **៧២ សហគមន៍** | **៤២ ភូមិ** | **មិនបានសម្ភាសន៍ ៧ សហគមន៍** |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| VII. ខណ្ឌ ឫស្សីកែវ | | | |
| ១. សង្កាត់ ឫស្សីកែវ | | | |
| ១៩៨ | បុរីមិត្តភាព | មិត្តភាព | |
| ១៩៩ | បុរីសន្តិភាព | | |
| ២០០ | បុរីដើមស្រល់ | | |
| ២០១ | សហគមន៍មិត្តភាព១ | | |
| ២០២ | សហគមន៍មិត្តភាព២ | | |
| ២០៣ | សហគមន៍លេខ៣ | បឹងសាឡាង | |
| ២០៤ | សហគមន៍បឹងសាឡាង | | |
| ២០៥ | ស្ត្រីឃ្លាំងសាំង | ឃ្លាំងសាំង | |
| ២០៦ | រស្មីសោភា 2 | | |
| ២០៧ | រស្មីសោភា 4 | | |
| ២. សង្កាត់ គីឡូម៉ែត្រលេខ ៦ | | | |
| ២០៨ | ជ័យមង្គល | ក្រោលគោ | |
| ២០៩ | ឆេកូថ្មី | | |
| ២១០ | ក្រោលគោ | | |
| ២១១ | ឆេកូ | | |
| ២១២ | សួនថ្មីក្រុម ១ | ស្ពានខ្ពស់ | |
| ២១៣ | ទន្លេសាប ១ | បឹងឈូក | |
| ២១៤ | មនោរម្យ | | មិនបានសម្ភាសន៍ |
| ៣. សង្កាត់ ច្រាំងចំរេះ ១ | | | |
| ២១៥ | ចម្រើនជាតិ | ភូមិ ១ | |
| ២១៦ | សែនសំណាង | ភូមិ ២ | |
| ២១៧ | ចម្រើនផល | ភូមិ ៣ | |
| ២១៨ | រីកចម្រើន | | |
| ២១៩ | លូតលាស់ | | |
| ៤. សង្កាត់ ច្រាំងចំរេះ ២ | | | |
| ២២០ | ម្លិះរួត | ភូមិ ខ១ | មិនបានសម្ភាសន៍ |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ២២១ | សន្តិភាព | | មិនបានសម្ភាសន៍ |
| ២២២ | ស្រះត្រី | ភូមិ ខ២ | |
| ២២៣ | វិហ៊ា | | |
| ២២៤ | ជ័យជំនះ | | |
| ២២៥ | សហគមន៍នេសាទទី 4-9 | ភូមិ ឃ | |
| ២២៦ | សហគមន៍នេសាទទី 5 | | |
| ២២៧ | សហគមន៍នេសាទទី 6 | | |
| ២២៨ | សហគមន៍នេសាទទី 7 | | |
| ២២៩ | សហគមន៍នេសាទទី 8 | | |
| ២៣០ | សហគមន៍នេសាទទី 9 | | មិនបានសម្ភាសន៍ |
| ២៣១ | សហគមន៍ចរិយា | | |
| ២៣២ | នេសាទទី 10 | ភូមិ ក | |
| ២៣៣ | នេសាទទី 11 | | |
| ២៣៤ | នេសាទទី 3 | | |
| ២៣៥ | រស្មីគង្គារ | | |
| ២៣៦ | នេសាទទី 1 | | មិនបានសម្ភាសន៍ |
| ២៣៧ | នេសាទទី 2 | | មិនបានសម្ភាសន៍ |
| ៥. សង្កាត់ ស្វាយប៉ាក | | | |
| ២៣៨ | អភិវឌ្ឍន៍ថ្មី | ភូមិស្វាយប៉ាក | |
| ២៣៩ | បុរីកម្មករ | ឡកំបោ | |
| ២៤០ | ស្ទឹងកំបុត | | |
| ៦. សង្កាត់ ជ្រោយចង្វា | | | |
| ២៤១ | សហគមន៍កុឡាឡោម ១ | ភូមិទី២ | |
| ២៤២ | សហគមន៍កុឡាឡោម ២ | | |
| ២៤៣ | សហគមន៍ឯករង្សី ១ | ភូមិទី១ | |
| ២៤៤ | សហគមន៍ឯករង្សី | | មិនបានសម្ភាសន៍ |
| ២៤៥ | សហគមន៍ប្រជុំសាគរ | | មិនបានសម្ភាសន៍ |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៧. សង្កាត់ ព្រែកលាប | | | |
| ២៤៦ | ខ្វរលិច | ភូមិ ខ្វរ | |
| ២៤៧ | ស្ពានទី ៣ | | |
| ២៤៨ | សុភមង្គល | ព្រែកលាភ | |
| ២៤៩ | ព្រែកខ្ចិត | | |
| ២៥០ | ដីមាស | | |
| ៨. សង្កាត់ ព្រែកតាសេក | | | |
| ២៥១ | សហគមន៍ព្រែកតាវ័ត្ត | ភូមិព្រែកតាវ័ត្ត | |
| ២៥២ | សហគមន៍ព្រែកតាគង់ | ព្រែកតាគង់ | |
| ២៥៣ | សហគមន៍ព្រែកតាប្រាក់ | | |
| ២៥៤ | សហគមន៍ភូមិថ្មី | | |
| ៩. សង្កាត់ កោះដាច់ | | | |
| ២៥៥ | សាមគ្គីរនះ ចុងកោះ | ចុងកោះ | |
| ២៥៦ | សហគមន៍ភូមិល្វា | ល្វា | |
| ២៥៧ | សហគមន៍អភិវឌ្ឍន៍នារីក.ដ | ក្បាលកោះ | |
| ២៥៨ | អភិវឌ្ឍន៍សាមគ្គីក្បាលកោះ | | |
| ២៥៩ | សាមគ្គីក្បាលកោះ | | |
| ២៦០ | តម្បាញក្រពុំពេជ្រកោះដាច់ | កោះដាច់ | |
| ២៦១ | សហគមន៍ក្រពុំពេជ្រ | | |
| ២៦២ | សហគមន៍រនះចុងកោះ | ភូមិរនះ | |
| ២៦៣ | សហគមន៍ក្រពុំពេជ្រ | | មិនបានសម្ភាសន៍ |
| ១០. សង្កាត់ ទួលសង្កែ | | | |
| ២៦៤ | សហគមន៍ផ្សារតូច A | ភូមិផ្សារតូច | |
| ២៦៥ | សហគមន៍ផ្សារតូច B | | |
| ២៦៦ | សហគមន៍បឹងតាចន | | |
| ២៦៧ | ទួលសង្កែ 2=B | ភូមិទួលសង្កែ | មិនបានសម្ភាសន៍ |
| ២៦៨ | ទួលសង្កែ 2=C | | មិនបានសម្ភាសន៍ |
| ២៦៩ | ទួលសង្កែ 1=B | | មិនបានសម្ភាសន៍ |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ២៧០ | ផ្លូវរថភ្លើង | | |
| ២៧១ | គង្គាផុស I | ភូមិទូលគោក | |
| ២៧២ | គង្គាផុស II | | |
| ២៧៣ | គង្គាផុស III | | |
| ២៧៤ | យុត្តិធម៌ថ្មី | | |
| ២៧៥ | ពន្លឺថ្មី ១ | | |
| ២៧៦ | ព្រែកជីក | | |
| ២៧៧ | បឹងទូលគោក | | |
| ២៧៨ | ទួលសំពៅ | | |
| ២៧៩ | ឃ្លាំងរំសេវ | | |
| **សរុប** | **៨២ សហគមន៍** | **២៩ ភូមិ** | **មិនបានសម្ភាសន៍ ១២ សហគមន៍** |
| | VIII. ខ័ណ្ឌ សែន សុខ | | |
| ១. សង្កាត់ ភ្នំពេញថ្មី | | | |
| ២៨០ | សហគមន៍ទំនប់ ៣ | ភូមិទំនប់ | |
| ២៨១ | សហគមន៍ទំនប់ ១ | | |
| ២៨២ | សហគមន៍ទំនប់ ២ | | |
| ២៨៣ | សហគមន៍ទំនប់ ៣ | | |
| ២៨៤ | សហគមន៍ភ្នំពេញថ្មី | | |
| ២៨៥ | សហគមន៍បុរីព្រែនគរ | គោកឃ្លាង | |
| ២៨៦ | សហគមន៍ I | | |
| ២៨៧ | សហគមន៍ II | | |
| ២៨៨ | សហគមន៍ III | | |
| ២៨៩ | សហគមន៍អភិវឌ្ឍន៍ស្ត្រីក្រីក្រ | | |
| ២៩០ | សហគមន៍ជឿនលឿន | ត្រពាំងស្វាយ | |
| ២៩១ | សហគមន៍កសិករ | ច្រេស | |
| ២. សង្កាត់ ទឹកថ្លា | | | |
| ២៩២ | សហគមន៍ធារាសាស្ត្រ | ចុងថ្នល់កើត | |
| ២៩៣ | សហគមន៍ទឹកថ្លាស្ត្រីក្រីក្រ | | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ២៩៤ | សហគមន៍សាមគ្គី ១ | ចុងថ្នល់លិច | |
| ៣. សង្កាត់ ឃ្មួញ | | | |
| ២៩៥ | សែនសប្បាយ- ភូមិសែនសុខ ១ | សែនសុខទី ១ | |
| ២៩៦ | សែនសុខទី២ | សែនសុខទី ២ | |
| ២៩៧ | សែនរីករាយ -ភូមិសែនសុខ ៥ | | |
| ២៩៨ | សែនពន្លឺ ១ - ភូមិសែនសុខ ៥ | ភូមិសែនសុខ ៥ | |
| ២៩៩ | សែនពន្លឺ ២- ភូមិសែនសុខ ៥ | | |
| ៣០០ | សែនសួស្តី - ភូមិសែនសុខ ៥ | | |
| ៣០១ | សំរោងមានជ័យ - ភូមិសំរោង | ភូមិសំរោង | |
| ៣០២ | ភូមិសែនសុខ ទី ៧ | ភូមិសែនសុខ ទី ៧ | |
| ៣០៣ | ភូមិត្រពាំងរាំង | ភូមិត្រពាំងរាំង | |
| **សរុប** | **២៤ សហគមន៍** | **១២ ភូមិ** | |
| | IX. ខ័ណ្ឌ ពោធិ៍សែនជ័យ | | |
| ១. សង្កាត់ គោករកា | | | |
| ៣០៤ | សហគមន៍ជ្រេសថ្មី | ជ្រេស | |
| ៣០៥ | សហគមន៍សំព័រថ្មី | ត្រពាំងសំព័រ | |
| ៣០៦ | សហគមន៍ស្វាយចេកថ្មី | ស្វាយចេក | |
| ៣០៧ | សហគមន៍អណ្តូង ១ | | |
| ៣០៨ | សហគមន៍អណ្តូង ២ | អូរអណ្តូង | |
| ៣០៩ | សហគមន៍អណ្តូង 3 | | |
| ៣១០ | សហគមន៍ខ្មែរលើថ្មី | ខ្មែរលើ | |
| ២. សង្កាត់ ចោមចៅ | | | |
| ៣១១ | សហគមន៍ កំពែង | ព្រៃល្វ | |
| ៣១២ | សហគមន៍ថ្មគោល ១ | ថ្មគោល | |
| ៣១៣ | ពង្រសែនជ័យ | ទួលពង្រ | |
| ៣១៤ | បុរីសន្តិភាព ២ សហគមន៍ ១ | | |
| ៣១៥ | បុរីសន្តិភាព ២ សហគមន៍ ២ | ដំណាក់ត្រយឹង | |
| ៣១៦ | បុរីសន្តិភាព ២ សហគមន៍ ៣ | | |

| ល.រ | ឈ្មោះសហគមន៍ | ភូមិ | ផ្សេងៗ |
|---|---|---|---|
| ៣១៧ | បុរីសន្តិភាព ២ សហគមន៍ ៤ | | |
| ៣១៨ | បុរីសន្តិភាព ២ សហគមន៍ ៥ | | |
| ៣១៩ | បុរីសន្តិភាព ២ សហគមន៍ ៦ | | |
| ៣២០ | បុរីសន្តិភាព ២ សហគមន៍ ៧ | | |
| ៣២១ | បុរីសន្តិភាព ២ សហគមន៍ ៨ | | |
| ៣. សង្កាត់ ក្រាំងធ្នង់ | | | |
| ៣២២ | សហគមន៍ ក្រាំងអង្គ្រង ២ | ក្រាំងអង្គ្រង | |
| ៣២៣ | សហគមន៍ ក្រាំងអង្គ្រង ១ (២៧១) | | |
| ៤. សង្កាត់ ត្រពាំងក្រសាំង | | | |
| ៣២៤ | សហគមន៍សាមគ្គី ១ | សាមគ្គី ១ | |
| ៣២៥ | សហគមន៍សាមគ្គី ២ | សាមគ្គី ២ | |
| ៣២៦ | សហគមន៍សាមគ្គី ៣ | សាមគ្គី ៣ | |
| ៣២៧ | សហគមន៍សាមគ្គី ៤ | សាមគ្គី ៤ | |
| ៣២៨ | សហគមន៍សាមគ្គី ៥ | សាមគ្គី ៥ | |
| ៣២៩ | សហគមន៍សាមគ្គី ៦ | សាមគ្គី ៦ | |
| ៣៣០ | សហគមន៍ត្រពាំងអញ្ចាញ ១ | ត្រពាំងអញ្ចាញ ១ | |
| ៣៣១ | សហគមន៍ត្រពាំងអញ្ចាញ ២ | ត្រពាំងអញ្ចាញ ២ | |
| ៣៣២ | សហគមន៍ត្រពាំងអញ្ចាញ ៣ | ត្រពាំងអញ្ចាញ ៣ | |
| ៣៣៣ | សហគមន៍ត្រពាំងអញ្ចាញ ៤ | ត្រពាំងអញ្ចាញ ៤ | |
| ៣៣៤ | សហគមន៍ត្រពាំងអញ្ចាញ ៥ | ត្រពាំងអញ្ចាញ ៥ | |
| ៣៣៥ | សហគមន៍ត្រពាំងអញ្ចាញ ៦ | ត្រពាំងអញ្ចាញ ៦ | |
| **សរុប** | **៣២ សហគមន៍** | **២២ ភូមិ** | |

# ឧបសម្ព័ន្ធ ៤ ៖ កម្រងសំណួរសម្រាប់ធ្វើសម្ភាសន៍គ្រួសារនៅតាមសហគមន៍អ្នកក្រីក្រ

## ឧបសម្ព័ន្ធ ៤៖ ការសិក្សាអំពីស្ថានភាពសហគមន៍អ្នកក្រីក្ររាជធានីភ្នំពេញ ឆ្នាំ ២០១១

លេខសំគាល់បញ្ជីសំណួរ:.............................

សំភាសន៍ដោយ:.................................. លេខទូស័ព្ទ:...........................

| | | | | |
|---|---|---|---|---|
| 1 | ថ្ងៃ /ខែ/ឆ្នាំ សំភាសន៍: | | | |
| 2 | ឈ្មោះសហគមន៍: | | | |
| 3 | ឈ្មោះភូមិ: | | | |
| 4 | ឈ្មោះសង្កាត់: | | | |
| 5 | ឈ្មោះខណ្ឌ: | | | |
| | **<u>ផ្នែកទីមួយ : ព័ត៌មានមូលដ្ឋានអំពី គ្រួសារ/អ្នកផ្តល់ការសម្ភាសន៍</u>** | | | |
| 6 | ភេទអ្នកផ្តល់ការសម្ភាសន៍ | ប្រុស | | ១- ☐ |
| | | ស្រី | | ២- ☐ |
| 7 | អាយុអ្នកផ្តល់ការសម្ភាសន៍ | ...............................ឆ្នាំ | | |
| | | សរុប | ប្រុស | ស្រី |
| 8 | តើមានសមាជិកគ្រួសារប៉ុន្មាននាក់? | | | |
| 9 | តើមានសមាជិកគ្រួសារអាយុក្រោម ១៨ ឆ្នាំ មានប៉ុន្មាន? | | | |
| 10 | តើមានសមាជិកគ្រួសារប៉ន្មាននាក់ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ | | | |
| 11 | តើអ្នកណាជារកចំណូល? (បើមានសូមជ្រើសរើស) | | | |
| | បុរស/ប្តី | ១ | ☐ | |
| | ស្ត្រី/ប្រពន្ធ | ២ | ☐ | |
| | ស្ត្រីមេម៉ាយ | ៣ | ☐ | |

| | | | |
|---|---|---|---|
| | កូន/កុមារ | ៤ | ☐ |
| | ជីដូន/ជីតា | ៥ | ☐ |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ........................................................................................................ | | |
| 12 | តើក្នុងគ្រួសារ បានទទួលចំណូលប្រហែលប៉ុន្មានរៀល ក្នុង ០១ ខែ ? | | |
| | មិនមានចំណូលសោះ | ១ | ☐ |
| | តិចជាង ១០ ម៉ឺនរៀល | ២ | ☐ |
| | ពី១០ម៉ឺន ទៅ ២០ ម៉ឺន | ៣ | ☐ |
| | ពី ២០ម៉ឺន ទៅ ៣០ ម៉ឺន | ៤ | ☐ |
| | ពី៣០ម៉ឺន ទៅ ៤០ ម៉ឺន | ៥ | ☐ |
| | ពី ៤០ម៉ឺន ៥០ម៉ឺន | ៦ | ☐ |
| | លើស ៥០ម៉ឺន | ៧ | ☐ |
| 13 | តើគ្រួសារមានប្រភពចំណូលអ្វីខ្លះ/មុខរបរសំខាន់ ? (សូមជ្រើសរើស) | | |
| | កម្មករតាមរោងចក្រ/សំណង់/ | ១ | ☐ |
| | រត់ម៉ូតូឌុប/ រ៉ឺម៉ក | ២ | ☐ |
| | លក់ដូរតាមសហគមន៍ | ៣ | ☐ |
| | ប្រាក់បៀវត្ស (រាជការ បុគ្គលិកក្រុមហ៊ុន ស្ថាប័នមិនមែនរដ្ឋាភិបាល) | ៤ | ☐ |
| | ការងារកសិកម្ម | ៥ | ☐ |
| | សិប្បកម្មលក្ខណៈគ្រួសារ | ៦ | ☐ |
| | រើសអេតចាយ | ៧ | ☐ |
| | លក់ស្រាបៀរ /ក្លឹបកំសាន្ត | ៨ | ☐ |
| | សេវាកម្ម/ ពលកម្ម (បោកគក់ ជួតផ្ទះ កោសខ្យល់ .......... ) | ៩ | ☐ |
| | របរផ្សេងទៀត សូមបញ្ជាក់ ........................................................................................................ | | |
| 14 | តើអ្នកណាជាមេគ្រួសារនេះ? (បើមានសូមជ្រើសរើស) | | |

| | | | |
|---|---|---|---|
| | បុរស/ប្តី | ១ | ☐ |
| | ស្ត្រី/ប្រពន្ធ | ២ | ☐ |
| | ស្ត្រីមេម៉ាយ | ៣ | ☐ |
| | កុមារ | ៤ | ☐ |
| | ជីដូន/ជីតា | ៥ | ☐ |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ................................................................................................................ | | |
| 15 | តើគ្រួសាររបស់លោកអ្នករស់នៅទីណា (សានភាពរស់នៅរបស់គ្រួសារ)?-(សូមជ្រើសរើស) | | |
| | រស់នៅតាមដងផ្លូវរថភ្លើង | ១ | ☐ |
| | រស់នៅតាមផ្លូវធ្វើដំណើរ | ២ | ☐ |
| | រស់នៅតាមប្រឡាយលូទឹក | ៣ | ☐ |
| | រស់នៅតាមច្រាំងទន្លេ | ៤ | ☐ |
| | រស់នៅតាមដីធ្លីដែលរៀបរយរួច | ៥ | ☐ |
| | រស់នៅតាមតំបន់/ដីធ្លីមិនទាន់រៀបរយ | ៦ | ☐ |
| | រស់នៅលើដំបូលអាគារ | ៧ | ☐ |
| | រស់នៅតាមវត្តអារាម ចេតដី | ៨ | ☐ |
| | រស់នៅលើបឹង | ៩ | ☐ |
| | រស់នៅលើដីអ្នកដទៃ | ១០ | ☐ |
| | រស់នៅជាមួយបងប្អូន | ១១ | ☐ |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ................................................................................................................ | | |
| 16 | តើលោកអ្នកមានផ្ទះរស់នៅប្រភេទណា? ប្រភេទលំនៅដ្ឋាន/ផ្ទះ? (សូមជ្រើសរើស) | | |
| | ផ្ទះជួលគេ | ១ | ☐ |
| | ផ្ទះខ្លួនឯង | ២ | ☐ |
| | ផ្ទះប្រើតង់កៅស៊ូបណ្តោះអសន្ន | ៣ | ☐ |
| | ផ្ទះសង់ពីឈើតូចៗប្រក់ស្បូវ/ឬក្រណាត់តង់ | ៤ | ☐ |
| | ផ្ទះសង់ពីឈើតូចៗប្រក់សង្កសី/ឬហ្វីប្រូសីមង់ | ៥ | ☐ |

| | | | | |
|---|---|---|---|---|
| | ផ្ទះឈើប្រក់ក្បឿង | ៦ | ☐ | |
| | ផ្ទះថ្ម/ផ្ទះបេតុង | ៧ | ☐ | |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ........................................ | | | |
| | **ផ្នែកទីពីរ ៖ ព័ត៌មានស្ថានភាពងាយរងគ្រោះរបស់គ្រួសារ** | | | |
| 17 | តើគ្រួសារមានបណ័គ្រួសារដែររឺទេ? | បាទ/ចាស់ | | ១-☐ |
| | | ទេ | | ២-☐ |
| 18 | តើគ្រួសារមានបណ័សៀវភៅស្នាក់នៅដែររឺទេ? | បាទ/ចាស់ | | ១-☐ |
| | | ទេ | | ២-☐ |
| | | សរុប | ស្រី | |
| 19 | តើសមាជិកគ្រួសារប៉ុន្មាននាក់មានសំបុត្រកំណើត/លិខិតបញ្ជាក់កំណើត? | | | |
| 20 | តើមានកុមារប៉ុន្មាននាក់(ក្រោម១៨ឆ្នាំ) មានសំបុត្រកំណើត? | | | |
| 21 | តើសមាជិកគ្រួសារប៉ុន្មាននាក់(អាយុលើ១៨ឆ្នាំ) មានអត្តសញ្ញាណបណ្ណ័? | | | |
| 22 | បច្ចុប្បន្ន តើលោក អ្នកមានកូនអាយុក្រោម១២ខែទេ (ក្រោមមួយឆ្នាំ)? | បាទ/ចាស់ | ១-☐ | បើគ្មាន ចូររំលងសំណួរបន្ទាប់ |
| | | ទេ | ២-☐ | |
| 23 | តើកូនរបស់អ្នកបានទទួលចាក់ថ្នាំបង្ការគ្រប់មុខហើយឬនៅ/ ឬបានចាក់វ៉ាក់សាំងការពារកញ្ជ្រិល ? | បាទ/ចាស់ | ១-☐ | |
| | | ទេ | ២-☐ | |
| | | បានខ្លះៗ | ៣-☐ | |

| | | | | |
|---|---|---|---|---|
| 24 | បច្ចុប្បន្ននេះ- តើក្នុងគ្រួសារមានស្ត្រីមានផ្ទៃពោះទេ? | បាទ/ចាស៎ | ១ - ☐ | បើគ្មាន ចូររំលងពីរសំណួរបន្ទាប់ |
| | | ទេ | ២ - ☐ | |
| 25 | តើស្ត្រី/គាត់/អ្នកបានទៅពិនិត្យផ្ទៃទាំផ្ទៃពោះដែរឬទេ? | បានគ្រប់គ្រាន់ | ១ - ☐ | បើមិនមាន ចូរ រំលងសំណួរបន្ទាប់ |
| | | មិនបាន | ២ - ☐ | |
| | | បានខ្លះៗ | ៣ - ☐ | រំលងសំនួរបន្ទាប់ |
| 26 | តើស្ត្រី/គាត់/អ្នកបានទៅពិនិត្យថែទាំផ្ទៃពោះនៅទីណា? (សូមជ្រើសរើស) | | | |
| | មណ្ឌលសុខភាព | ១ | ☐ | |
| | មន្ទីរពេទ្យ | ២ | ☐ | |
| | គ្លីនិកឯកជន | ៣ | ☐ | |
| | ពេទ្យឆ្មបបុរាណត្បតាមសហគមន៍ | ៤ | ☐ | |
| | ភ្នាក់ងារសុខភាពរបស់អង្គការ/សមាគមន៏នានា | ៥ | ☐ | |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ………………………………………………………………………… | | | |
| 27 | តើស្ត្រី/គាត់/អ្នកបានទៅពិនិត្យថែទាំផ្ទៃពោះដោយមធ្យោបាយណា? | | | |
| | ដោយខ្លួនឯង/ថវិការបស់គ្រួសារ | ១ | ☐ | |
| | មានការគាំទ្រពីដៃគូអភិវឌ្ឍន៏នានា | ២ | ☐ | |
| | មានការគាំទ្រពីអជ្ញាធរមូលដ្ឋាន | ៣ | ☐ | |

| | | | |
|---|---|---|---|
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ........................................................................................................ | | |
| 28 | តើក្នុងគ្រួសារមានកុមារអាយុ ៣-៥ ឆ្នាំទេ? (បើមិនមាន ចូររំលងពីរសំណួរបន្ទាប់) | បាទ/ចាស់ | ១- ☐ |
| | | ទេ | ២- ☐ |
| 29 | បើមាន ប៉ុន្មាននាក់? | សរុប: ...... | ស្រី: ......... |
| 30 | តើក្នុងគ្រួសារមានកុមារអាយុ ៣-៥ ឆ្នាំបានទៅរៀននៅថ្នាក់មត្តេយ្យទេ? | បាទ/ចាស់ | ១- ☐ |
| | | ទេ | ២- ☐ |
| 31 | តើក្នុងគ្រួសារមានកុមារអាយុ ៦-១១ ឆ្នាំដែរទេ? (បើមិនមាន ចូររំលងពីរសំណួរបន្ទាប់) | បាទ/ចាស់ | ១- ☐ |
| | | ទេ | ២- ☐ |
| 32 | បើមាន តើប៉ុន្មាននាក់? | សរុប: ...... | ស្រី: ......... |
| 33 | តើក្នុងគ្រួសារមានកុមារអាយុ ៦-១១ ឆ្នាំបានទៅរៀននៅបឋមសិក្សាទេ? | | |

| | | | | | |
|---|---|---|---|---|---|
| | | បាទ/ចាស់ (កំពុងរៀន) | ១ | ☐ | |
| | | បោះបង់ | ២ | ☐ | |
| | | ទេ | ៣ | ☐ | |
| 34 | តើក្នុងគ្រួសារមានកុមារអាយុ ១២-១៤ ឆ្នាំដែរទេ? (បើមិនមាន ចូររំលងពីរសំណួរបន្ទាប់) | | | បាទ/ចាស់ | ១- ☐ |
| | | | | ទេ | ២- ☐ |
| 35 | បើមាន តើប៉ុន្មាននាក់? | | | សរុប: ...... | ស្រី: ......... |
| 36 | តើក្នុងគ្រួសារមានកុមារអាយុ ១២-១៤ ឆ្នាំបានទៅរៀនមធ្យមសិក្សាទេ? | | | | |
| | | បាទ/ចាស់ | ១ | ☐ | |
| | | បោះបង់ | ២ | ☐ | |
| | | ទេ | ៣ | ☐ | |
| | | | | បាទ/ចាស់ | ១- ☐ |
| 37 | តើមានកូនធ្វើការងារដែលងាយមានគ្រោះថ្នាក់ទេ? | | | ទេ | ២- ☐ |
| 38 | តើមានបង្គន់អនាម័យប្រើប្រាស់ទេ? | | | បាទ/ចាស់ | ១- ☐ |

| | | | | |
|---|---|---|---|---|
| | | ទេ | ២- ☐ | |
| 39 | តើនៅក្នុងគ្រួសារមានកុមារកំព្រា ឬកុមារដែលត្រូវបានបោះបង់ចោលទេ? | បាទ/ចាស់ | ១- ☐ | |
| | | ទេ | ២- ☐ | |
| 40 | តើនៅក្នុងគ្រួសារមានសមាជិកដែលមានជំងឺរ៉ាំរ៉ៃទេ? (អេដស៍) | បាទ/ចាស់ | ១- ☐ | |
| | | ទេ | ២- ☐ | |
| 41 | តើនៅក្នុងគ្រួសារកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភទេ? | បាទ/ចាស់ | ១- ☐ | |
| | | ទេ | ២- ☐ | |
| 42 | តើនៅក្នុងគ្រួសារកុមារពិការដែរឬទេ- រាប់ទាំងពិការរាងកាយ និងផ្លូវចិត្ត? | បាទ/ចាស់ | ១- ☐ | |
| | | ទេ | ២- ☐ | |
| 43 | តើគ្រួសារទទួលបានប័ណ្ណបញ្ជាក់ភាពក្រីក្រទេ? | បាទ/ចាស់ | ១ - ☐ | បើទេ រំលងសំនួរបន្ទាប់ |
| | | ទេ | ២ - ☐ | |

| | | | |
|---|---|---|---|
| 44 | បើបាន តើផ្តល់ដោយអ្នកណា? | | |
| | ក្រុមប្រឹក្សាឃុំ/សង្កាត់ | ១ | ☐ |
| | កម្មវិធី/អង្គការនានា | ២ | ☐ |
| | មិនដឹង | ៣ | ☐ |
| 45 | បច្ចុប្បន្ន- តើគ្រួសារមានជំពាក់បំណុលទេ? បាទ/ចាស៎ | ១ - | ☐ |
| | ទេ | ២ - | ☐ |
| 46 | បើមាន សំរាប់ធ្វើអ្វី? | | |
| | បង្កើតមុខរបរ | ១ | ☐ |
| | ព្យាបាលជំងឺ | ២ | ☐ |
| | ថ្លៃសេវាសំរាលកូន | ៣ | ☐ |
| | បង់ថ្លៃសាលាកូន (បើសាលាឯកជន ឬមហាវិទ្យាល័យ) | ៤ | ☐ |
| | ទិញស្បៀងអាហារបន្ទាន់ | ៥ | ☐ |
| | ធ្វើជំរក អាហារដោយរងគ្រោះនៃគ្រោះមហន្តរាយ | ៦ | ☐ |
| | ផ្សេងទៀត សូមបញ្ជាក់ ........................................................................................................................................ | | |
| 47 | តើគ្រួសារមានមធ្យោបាយធ្វើដំណើរអ្វីខ្លះ? (សូមជ្រើសរើស) | | |
| | ឡាន | ១ | ☐ |
| | ម៉ូតូ | ២ | ☐ |
| | រឺម៉ក | ៣ | ☐ |
| | កង់ | ៤ | ☐ |
| | ស៊ីក្លូ | ៥ | ☐ |

| | | | |
|---|---|---|---|
| | គ្មាន | ៦ | ☐ |
| 48 | តើគ្រួសារមានឧបករណ៍ទំនាក់ទំនងព័ត៌មានអ្វីខ្លះ? (សូមជ្រើសរើស) | | |
| | ទូរទស្សន៍ | ១ | ☐ |
| | ម៉ាញ៉េ/វិទ្យុ | ២ | ☐ |
| | ទូរស័ព្ទដៃ | ៣ | ☐ |
| | ឧបករណ៍ផ្សេងទៀត សូមបញ្ជាក់<br>........................................................................................................................ | | |

## ឧបសម្ព័ន្ធ ៥ ៖ ផែនទីខណ្ឌ កម្រងសំណួរសម្រាប់សម្ភាសន៍សហគមន៍អ្នកក្រីក្រ

លេខសំគាល់បញ្ជីសំណួរ:.............................

សំភាសន៍ដោយ:.................................. លេខទូស័ព្ទ:...........................

| | | | |
|---|---|---|---|
| 1 | ថ្ងៃ /ខែ/ឆ្នាំ សំភាសន៍: | | |
| 2 | ឈ្មោះសហគមន៍: | | |
| 3 | ឈ្មោះភូមិ: | | |
| 4 | ឈ្មោះសង្កាត់: | | |
| 5 | ឈ្មោះខណ្ឌ: | | |
| | **<u>ផ្នែកទីមួយ : ព័ត៌មានមូលដ្ឋានអំពីសហគមន៍</u>** | សរុប | ស្ត្រី |
| 6 | ចំនួនគ្រួសារកំពុងរស់នៅក្នុងសហគមន៍សរុបមានប៉ុន្មាន? | | |
| 7 | តើនៅក្នុងសហគមន៍មានប៉ុន្មានគ្រួសារដែលមានស្ត្រីមេម៉ាយជាមេគ្រួសារ? | | |
| 8 | តើនៅក្នុងសហគមន៍មានប៉ុន្មានគ្រួសារដែលមានស្ត្រីជាមេគ្រួសារ? | | |
| 9 | តើក្នុងសហគមន៍មានប៉ុន្មានគ្រួសារដែលមានកុមារជាមេគ្រួសារ? | | |
| 10 | តើចំនួនមនុស្សកំពុងរស់នៅក្នុងសហគមន៍សរុបប៉ុន្មាន? | | |
| 11 | តើមនុស្សអាយុក្រោម ១៨ ឆ្នាំ មានប៉ុន្មាននាក់? | | |

| | | | |
|---|---|---|---|
| 12 | តើកុមារពិការ នៅក្នុងសហគមន៍សរុបប៉ុន្មាន? | | ☐ |
| 13 | តើកុមារផ្ទុកមេរោគអេដស៍ នៅក្នុងសហគមន៍សរុបប៉ុន្មាន? | | ☐ |
| 14 | ស្ថានភាពរស់នៅរបស់គ្រួសារក្នុងសហគមន៍ (បើមានសូមជ្រើសរើស) | | ចំនួនគ្រួសារ- ប្រសិនជាដឹង |
| | គ្រួសាររស់នៅតាមដងផ្លូវរថភ្លើង | ១- ☐ | ☐ |
| | គ្រួសាររស់នៅតាមផ្លូវធ្វើដំណើរ | ២- ☐ | |
| | គ្រួសាររស់នៅតាមប្រឡាយលូទឹក | ៣- ☐ | |
| | គ្រួសាររស់នៅតាមច្រាំងទន្លេ | ៤- ☐ | |
| | គ្រួសាររស់នៅតាមដីធ្លីដែលរៀបរយរួច | ៥- ☐ | |
| | គ្រួសាររស់នៅតាមតំបន់/ដីធ្លីមិនទាន់រៀបរយ | ៦- ☐ | |
| | គ្រួសាររស់នៅលើដំបូលអាគារ | ៧- ☐ | |
| | គ្រួសារដែលរស់នៅតាមវត្តអារាម ចេតិយ | ៨- ☐ | |
| | គ្រួសារដែលរស់នៅលើបឹង | ៩- ☐ | |
| | គ្រួសារដែលរស់នៅលើដីអ្នកដទៃ | ១០- ☐ | |
| | ប្រភេទផ្សេងទៀត សូមបញ្ជាក់ ........................................................................................................ | | |